សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អាពាហ៍ពិពាហ៍ និង ការលែងលះ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៦

តាក់តែងឡើងដោយ ៖
និស្សិតឈ្មោះ **មាស វង្សសុគា**
**ឆន មួយគា**

សាស្ត្រាចារ្យណែនាំ
លោក **អម សុផាណារ៉ាត**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **មាស ចន្ទសុគា** និង **ឆន មួយគា** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ផ្នែកនីតិសាស្រ្ត ឆ្នាំសិក្សា ២០១២-២០១៦។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ លោកឪពុក អ្នកម្ដាយជាទីគោរពស្រលាញ់នៃកូនដែលលោកបានផ្ដល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាកូនដោយក្ដីមេត្តាករុណា និង ផ្ដល់ក្ដីស្រលាញ់ចំពោះកូនតាំងពីតូចរហូតដល់ធំពេញវ័យ ហើយរូបលោកបានលះបង់គ្រប់បែបយ៉ាងទាំងកម្លាំងកាយចិត្ត និង ថវិកា ដើម្បីឲ្យរូបកូនបានសិក្សារៀនសូត្រ ព្រមទាំងខិតខំអប់រំ ផ្ដល់ដំបូន្មានប្រៀនប្រដៅឲ្យរូបកូនដើរក្នុងផ្លូវល្អ មិនឲ្យប្រព្រឹត្តនូវអំពើណាដែលសង្គមស្អប់ខ្ពើម ដោយឲ្យកូនប្រតិបត្តិតែអំពើសុចរិតទៀងត្រង់ ព្រមទាំងបានជំរុញលើកទាំងចិត្តដល់រូបកូនក្នុងការសិក្សារៀនសូត្រ និង តម្រង់ទិសកូនឲ្យក្លាយទៅជាពលរដ្ឋល្អក្នុងសង្គម។ ដោយការយកចិត្តទុកដាក់ និង ការខិតខំប្រឹងប្រែងរបស់លោកទាំងពីរ ទើបធ្វើអោយកូនឈានមកដល់ថ្ងៃនេះ គឺថ្ងៃដែលកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្របានជោគជ័យ។

ទន្ទឹមគ្នានេះដែរ យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា** ដែលលោកជាអ្នកគ្រប់គ្រងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ហើយលោកបានផ្ដល់ជាកន្លែងសិក្សាដល់រូបយើងខ្ញុំទាំងពីរបានសិក្សារហូតបានសម្រេចជាលទ្ធផលបង្កើតជាស្នាដៃនេះឡើង។

ជាងនេះទៅទៀត សូមថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យ អម សុផាណារ៉ាត** ដែលជាសាស្រ្តាចារ្យណែនាំដល់ពួកយើងខ្ញុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ធ្វើការបង្ហាត់បង្ហាញ ណែនាំ កែតម្រូវ ផ្ដល់ជាអនុសាសន៍ និង ប្រាប់ទិសដៅឲ្យយើងក្នុងការបង្កើតកិច្ចការស្រាវជ្រាវបានដោយជោគជ័យ។

ម្យ៉ាងទៀត យើងខ្ញុំទាំងពីរក៏សូមថ្លែងអំណរគុណ និង ដឹងគុណចំពោះ លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យទាំងអស់ ដែលបានខិតខំបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្ត និង ផ្ដល់នូវចំណេះដឹងយ៉ាងច្រើន និង ពិតប្រាកដទៅដល់ពួកយើងខ្ញុំទាំងពីរអោយឈានដល់ការបង្កើតស្នាដៃនេះឡើង។

មួយវិញទៀតសូមថ្លែងអំណរគុណដល់បងប្អូន សិស្សច្បង មិត្តភក្ដិទាំងអស់ដែលបានជួយជ្រោមជ្រែង លើកទឹកចិត្ត និង ផ្ដល់ជាមតិយោគបល់ល្អៗជាច្រើន ក៏ដូចជាចែករំលែកនូវបទពិសោធន៍នានា ដល់ពួកយើងខ្ញុំទាំងពីរ។

ចុងបញ្ចប់នេះ យើងខ្ញុំទាំងពីរសូមអោយវត្ថុស័ក្ដសិទ្ធិទាំងអស់ក្នុងលោកតាមថែរក្សាការពារ និង ប្រសិទ្ធពរជ័យ សិរីសួស្ដីជូនដល់អស់លោកទាំងអស់ឲ្យជួបប្រទះតែនឹងសេចក្ដីសុខ សេចក្ដីចម្រើន សុខភាពល្អ កាយសម្បទារឹងមាំ អាយុយឺនយូរ និង ទទួលបានជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធិពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីទទួលបានការសិក្សាថ្នាក់បរិញ្ញាត្រនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំកន្លងមក និងបានសិក្សាលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និង ផ្នែកនីតិសាធារណៈរួចមក យើងខ្ញុំទាំងពីរបានទទួលនូវចំណេះដឹងទូលំទូលាយលើមុខវិជ្ជាទាំងនោះ ក្រោមការខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ មកដល់ពួកយើងខ្ញុំ។ ដោយការជួយជ្រោមជ្រែង និងការយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្តទាំងអស់នេះហើយ ទើបធ្វើអោយយើងខ្ញុំអាចឈានមកដល់ការចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាត្រនីតិសាស្ត្រនេះ។ការរៀបចំសរសេរសារណានេះឡើង ក្នុងគោលដៅដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី១៦នេះ និង ដើម្បីចូលរួមចំណែកនៅក្នុងសង្គម។ ការសរសេរសារណា ត្រូវតម្រូវអោយយើងមាន សមត្ថភាព និង ចំណេះដឹងខ្ពស់ក្នុងការចងក្រងវាឡើងមក ព្រោះការចងក្រងសារណាមួយឡើងមក យើងត្រូវជួបប្រទះនូវការលំបាកជាច្រើន ទើបយើងអាចទទួលបាននូវលទ្ធផលល្អ។

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះក្រុមយើងខ្ញុំបានសម្រេចជ្រើសរើសប្រធានបទមួយដែលទាក់ទងទៅនឹងផ្នែកនីតិឯកជន ដែលមានចំណងជើងថា «អាពាហ៍ពិពាហ៍ និង ការលែងលះ»។ការជ្រើសរើសប្រធានបទនេះឡើងមកគឺដើម្បីអោយបុគ្គលគ្រប់រូបយល់ដឹងកាន់តែច្បាស់អំពីបែបបទនៃការរៀបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈស្របទៅតាមច្បាប់ដែលបានតាក់តែងឡើង មិនតែប៉ុណ្ណោះគឺដើម្បីអោយបុគ្គលគ្រប់រូបដែលមានបញ្ហាក្នុងចំណងអាពាហ៍ពិពាហ៍មានភាពរកាំរកូស មានភាពមិនចុះសម្រុងក្នុងគ្រួសារ ហើយចង់ផ្តាច់ចំណងអាពាហ៍ពិពាហ៍នោះអោយជ្រាបច្បាស់អំពីនីតិវិធីនៃការលែងលះ ការបែងចែកទ្រព្យសម្បត្តិ ការផ្តល់អាហារកិច្ចជាដើម។ អាពាហ៍ពិពាហ៍ និង ការលែងលះ ត្រូវបានកំនត់នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ដែលប្រកាសអោយប្រើនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដោយ អនុក្រឹត្យលេខ ៥៦។ ប៉ុន្តែក្នុងពេលបច្ចុប្បន្នច្បាប់នេះត្រូវបាននិរាករណ៍ចោលទៅហើយ ហើយបានជំនួសនូវក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ទៅវិញ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងអាចជាជំនួយក្នុងការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិត និង ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលចង់ស្វែងយល់បន្ថែមទាក់ទងនឹងអាពាហ៍ពិពាហ៍ និង ការលែងលះដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ហើយនឹងទុកជាស្នាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីសិក្សាបន្ថែមអោយកាន់តែច្បាស់អំពីនីតិវិធីក្នុងការរៀបអាពាហ៍ពិពាហ៍ និង ការលែងលះ ក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់ចំនុចខ្វះខាតមួយចំនួនដូចជាពាក្យពេចន៍ខ្លឹមសារអត្ថន័យ ឬ អក្ខរាវារុទ្ធទាំងឡាយ ដែលមានក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយអចេតនា។ ហើយក្រុមយើងខ្ញុំនឹងទទួលស្វាគមន៍ជានិច្ចនូវរាល់ការរិះគន់ក្នុងន័យស្ថាបនាជាមួយនឹងគំនិតយោបល់ល្អៗផ្សេងៗរបស់មិត្តអ្នកអានទាំងអស់ ដើម្បីធ្វើការកែលំអរ នឹងធ្វើឲ្យល្អប្រសើរជាងមុន។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................................................ ០១

## ជំពូកទី១
## កំជាប់ពាក្យ

ផ្នែកទី១ និយមន័យ និង ការបង្កើត ........................................................ ០៥
កថាខណ្ឌទី១ ការបង្កើតកំជាប់ពាក្យ ........................................................ ០៥
១.លក្ខខណ្ឌបង្កើតកំជាប់ពាក្យតាមប្រពៃណី ........................................................ ០៦
១.១.ការចែចូវ ........................................................ ០៦
១.២.ការស្តីដណ្តឹង ........................................................ ០៦
១.៣.សេចក្តីសន្យា ........................................................ ០៧
១.៤.ពិធីកំជាប់ពាក្យ ........................................................ ០៨
២.លក្ខខណ្ឌផ្លូវច្បាប់នៃកំជាប់ពាក្យ ........................................................ ០៨
៣.ការមិនកំនត់លក្ខខណ្ឌអាយុកូនប្រុសស្រីក្នុងកំជាប់ពាក្យ ........................................................ ០៩
ផ្នែកទី២ ការរលាយនៃកំជាប់ពាក្យ ........................................................ ១០
កថាខណ្ឌទី១ ការទទួលខុសត្រូវចំពោះការបដិសេធដោយគ្មានមូលហេតុត្រឹមត្រូវ ........................................................ ១០
កថាខណ្ឌទី២ ការសងជំនូន ........................................................ ១១
កថាខណ្ឌទី៣ ភាគីអាចទាមទារឱ្យសងជំនូន ........................................................ ១១
កថាខណ្ឌទី៤ ភាគីអាចទាមទារឱ្យសងសំណងនៃការខូចខាត ........................................................ ១៣
កថាខណ្ឌទី៥ អំឡុងពេលនៃការទាមទារសំណងខូចខាត ........................................................ ១៣

## ជំពូកទី២
## អាពាហ៍ពិពាហ៍

ផ្នែកទី១ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍ ........................................................ ១៥

កថាខណ្ឌទី១ និយមន័យនៃអាពាហ៍ពិពាហ៍ .................... ១៦
កថាខណ្ឌទី២ និយមន័យនៃគ្រួសារ .................... ១៦
ផ្នែកទី២ ការបង្កើតអាពាហ៍ពិពាហ៍ .................... ១៧
កថាខណ្ឌទី១ លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍ .................... ១៧
១.ភេទរបស់ភាគី .................... ១៧
២.គោលការណ៍ស្ម័គ្រចិត្ត .................... ១៨
៣.អាយុសម្រាប់រៀបអាពាហ៍ពិពាហ៍ .................... ១៩
៤.ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន .................... ២០
៥.ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ .................... ២០
៦.ការយល់ព្រមលើការរៀបអាពាហ៍ពិពាហ៍ .................... ២១
៧.ការណីលើកលែងសមត្ថភាពផ្លូវកាយ និង ស្មារតី .................... ២១
៨.ការយល់ព្រមចំពោះការរៀបអាពាហ៍ពិពាហ៍នៅពេលសហព័ទ្ធអវត្តមានឬ
ការបាត់ខ្លួន .................... ២២
៨.១.បុគ្គលអវត្តមានលើសពី៥ឆ្នាំ .................... ២២
៨.២.បុគលបាត់ខ្លួនក្រោយជួបឧបទ្ទវហេតុលើសពី១ឆ្នាំ
កថាខណ្ឌទី២ លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ .................... ២៤
១.ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ .................... ២៤
២.ប័ណ្ណប្រកាសជាសាធារណៈ .................... ២៤
៣.រយៈពេលរង់ចាំ .................... ២៥
៤.ជនអាចប្តឹងជំទាស់អាពាហ៍ពិពាហ៍ .................... ២៥
៥.មូលហេតុជំទាស់នឹងគម្រោងអាពាហ៍ពិពាហ៍ .................... ២៦
៦.ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ .................... ២៦
៧.ការចេញសំបុត្រអាពាហ៍ពិពាហ៍ .................... ២៧
កថាខណ្ឌទី៣ លក្ខខណ្ឌហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ .................... ២៧
១.ការហាមមិនឱ្យមានទ្វេរពន្ធភាព .................... ២៧
២.អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី .................... ២៨
៣.ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងញាតិលោហិត .................... ២៩
៣.១. ហាមការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់ .................... ២៩
៣.២. ហាមការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិត .................... ៣០

៣.៣.ហាមការរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬ ម្ដាយបង្កើត ជាមួយអតីតកូនបង្កើត ..... ៣០
៣.៤.ហាមការរៀបអាពាហ៍ពិពាហ៍អតីតឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹមជាមួយកូនសុំ ..... ៣០
៤.ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ ..... ៣១
៤.១. ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់ ..... ៣១
៤.២. ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ ..... ៣២
៤.៣. ការហាមមិនរៀបអាពាហ៍ពិពាហ៍រវាងឪពុកម្ដាយចុងជាមួយកូនចុង ..... ៣៣
៤.៤. ករណីលើកលែងអាចរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ ..... ៣៣
ផ្នែកទី៣ អានុភាពនៃអាពាហ៍ពិពាហ៍ ..... ៣៣
កថាខណ្ឌទី១ នាមត្រកូលរបស់ប្ដីប្រពន្ធ ..... ៣៣
កថាខណ្ឌទី២ ករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមក ..... ៣៤
កថាខណ្ឌទី៣ សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ..... ៣៤
កថាខណ្ឌទី៤ សិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងលើទ្រព្យរួម ..... ៣៦
ផ្នែកទី៤ មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍ ..... ៣៧
កថាខណ្ឌទី១ មោឃភាពនៃអាពាហ៍ពិពាហ៍ ..... ៣៧
១.មោឃភាពដាច់ខាត ..... ៣៨
១.១.ការភាន់ច្រឡំលើមនុស្ស ..... ៣៨
១.២.ការបង្ខិតបង្ខំ ..... ៣៨
២.មោឃភាពមិនដាច់ខាត ..... ៣៩
២.១.ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ..... ៣៩
២.២.ភាគីមិនបានជូនដំណឹងជាសាធារណៈ ..... ៣៩
២.៣.ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ..... ៤០
២.៤.ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ..... ៤០
កថាខណ្ឌទី២ ការលុបចោលអាពាហ៍ពិពាហ៍ ..... ៤០
១.អាពាហ៍ពិពាហ៍មិនគ្រប់អាយុ ..... ៤១

២.ការមានទេ្វពន្ធភាព........................................................................................ ៤២
៣.ការលុបចោលអាពាហ៍ពិពាហ៍ធ្វើក្នុងអំឡុងពេលហាមឃាត់មិនអោយរៀប
អាពាហ៍ពិពាហ៍ថ្មីទៀត ........................................................................................ ៤២
៤.ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិលោហិត................................................... ៤៣
៥.ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិពន្ធ......................................................... ៤៣
៦.ការលុបអាពាហ៍ពិពាហ៍ដោយការឆបោក............................................................. ៤៤
៧.ការលុបចោលអាពាហ៍ពិពាហ៍ដោយការគំរាម ........................................................ ៤៤
៨.អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍............................................................ ៤៤

## ជំពូកទី៣
## ការលែងលះ

ផ្នែកទី១ សញ្ញាណនៃការលែងលះ........................................................................... ៤៦
កថាខណ្ឌទី១ និយមន័យ ........................................................................................ ៤៦
កថាខណ្ឌទី២ ប្រភេទនៃការលែងលះ ....................................................................... ៤៧
១.ការលែងលះជាឯកតោភាគី ................................................................................ ៤៧
២.ការលែងលះជាទេ្វភាគី ..................................................................................... ៤៧
ផ្នែកទី២ មូលហេតុ និង នីតិវិធីនៃការលែងលះ ...................................................... ៤៨
កថាខណ្ឌទី១ មូលហេតុនៃការលែងលះ ................................................................... ៤៨
កថាខណ្ឌទី២ នីតិវិធីនៃការលែងលះ ...................................................................... ៤៩
១.បណ្តឹងនៃការលែងលះ........................................................................................ ៤៩
១.១.អ្នកមានសិទ្ធិប្តឹងលែងលះ.............................................................................. ៥០
១.២.ទម្រង់នៃបណ្តឹងលែងលះ............................................................................... ៥០
២.សមត្ថកិច្ចក្រុមប្រឹក្សាឃុំ-សង្កាត់ ....................................................................... ៥១
៣.សមត្ថកិច្ចសាលាដំបូងរាជធានី-ខេត្ត .................................................................. ៥២
៣.១.ការដាក់ពាក្យបណ្តឹង ..................................................................................... ៥៣
៣.២.ការពិនិត្យពាក្យបណ្តឹង ................................................................................... ៥៣

៣.៣.ការទទួលពាក្យបណ្ដឹង ........ ៥៤
៣.៤.ការបញ្ជូនពាក្យបណ្ដឹង ........ ៥៤
៣.៥.នីតិវិធីត្រៀមសម្រាប់ទាញហេតុផល ........ ៥៥
៣.៦.នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ ........ ៥៦
៣.៧.ការប្រកាសសាលក្រម ........ ៥៦
៣.៧.១.សាលក្រមចំពោះមុខ ........ ៥៧
៣.៧.២.សាលក្រមកំបាំងមុខ ........ ៥៧

ផ្នែកទី៣ អានុភាពនៃការលែងលះ ........ ៥៨
កថាខណ្ឌទី១ ការរំលាយចំណងអាពាហ៍ពិពាហ៍ ........ ៥៨

កថាខណ្ឌទី២ ការបែងចែកទ្រព្យ ........ ៥៨

១.ការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀង ........ ៥៨
២.ការបែងចែកទ្រព្យសម្បត្តិដោយគ្មានការព្រមព្រៀង ........ ៥៩

កថាខណ្ឌទី៣ ការបែងចែកកូន ........ ៦០
១.ការបែងចែកកូនតាមការព្រមព្រៀងរបស់ភាគី ........ ៦០
២.ការបែងចែកកូនតាមការមិនព្រមព្រៀងរបស់ភាគី ........ ៦១
កថាខណ្ឌទី៤ អាហារកិច្ច ........ ៦២
១.អាហារកិច្ចចំពោះកូន ........ ៦២
១.១.អាហារកិច្ចដោយការព្រមព្រៀងរបស់ភាគី ........ ៦២
១.២.អាហារកិច្ចដោយមិនមានការព្រមព្រៀង ........ ៦២
២.អាហារកិច្ចចំពោះសហព័ទ្ធ ........ ៦៣
២.១.អាហារកិច្ចចំពោះសហព័ទ្ធដោយការព្រមព្រៀង ........ ៦៣
២.២.អាហារកិច្ចចំពោះសហព័ទ្ធដោយមិនមានការព្រមព្រៀងរបស់ភាគី ........ ៦៤
សេចក្ដីសន្និដ្ឋាន ........ ៦៥

អនុសាសន៍ ........ ៦៦

ឯកសារយោង

ឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

## ១.លំនាំបញ្ហា

ធម្មជាតិបានបង្កើតអោយមានមនុស្សប្រុស និង មនុស្សស្រី ហើយបុរស និង ស្រ្តី នេះទៀតសោត ពេលដែលចំរើនវ័យកម្លោះក្រមុំទៅមានតួនាទីត្រូវបង្កើតគ្រួសារជាមួយគ្នា ដើម្បីបន្តពូជពង្សវង្សត្រកូលដោយបង្កើតអោយមានកូនចៅជំនាន់ក្រោយបន្តវៀងមក។ ដើម្បីរួមរស់នឹងបង្កើតគ្រួសារជាមួយគ្នាបាន បុរស និង នារី ត្រូវបង្កើតអោយមានចំណងអាពាហ៍ពិពាហ៍ជាមុនសិន ហើយចំណងអាពាហ៍ពិពាហ៍អាចកើតមានឡើងបានលុះត្រាតែមានសេចក្តីស្រលាញ់ពេញចិត្តចំពោះគ្នាទៅវិញទៅមករវាងបុរស និង ស្រ្តី។

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសដែលមានអរិយធម៌សំបូរបែប មិនទទួលស្គាល់ការរស់នៅជាអនីតិសង្វាសឡើយ។ តាំងពីបុរាណមក ការរៀបអាពាហ៍ពិពាហ៍បានប្រារព្ធធ្វើតាមបែបសាសនា ប្រពៃណី ទំនៀមទំលាប់ ដោយមិនមានការចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ប៉ុន្តែគេអាចសម្គាល់ថាបុរស និង ស្ត្រីដែលមានបំណងចង់រស់នៅជាមួយគ្នានោះជាប្តីប្រពន្ធស្របច្បាប់បាន។ ចំណែកឯក្នុងសម័យបច្ចុប្បន្នវិញ ដើម្បីទទួលបានសិទ្ធិជាប្តីប្រពន្ធស្របច្បាប់ គឺគេរៀបចំធ្វើពិធីតាមបែប សាសនា ប្រពៃណី ទំនៀមទំលាប់ផង និងទៅចុះសំបុត្រអាពាហ៍ពិពាហ៍ដោយបំពេញទៅតាមអ្វីដែលច្បាប់បានកំណត់ផង ទើបអាពាហ៍ពិពាហ៍នោះមានលក្ខណៈស្របច្បាប់។ ទន្ទឹមនឹងការរៀបអាពាហ៍ពិពាហ៍នេះផងដែរ ក៏មានគូស្វាមីភរិយាមួយចំនួន នៅពេលដែលបានរួមរស់ជាមួយគ្នាអស់រយៈពេលច្រើនឆ្នាំហើយ ក៏បែរជាមានបញ្ហា រស់នៅមិនចុះសម្រុងនឹងគ្នា មានភាពរកាំរកូស ឈ្លោះប្រកែកទាស់ទែងគ្នា ការផិតក្បត់ ឬអស់មនោសញ្ចេតនានឹងគ្នា ជាដើម។ ហើយការមានបញ្ហាទាំងអស់នេះជាមួយគ្នាជារៀងរាល់ថ្ងៃ ហើយគ្មានការដោះស្រាយនឹងគ្នាយូរៗទៅ ក៏បណ្តាលអោយគូភាគីអស់មនោសញ្ចេតនានឹងគ្នា ហើយនាំអោយឈានទៅដល់ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ដែលហៅថា «ការលែងលះ»។ នៅពេលមានការលែងលះ កើតឡើងធ្វើ អោយមានផលលំបាកជាច្រើនទៅដល់ក្រុមគ្រួសារ ជាពិសេសគឺប៉ះពាល់ដល់អារម្មណ៍កូនៗរបស់ពួកគេ ដោយសារមានការបែងចែកទ្រព្យ និង ការបែងចែកកូន ជាដើម។ល។ ម្យ៉ាងទៀតការលែងលះគ្នាត្រូវឆ្លងកាត់ដំណាក់កាលជាច្រើន ហើយអាចឈានទៅដល់ដំណាក់កាលតុលាការទៀតផង។

អាស្រ័យហេតុនេះ ទើបក្រុមយើងខ្ញុំលើកយកប្រធានបទដែលទាក់ទងនឹង «អាពាហ៍ពិពាហ៍ និង ការលែងលះ» នេះមកធ្វើការបកស្រាយ។ ដោយសារប្រធានបទនេះ អាចជួយកែប្រែរាល់ការ

អនុវត្តដែលមិនត្រឹមត្រូវមួយចំនួន និង ដើម្បីចែករំលែកអោយមហាជនទាំងអស់បានស្វែងយល់កាន់តែច្បាស់។

## ២.ចំណោទបញ្ហា

ដើម្បីអោយអាពាហ៍ពិពាហ៍មួយអាចប្រព្រឹត្តទៅដោយស្របច្បាប់ តើត្រូវបំពេញនូវលក្ខខណ្ឌគតិយុត្តអ្វីខ្លះ? តើមានមូលហេតុអ្វីខ្លះ ដែលនាំអោយមានការលែងលះគ្នា?

នៅពេលមានវិវាទអាពាហ៍ពិពាហ៍កើតឡើង តើស្ថាប័នណាខ្លះដែលមានសមត្ថកិច្ចដោះស្រាយ? តើនីតិវិធីក្នុងការដោះស្រាយប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះដើម្បីអោយការលែងលះនោះមានអានុភាពគតិយុត្ត?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃប្រធានបទ គឺដើម្បីអោយការរៀបអាពាហ៍ពិពាហ៍ និង ការលែងលះអាចប្រព្រឹត្តទៅដោយរលូន និង ស្របទៅតាមច្បាប់កំណត់។ ហើយម្យ៉ាងទៀតចង់អោយអាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីភារកិច្ចទាក់ទងទៅនឹងផ្នែកនេះ អាចអនុវត្តការងារអោយបានម៉ត់ចត់ និង យកចិត្តទុកដាក់ខ្ពស់ចំពោះការងារ ដើម្បីផ្តល់ភាពងាយស្រួល និង បង្កើនទំនុកចិត្តដល់ប្រជាពលរដ្ឋដែលមានបញ្ហាទាំងអស់នេះ។

ការចូលរួមអនុវត្តពីស្ថាប័នដែលពាក់ព័ន្ធនឹងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ជារឿងដែលចាំបាច់បំផុត ដើម្បីអោយសង្គមមានការអភិវឌ្ឍន៍រីកចំរើនទៅមុខខ្លាំង។ ដូចនេះ អាជ្ញាធរដែលមានភារកិច្ចទាក់ទងនឹងផ្នែកនេះមិនត្រូវធ្វេសប្រហែសចំពោះការងាររបស់ខ្លួនឡើង។

ការរួមគ្នាអនុវត្តច្បាប់អោយបានត្រឹមត្រូវទាំងអាជ្ញាធរ និង ប្រជាពលរដ្ឋ គឺជាចំណែកមួយក៏សំខាន់ ដើម្បីអោយប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាយើងមានភាពរឹងមាំ និង រីកចម្រើនទៅមុខយ៉ាងរហ័ស។

## ៤.ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទខាងលើនេះ មានដែនកំណត់ស្ថិតក្រោម រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ ច្បាប់ស្តីពីឯកពន្ធភាព

ឆ្នាំ២០០៦ និង អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន។ ហើយប្រធានបទស្តីពីអាពាហ៍ពិពាហ៍ និង ការលែងលះ នេះ មានវិសាលភាពគ្របដណ្តប់ទៅលើផ្នែកនៃនីតិអាពាហ៍ពិពាហ៍ និង គ្រួសារ ក្នុង ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

សារៈប្រយោជន៍នៃប្រធានបទនេះ គឺដើម្បីអោយមហាជនក៏ដូចជាសិស្សានុសិស្ស និស្សិត បញ្ញាវន្តទាំងអស់បានយល់ដឹងអោយបានច្បាស់ពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍មួយអោយមាន លក្ខណៈស្របទៅតាមច្បាប់របស់ប្រទេសកម្ពុជាយើង ដើម្បីចៀសវាងការរៀបអាពាហ៍ពិពាហ៍ដែល មិនត្រឹមត្រូវតាមគោលការណ៍ដែលច្បាប់តំរូវព្រោះអាចនាំអោយមានបញ្ហាទៅថ្ងៃខាងមុខ។ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋទាំងអស់ក៏ត្រូវយល់ដឹងអោយបានច្បាស់អំពីនីតិវិធីនៃការលែងលះផង ដែរ។ ចៀសវាង នៅពេលមានវិវាទអាពាហ៍ពិពាហ៍កើតឡើង យើងមិនដឹងថាត្រូវរកស្ថាប័នណាមួយ អោយជួយដោះស្រាយ ហើយយើងមិនដឹងអំពីបែបបទក្នុងការដោះស្រាយបញ្ហាជាដើម។

ជាងនេះទៅទៀត ការរៀបចំចងក្រងអំពីប្រធានបទនេះ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ ប្រព័ន្ធច្បាប់នៅព្រះរាជាណាចក្រកម្ពុជាអោយកាន់តែមានភាពប្រសើរឡើង និង រីកចំរើនទៅមុខ ជាបន្តបន្ទាប់។

## ៦.វិធីសាស្ត្រស្រាវជ្រាវ

ប្រធានបទខាងលើនេះ យើងខ្ញុំបានខិតខំស្រាវជ្រាវយ៉ាងសស្រាក់សស្រាំ ដើម្បីប្រមូលនូវ ឯកសារមួយចំនួន និង ច្បាប់ពាក់ព័ន្ធនានា ការស្រាវជ្រាវតាមបណ្តាញអ៊ីនធឺណេត រួមទាំងចំណេះ ដឹងដែលទទួលបានពីលោកគ្រូ អ្នកគ្រូ ដែលជាសាស្ត្រាចារ្យ ដើម្បីធ្វើការចងក្រងបង្កើតស្នាដៃនេះ ឡើង។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទ «អាពាហ៍ពិពាហ៍ និង ការលែងលះ» យើងខ្ញុំបានធ្វើការ បែងចែកជា ៣ ជំពូកគឺ៖

## ជំពូកទី១ កំដាប់ពាក្យ

ផ្នែកទី១ និយមន័យ និង ការបង្កើតកំដាប់ពាក្យ
ផ្នែកទី២ ការរលាយនៃកំដាប់ពាក្យ

## ជំពូកទី២ អាពាហ៍ពិពាហ៍

ផ្នែកទី១ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍
ផ្នែកទី២ ការបង្កើតអាពាហ៍ពិពាហ៍
ផ្នែកទី៣ អានុភាពនៃអាពាហ៍ពិពាហ៍
ផ្នែកទី៤ មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

## ជំពូកទី៣ ការលែងលះ

ផ្នែកទី១ សញ្ញាណនៃការលែងលះ
ផ្នែកទី២ មូលហេតុ និង នីតិវិធីនៃការលែងលះ
ផ្នែកទី៣ អានុភាពនៃការលែងលះ

ចំពោះខ្លឹមសារ និងចំណុចលម្អិតសំខាន់ៗជាច្រើនទៀត ដែលមាននៅក្នុងប្រធានបទនេះ យើងនឹងធ្វើការបកស្រាយនៅទំព័របន្តបន្ទាប់ទៀតនៃសារណាមួយនេះ។

# ជំពូកទី១
# កំជាប់ពាក្យ

## ផ្នែកទី១ និយមន័យ និង ការបង្កើតកំជាប់ពាក្យ

កំជាប់ពាក្យ សំដៅដល់ពិធីតាមទំនៀមទំលាប់ប្រពៃណីដែលច្បាប់ទទួលស្គាល់ដែល តាមរយៈពិធីនេះ បុរស និង នារី សន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។

កំជាប់ពាក្យ ត្រូវបង្កើតឡើងតាមការសន្យារវាងបុរស នារី ថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នានឹងគ្នា នាពេលអនាគត និង ដោយធ្វើពិធីកំជាប់ពាក្យ[1]។ ដោយហេតុថា ការសន្យានេះហើយទើបធ្វើឲ្យបុរស និង នារីត្រូវធ្វើពិធីកំជាប់ពាក្យ ដើម្បីបញ្ជាក់ថាអ្នកទាំងពីរជាគូនឹងគ្នា ហើយដើម្បីប្រកាសប្រាប់មនុស្សទាំងអស់គ្នាថាបុរស និង នារីនោះមានម្ចាស់រួចហើយ ។

កំជាប់ពាក្យ ជាការសន្យារបស់បុរស និង នារី ប៉ុន្តែការសន្យានេះមានលក្ខណៈខុសពីកិច្ចសន្យា មានន័យថា ជាគោលការណ៍ បើកិច្ចសន្យាគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ ឬ គ្មានកំហុសនោះទេ ភាគីត្រូវតែអនុវត្តកិច្ចសន្យា ។

នៅក្នុងសង្គមកម្ពុជា មុននឹងឈានដល់ការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ តែងតែមានការរៀបចំពិធីកំជាប់ពាក្យដើម្បីធ្វើជាសក្ខីភាពនៃការសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ ដោយនៅក្នុងពិធីកំជាប់ពាក្យតែងតែមានជំនូនដែលជាទម្លាប់ គឺខាងប្រុសយកជំនូនមកឲ្យខាងស្រី ដោយជំនូន គឺជាភស្តុតាង ឬ ជាបណ្ណាការដែលភាគីម្ខាងជូនទៅភាគីម្ខាងទៀតនៅក្នុងអំឡុងពេលរៀបចំពិធីកំជាប់ពាក្យ ។

### កថាខណ្ឌទី១ ការបង្កើតកំជាប់ពាក្យ

កំជាប់ពាក្យ គឺជាពិធីមួយដែលគេធ្វើឡើងនៅមុនពេលអាពាហ៍ពិពាហ៍ ដើម្បីជាសញ្ញាណមួយបញ្ជាក់ថាបុរស ឬ នារីនោះមានគូកំណាន់ និង ម្ចាស់ចិត្តរួចហើយ ។ លើសពីនេះទៅទៀត វាក៏ជាលក្ខខណ្ឌមួយសម្រាប់គ្រួសារទាំងពីរ ដែលមានន័យថាពួកគេបានភ្ជាប់សាច់ឈាមនឹងគ្នាហើយដោយសារពិធីកំជាប់ពាក្យនេះ។ ម៉្យាងវិញទៀត ការបង្កើតកំជាប់ពាក្យ ត្រូវកើតឡើងទៅតាមផ្លូវច្បាប់

[1] មាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ដោយមានការព្រមព្រៀងពីភាគីខាងកូនប្រុស និង ភាគីខាងកូនស្រី មុនពេលរៀបអាពាហ៍ពិពាហ៍ទៅតាមផ្លូវច្បាប់ ។

## ១.លក្ខខណ្ឌបង្កើតកំជាប់ពាក្យតាមប្រពៃណី

បើយោងទៅតាមចាស់បុរាណ ការបង្កើតពិធីកំជាប់ពាក្យនេះគេត្រូវធ្វើឡើងទៅតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

### ១.១. ការចែចូវ

ការចែចូវ ធ្វើឡើងនៅពេលដែលមាតាបិតាខាងកូនប្រុសបានមើលឃើញកូនស្រីរបស់នរណាម្នាក់ ឬ ពេញចិត្តនឹងកូនស្រីនរណាម្នាក់ ដោយចង់បានធ្វើជាកូនប្រសារ នោះគាត់នឹងពឹងពាក់អ្នកដែលមានមុខមាត់ មានគេគោរពច្រើនក្នុងភូមិ (អ្នកផ្លូវ) ដើម្បីចូលសើបសួរពីមាតាបិតាខាងកូនស្រី ថាកូនគាត់នៅទំនេរ ឬ មួយក៏អត់ ។ ការចូលចែចូវនេះគេធ្វើឡើងបីលើកគឺ៖

- លើកទីមួយ អ្នកផ្លូវចូលទៅសួរសុខទុក្ខធម្មតាដោយគ្មានកាន់អ្វីនៅក្នុងដៃទៅជាមួយទេ។
- លើកទីពីរ អ្នកផ្លូវចូលទៅដៃទទេដដែល តែចូលទៅម្តងនេះគឺដើម្បីស្ទង់មើលចិត្តថ្លើមមាតាបិតាខាងកូនស្រីតែប៉ុណ្ណោះ។
- លើកទីបី នៅពេលដែលបានដឹងថាមានសង្ឃឹមហើយថាមាតាបិតាខាងកូនស្រីយល់ព្រមហើយនោះ អ្នកផ្លូវត្រូវចូលទៅម្តងទៀត ដោយម្តងនេះត្រូវកាន់នូវរបស់ជាប់ដៃទៅជាមួយផងដែលរួមមាន បារី ម្លូស្លា ដាក់ក្នុងពានយកទៅជាមួយផង ។

### ១.២. ការស្តីដណ្តឹង

នៅពេលចូលស្តីដណ្តឹង មាតាបិតាខាងប្រុសរកអ្នកមុខ អ្នកការ មានហោរបីនាក់ ឲ្យធ្វើជាអ្នកផ្លូវចូលទៅស្តីដណ្តឹងកូនស្រី ដោយមានរបស់កំដរដៃដូចជាការចូលចែចូវដែរ ដែលមានម្លូស្លា បារី ស្លាបផ្កា កំបោរ កាន់មកជាប់ដៃជាមួយផង ។ ចំពោះការស្តីដណ្តឹងក៏មាន ៣ ដំណាក់កាលដូចគ្នាទៅនឹងការចែចូវដែរ ប៉ុន្តែសម្រាប់ពេលបច្ចុប្បន្ននេះ គឺគេធ្វើតែមួយដំណាក់កាលជាការស្រេច ។ ចំពោះដំណាក់កាលនៅសម័យបុរាណនៃការស្តីដណ្តឹងរួមមាន៖

- លើកទីមួយ អ្នកផ្លូវត្រូវជំរាបទៅមេបាជាពាក្យយ៉ាងនេះថា "សូមទាន សូមជម្រាបអស់លោកមេបាតូចធំ ត្រកូលរៀមច្បង សូមទានជ្រាប ត្បិតពឹងពររកយើងខ្ញុំទាំងបីនាក់

ឲ្យធ្វើជាអ្នកផ្លូវ នាំភស្តុតាង បណ្ណាការមកជូនលោកមេបា សុំស្គាល់ សុំស្រលាញ់ ជាសម្ព័ន្ធមិត្តនឹងលោកមេបា ឈ្មោះនាង..........ថានៅទំនេរឥតមាន ទាក់ទងសម្តី នឹងអ្នកណាទេ ឬ ដូចម្តេច? ពេលនោះលោកមេបាខាងស្រីនឹងឆ្លើយតបមកវិញថា ឲ្យ ឬ មិនឲ្យ" [2]។

- លើកទីពីរ អ្នកផ្លូវចូលទៅដូចមុនហើយនិយាយថា "........ត្បិតជើងមុន យើងខ្ញុំសុំឲ្យលោកមេបាដោះពាក្យដែលជំពាក់នោះ ឥឡូវនេះលោកបានដោះរួចហើយរួចហើយ ឬនៅ?[3]" មេបាឆ្លើយតបទៅនឹងអ្វីដែលគេបានសន្យាពីមុនមកនោះ ។
- លើកទីបី "អ្នកផ្លូវសុំស្ដីដណ្ដឹងម្តងទៀត តែមេបាតូច (មេបាស្រី) ឆ្លើយថាស្រេចលើមេបាធំ (មេបាប្រុស)"[4]។

ប៉ុន្តែបច្ចុប្បន្ននេះពិធីមួយចំនួនក៏ត្រូវបានកាត់ចោលផងដែរ ដោយសារតែចំណាយពេលវេលាយូរ ចំណែកឯការចំណាយថវិការក៏ច្រើនផងដែរ ។ ចំពោះពិធីចូលចៃចូវ និង ស្តីដណ្តឹងក៏ត្រូវបានកាត់ចេញនៅពិធីមួយចំនួនផងដែរ ដែលបច្ចុប្បន្ននេះការចូលចៃចូវគឺមានមួយលើកប៉ុណ្ណោះ ហើយយកជាការតែម្តង ។ ចំពោះការស្តីដណ្តឹងវិញក៏ដូចគ្នាដែរ ឲ្យតែកូនប្រុសស្រីបានព្រមព្រៀងគ្នាហើយ មានការព្រមព្រៀងពីឪពុកម្តាយទាំងសងខាងនោះគឺអាចប្រារព្ធពិធីបានដូចគ្នា ដែលភាគច្រើនគេធ្វើតែមួយលើកជាការស្រេច ។ ម្យ៉ាងវិញទៀត វាចំណេញពេល និង ថវិការសម្រាប់គ្រួសារទាំងពីរផងដែរ ។

### ១.៣. សេចក្តីសន្យា

សេចក្តីសន្យា គឺសំដៅលើភាគីទាំងពីរដែលជាបុរស នារី បានបង្ហាញឆន្ទៈនៃការព្រមព្រៀងថានឹងយកគ្នាជាប្តីប្រពន្ធ ស្របតាមផ្លូវច្បាប់ ។ មួយវិញទៀត សេចក្តីសន្យានេះនឹងឈានទៅ

[2] រៀបរៀងដោយលោក ជឹម ហួរ និង ផ្សេងៗទៀត, អរិយធម៌ខ្មែរ(ភ្នំពេញ ២០១៤), ១៩៧

[3] រៀបរៀងដោយលោក ជឹម ហួរ និង ផ្សេងៗទៀត, អរិយធម៌ខ្មែរ(ភ្នំពេញ ២០១៤), ២០០

[4] រៀបរៀងដោយលោក ជឹម ហួរ និង ផ្សេងៗទៀត, អរិយធម៌ខ្មែរ(ភ្នំពេញ ២០១៤), ២០១

រកការរៀបអាពាហ៍ពិពាហ៍នៅពេលអនាគតផងដែរ ។ បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ៩៥៤ ក៏បានចែងផងដែរថា "កំជាប់ពាក្យ ត្រូវបង្កើតឡើង តាមសេចក្តីសន្យារវាងបុរស នារីថានឹងបង្កើតចំណងអាពាហ៍ពិពាហ៍រវាងគ្នា នាពេលអនាគត និង ដោយធ្វើពិធីកំជាប់ពាក្យ" ។

ដូចនេះ សេចក្តីសន្យា គឺជាការព្រមព្រៀងរវាងបុរស និង នារីថានឹងរៀបអាពាហ៍ពិពាហ៍រវាងគ្នា នៅពេលអនាគតដោយឆ្លងកាត់នូវពិធីកំជាប់ពាក្យ ។

### ១.៤.ពិធីកំជាប់ពាក្យ

កំជាប់ពាក្យ ឬ ការលើកស្លា ឬ ការនិយាយភាសាដែលប្រជាជនខ្មែរធ្លាប់ប្រើប្រចាំថ្ងៃហៅថា "ការភ្ជាប់ពាក្យ"។ ពិធីកំជាប់ពាក្យ ជាប្រពៃណីខ្មែរដែលមានតាំងពីបុរាណមក ហើយក៏ជាពិធីដ៏ធំមួយមុននឹងឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍។ នៅពេលសព្វថ្ងៃ ពិធីនេះនៅមានការនិយមធ្វើជាទូទៅ មុននឹងបុត្រធីតារបស់គេឈានទៅដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍ ហើយនៅក្នុងគ្រួសារដែលមានជីវភាពធូរធារ បានរៀបចំពិធីនេះយ៉ាងអធិកអធមធំប៉ុនគ្នានឹងពិធីរៀបអាពាហ៍ពិពាហ៍ដែរ ប៉ុន្តែសម្រាប់គ្រួសារ ដែលមានជីវភាពមធ្យម បានរៀបចំតូចល្មមទៅតាមធនធាន ហើយសម្រាប់អ្នកខ្លះដែលមានជីវភាពមិនធូរធារ បានលើកពិធីនេះចោលក៏មានដែរ។ ពិធីនេះ គេច្រើនធ្វើមួយព្រឹក ឬ មួយថ្ងៃពេញតែម្តង ហើយមានការបំពាក់ចិញ្ចៀន ឬ ខ្សែក ឬ ក៏ការប្រគល់វត្ថុអនុស្សាវរីយ៍ផ្សេងៗដល់អនាគតស្វាមី ឬ ភរិយាទៀតផងតាមការនិយម និង តាមសមត្ថភាពធនធានដែលភាគីមាន[5]។

## ២.លក្ខខណ្ឌផ្លូវច្បាប់នៃកំជាប់ពាក្យ

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គន្ថីទី៧ ជំពូកទី២ បានទទួលស្គាល់ពិធីនេះជាផ្លូវការ និងជាវិធានដែលកំណត់អោយភាគីត្រូវធ្វើការសម្រេចចិត្តដោយសេរីចេញពីឆន្ទៈ នៅមុនពេលរៀបអាពាហ៍ពិពាហ៍។ ដោយហេតុថា ក្នុងករណីខ្លះ កំជាប់ពាក្យនេះត្រូវបានធ្វើឡើងដោយមិនគោរពឆន្ទៈរបស់ភាគីទេ ប៉ុន្តែបែរជាសម្រេចទៅតាមឆន្ទៈរបស់ឪពុកម្តាយទៅវិញ។

[5] នីតិគ្រួសារ និង អាពាហ៍ពិពាហ៍,ឥន យឿន,២០១៣,ទំព័រ ២០-២១

កំជាប់ពាក្យនេះជាវិធីមួយដែលភាគីជាបុរស និង ស្ត្រី ដែលឈានដល់វ័យគ្រប់ការហើយបានសន្យានឹងគ្នាថានឹងរៀបអាពាហ៍ពិពាហ៍ ជាមួយគ្នានៅពេលអនាគត ហើយដែលមានចាស់ទុំភាគីទាំងសងខាង អ្នកផ្លូវថៅមហា ព្រមទាំងភ្ញៀវជួយធ្វើជាសាក្សី និង ដឹងឮផងដែរ។ ដូច្នេះ ក្រមរដ្ឋប្បវេណីកំណត់ថា កំជាប់ពាក្យត្រូវធ្វើឡើងដោយសេរីរបស់ភាគី។

កំជាប់ពាក្យនេះ ទុកជាបានការលុះត្រាតែភាគីបានធ្វើពិធីនេះជាឱឡារិក ដែលហៅថាពិធីលើកស្លា។

## ៣.ការមិនកំណត់លក្ខខណ្ឌអាយុក្នុងប្រុសស្រីក្នុងកំជាប់ពាក្យ

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មិនបានកំនត់លក្ខខណ្ឌអាយុសម្រាប់ពិធីកំជាប់ពាក្យ ឬ ពិធីលើកស្លា ឬ ពិធីភ្ជាប់ពាក្យនេះដូចការកំណត់លក្ខខណ្ឌអាយុក្នុងការរៀបអាពាហ៍ពិពាហ៍ទេ។ ដោយហេតុថា ពិធីកំជាប់ពាក្យ ឬ ពិធីលើកស្លា មិនទាន់ដល់ពេលដែលភាគីអាចរួមរស់ជាមួយគ្នាជាប្តីប្រពន្ធបានឡើយ ហើយពិធីនេះភាគីអាចទុករយៈពេលខ្លី ឬ រយៈពេលវែងដើម្បីរៀបអាពាហ៍ពិពាហ៍។ ករណីជាក់ស្តែងខ្លះ ភាគីដែលបានធ្វើពិធីកំជាប់ពាក្យ ឬ ពិធីលើកស្លា ឬ ពិធីភ្ជាប់ពាក្យហើយ គេអាចទុករយៈពេលច្រើនឆ្នាំទៀត ដើម្បីរៀបអាពាហ៍ពិពាហ៍ក៏បាន អាស្រ័យដោយការចាំបាច់របស់គូភាគី ដូចជាជាប់រវល់បន្តការសិក្សា ឬមិនទាន់ដល់វ័យរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពួកគេបានស្រលាញ់គ្នា និង បានសន្យាជាមួយគ្នាថា នឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅពេលអនាគតដើម្បីចៀសវាងអ្នកដទៃទៅទាក់ទង ឬ ភាគីម្ខាងទៀតមិនជឿចិត្ត ឬ ផ្លាស់ប្តូរចិត្ត។

ក្នុងករណីដែលភាគីជាអនីតិជន (អាយុក្រោម១៨ឆ្នាំ) បានធ្វើកំជាប់ពាក្យ ឬក៏ពិធីភ្ជាប់ពាក្យក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មិនបានកំណត់ថា ត្រូវមានការយល់ព្រមពីឪពុកម្តាយ ឬ អាណាព្យាបាលទេ។ ទោះបីជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានចែងក៏ដោយដែលទុកថា ភាគីដែលជានីតិជន (អាយុចាប់ពី១៨ ឆ្នាំទៅ) ឬ អនីតិជនមិនចាំបាច់មានការយល់ព្រម ឬ អាចមានការយល់ព្រមក៏បានតែនៅក្នុងការប្រារព្ធពិធីជាក់ស្តែងនៃការលើកស្លានេះ ថៅមហាដែលតំណាងអោយ

មេបាខាងប្រុសតែងតែសួរមកមេបា ឬ ចៅមហាខាងស្រីថា តើលោកមេបាខាងស្រីយល់ព្រមដែរ អត់? ប្រសិនបើថាយល់ព្រមហើយ ទើបពិធីនេះបានប្រព្រឹត្តទៅដល់ចប់។

## ផ្នែកទី២ ការរលាយនៃកំជាប់ពាក្យ

ជាទំលាប់នៅពេលមានពិធីកំជាប់ពាក្យ គឺតែងតែមានការជូនជាជំនូន អាចជាភាគីខាងប្រុសជាអ្នកជូន ឬ អាចជាភាគីខាងស្រីជាអ្នកជូនដែរ។ ជំនូននៅទីនេះអាចជាប្រាក់កាស ឬ ជាទ្រព្យផ្សេងៗ។ កំជាប់ពាក្យត្រូវបានបង្កើតឡើង ប៉ុន្តែដោយសារហេតុផលអ្វីមួយធ្វើឱ្យកំជាប់ពាក្យរលាយទៅវិញ។

នៅក្នុងពិធីកំជាប់ពាក្យ នៅពេលណាដែលមានបញ្ហាណាមួយកើតឡើងដែលនាំឲ្យឈានទៅដល់ការលុបចោលនៅពិធីកំជាប់ពាក្យ នោះភាគីដែលធ្វើខុសត្រូវទទួលខុសត្រូវចំពោះភាគីម្ខាងទៀត ។ មូលហេតុដែលនាំឲ្យមានការរលាយពិធីកំជាប់ពាក្យមានដូចជា៖

- រលាយដោយអាពាហ៍ពិពាហ៍
- រលាយដោយមរណភាពរបស់ភាគីណាមួយ
- រលាយដោយការព្រមព្រៀងរបស់ភាគី
- រលាយដោយការបដិសេធចោលដោយមានមូលហេតុត្រឹមត្រូវ
- រលាយដោយការបដិសេធដោយគ្មានមូលហេតុត្រឹមត្រូវ ។

### កថាខណ្ឌទី១ ការទទួលខុសត្រូវចំពោះការបដិសេធដោយគ្មានមូលហេតុត្រឹមត្រូវ

កំជាប់ពាក្យ គឺជាដំណើការសង្គម ដែលជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍តាមច្បាប់ ហើយមានអត្ថន័យតាមផ្លូវច្បាប់លើសពីពិធីដែលគ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញ។ ក្នុងករណីដែលភាគីម្ខាងបដិសេធកំជាប់ពាក្យចោលដោយមិនត្រឹមត្រូវ ភាគីនោះត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាត មានន័យថា ភាគីម្ខាងទៀតអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងពីការបដិសេធនោះបាន ។ មូលហេតុមិនត្រឹមត្រូវរួមមាន ភាពមិនស្មោះត្រង់របស់ភាគីម្ខាងទៀត អំពើហិង្សាតាមរយៈពាក្យសម្តី ឬ លើរូបរាងកាយ ឬ អសមត្ថភាពផ្លូវកាយ ឬ ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។

ការខូចខាតក្នុងចំណុចនេះរួមមាន ការខូចខាតផ្នែកផ្លូវចិត្ត ក៏ដូចជាការខូចខាតផ្នែកទ្រព្យសម្បត្តិ រួមមានការចំណាយប្រាក់សម្រាប់កក់ភោជនីយដ្ឋានសម្រាប់រៀបចំកម្មវិធីរៀបអាពាហ៍ពិពាហ៍ ឬ ការចំណាយផ្សេងៗទៀតដែលធ្វើឡើងនៅពេលរៀបអាពាហ៍ពិពាហ៍ ។

### កថាខណ្ឌទី២ ការសងជំនូន

ផ្ទុយទៅវិញចំពោះកំជាប់ពាក្យ ទោះបីជាភាគីណាម្ខាងបដិសេធចោលការរៀបអាពាហ៍ពិពាហ៍ដោយគ្មានមូលហេតុត្រឹមត្រូវ ក៏ដោយក៏ភាគីម្ខាងទៀតមិនអាចទាមទារឱ្យភាគីម្ខាងនោះអនុវត្តចំពោះការសន្យាបានដែរ ព្រោះការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងដោយការស្ម័គ្រចិត្តរបស់ភាគី ហេតុនេះដំណោះស្រាយតាមផ្លូវច្បាប់ចំពោះអ្នកខូចខាត គឺមានសិទ្ធិទាមទារជំនូន និង សំណងនៃការខូចខាតទៅតាមនីតិវិធីដែលមានកំណត់ក្នុងច្បាប់ចំពោះអ្នកខូចខាត គឺមានសិទ្ធិទាមទារជំនូន និង សំណងនៃការខូចខាតទៅតាមនីតិវិធីដែលមានកំណត់ក្នុងច្បាប់ជាធរមាន។ នៅក្នុងករណីភាគីម្ខាងបដិសេធកំជាប់ពាក្យដោយគ្មានមូលហេតុត្រឹមត្រូវ ឬ កំជាប់ពាក្យបានរលាយ ភាគីដែលខូចប្រយោជន៍អាចធ្វើសកម្មភាពប្តឹងទៅភាគីម្ខាងទៀតដើម្បីទាមទារជំនូន និង សំណងនៃការខូចខាតមកវិញ។ ដោយការគណនាសំណងនៃការខូចខាត យើងអាចវិនិច្ឆ័យអំពីទំហំនៃសំណងសម្រាប់អ្នកដែលខាតបង់ប្រយោជន៍ ហើយអ្នកដែលមានសិទ្ធិទាមទារជំនូន និង សំណងនៃការខូចខាតនេះ ត្រូវធ្វើសកម្មភាពប្តឹងក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះត្រូវបានរលាយ។

### កថាខណ្ឌទី៣ ភាគីអាចទាមទារអោយសងជំនូន

តាមទំនៀមទំលាប់ ព្រះរាជាណាចក្រកម្ពុជាមានករណីជាច្រើនដែលការជូនដល់ភាគីម្ខាងទៀតនូវប្រាក់កាស និង ទ្រព្យ (ជំនូន) ត្រូវបានធ្វើឡើងនៅពេលដែលមានគម្រោងរៀប

អាពាហ៍ពិពាហ៍ ជាពិសេសភាគីម្ខាង អាចទាមទារឲ្យភាគីម្ខាងទៀតសងជំនួនមកវិញ[6]បានក្នុងករណីដែលកំជាប់ពាក្យត្រូវបានរលាយ។

ផ្ទុយទៅវិញ នៅពេលដែលភាគីដែលបានភ្ជាប់ពាក្យ ហើយបានរៀបអាពាហ៍ពិពាហ៍រួចហើយនោះភាគីមិនអាចទាមទារឲ្យសងជំនួននោះពីភាគីម្ខាងទៀតបានទេ ទោះបីជាពួកគេបានលែងលះក៏ដោយ។ការសងជំនួន គឺត្រូវធ្វើឡើងនៅកំឡុងពេលដែលមានកំជាប់ពាក្យ ដែលមានដូចជាប្រាក់សម្រាប់ការជួលទីកន្លែង សម្រាប់រៀបចំពិធី ឬ ថ្លៃរបស់របរផ្សេងៗទៀតដែលបានរៀបចំពិធីនោះ។ការសងសំណងនេះអាចកើតមានឡើងលុះត្រាតែកម្មវិធីនោះបានប្រារព្ធឡើង ទើបភាគីដែលខូចខាតមានសិទ្ធិក្នុងការទាមទារសំណងនេះ មានន័យថា ប្រសិនបើពិធីកំជាប់ពាក្យបានបញ្ចប់មុនពេលកម្មវិធី (រៀបចំពិធី ជួលទីកន្លែង ឬ របស់របរផ្សេងៗនៅក្នុងពិធី) ហើយមិនបានធ្វើឲ្យប៉ះពាល់ដល់ភាគីម្ខាងទៀត នោះមិនត្រូវទទួលខុសត្រូវចំពោះសំណងនោះទេ ។

ការទទួលខុសត្រូវក្នុងការសងជំនួននេះ កើតឡើងដោយមិនគិតពីមូលហេតុនៃការរលាយកំជាប់ពាក្យទេ លើកលែងតែការរលាយដោយអាពាហ៍ពិពាហ៍ ។ ដូចនេះ ទោះបីជាកំជាប់ពាក្យត្រូវបានរលាយដោយមរណភាពរបស់ភាគីណាមួយក្តី ដោយការព្រមព្រៀងរបស់គូភាគីក្តី ឬ ដោយការបដិសេធចោលដោយមូលហេតុត្រឹមត្រូវក្តី ក៏ភាគីត្រូវសងជំនួននោះវិញដែរ ។ ភាគី ដែលបានលើកជំនួននៅពេលកំជាប់ពាក្យ ដោយការសង្ឃឹមថាខ្លួននឹងបានរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែកំជាប់ពាក្យត្រូវបានរលាយទៅវិញ ភាគីដែលបានលើកជំនួននោះអាចទាមទារអោយភាគីប្រព្រឹត្តកំហុសសងជំនួនមកវិញបាន។ ទោះបីជាភាគីដែលលើកជំនួនមានកំហុស ឬ គ្មានកំហុសក្នុងការរលាយកំជាប់ពាក្យក៏ដោយក៏ភាគីនោះអាចទាមទារអោយភាគីដែលប្រព្រឹត្តកំហុសសងជំនួនមកវិញបានដែរ[7]។

---

[6] មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[7] មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## កថាខណ្ឌទី២ ភាគីអាចទាមទារអោយសងសំណងនៃការខូចខាត

កំជាប់ពាក្យ មានអត្ថន័យតាមផ្លូវច្បាប់លើសពីអ្វី ដែលគ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញ។ ហេតុដូចនេះ បើចេះតែអោយភាគីណាមួយ អាចរំលាយកំជាប់ពាក្យបានដោយសេរី ដោយភាគីដែលសុំរំលាយ មានកំហុសនោះវាអាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និង ទំនៀមទំលាប់ល្អរបស់សង្គម។ ដូចនេះ ទើបក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានដាក់កំរិតចំពោះភាគី ដែលមានកំហុសក្នុងការរំលាយកំជាប់ពាក្យ ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាត។ វាមានន័យថាបើភាគីម្ខាងបដិសេធ កំជាប់ពាក្យដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀតនៃកំជាប់ពាក្យ អាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការបដិសេធចោលនោះបាន[8]។

## កថាខណ្ឌទី៣ អំឡុងពេលនៃការទាមទារសំណងខូចខាត

នៅពេលដែលកំជាប់ពាក្យត្រូវបានរលាយ ឬ បដិសេធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីម្ខាងទៀត មានសិទ្ធិធ្វើការប្តឹងទាមទារទៅតុលាការទាមទារសំណង ដូចជាការសងជំនួន ការទទួលខុសត្រូវផ្សេងៗទៀត ដោយភាគីនោះ ត្រូវប្តឹងទៅតុលាការនៅក្នុងកំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះបានរលាយ[9] ។ ប្រសិនបើហួសនៅកំឡុងពេលមួយឆ្នាំនោះ ការប្តឹងទាមទារសំណងនោះនឹងមិនអាចធ្វើបាននោះទេ គឺអាស្រ័យទៅលើភាគីដែលបានព្រមព្រៀងគ្នាវិញ ។ ពិធីកំជាប់ពាក្យ ត្រូវបានច្បាប់ទទួលស្គាល់ពិតមែន ប៉ុន្តែភាគីដែលមិនចុះសម្រុងគ្នា ឬ មិនត្រូវគ្នា ឬ ដោយមូលហេតុផ្សេងទៀត គេនៅតែអាចបដិសេធពិធីកំជាប់ពាក្យ ឬ ពិធីភ្ជាប់ពាក្យនេះចោល ហើយឈានទៅលុបគម្រោងអាពាហ៍ពិពាហ៍ដែលគ្រោងធ្វើនៅពេលខាងមុខបាន។កំជាប់ពាក្យត្រូវបានរលាយ ដោយមានការព្រមព្រៀងពីភាគីទាំងសងខាង ឬ ដោយមរណភាព របស់ភាគី។ ទោះជាមូលហេតុណាក៏ដោយភាគីម្ខាងទៀតដែលត្រូវគេផ្តាច់កំជាប់ពាក្យអាចទាមទារ

[8] មាត្រា ៩៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[9] មាត្រា ៩៥៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ថ្លៃជំនូន និង ភស្តុភារ បណ្ណាការដែលបានជូនទៅភាគីម្ខាងទៀតវិញបាន។ ប៉ុន្តែនៅក្នុងករណីដែលភាគីណាមួយ បានបដិសេធកំជាប់ពាក្យដែលបានភ្ជាប់រវាងភាគីទាំងពីរចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ភាគីនោះត្រូវទទួលខុសត្រូវចំពោះសំណងខូចខាតទៅភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតអាចទាមទារសំណងខូចខាតដែលបានកើតឡើងពីការបដិសេធនោះបាន។ សំណងខូចខាតនេះអាចរួមមានសំណងជម្ងឺចិត្តអោយសមរម្យតាមថ្លៃជំនូន និង ភស្តុភារ បណ្ណាការដែលទិញជូនដើម្បីរៀបចំពិធីនោះជាដើម។ ភាគីដែលត្រូវបានគេផ្តាច់កំជាប់ពាក្យ ដោយគ្មានមូលហេតុត្រឹមត្រូវ ឬដោយខ្លួនគ្មានកំហុស អាចប្តឹងទៅតុលាការដើម្បីទាមទារជំនូន និង សំណងការខូចខាតមកវិញក្នុងរយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃដែលកំជាប់ពាក្យនោះត្រូវបានរលាយ ហើយក្នុងករណីផុតរយៈពេលកំណត់នេះបើភាគីខកខានមិនបានដាក់ពាក្យប្តឹងទេនោះភាគីដែលមានសិទ្ធិប្តឹងនោះ ត្រូវរលត់សិទ្ធិប្តឹងទាមទារ ជំនូន ឬ សំណងជម្ងឺចិត្តមកវិញ[10]។ ប្រសិនបើភាគីដែលត្រូវបានគេផ្តាច់កំជាប់ពាក្យនោះ បានធ្វើអោយមានកំហុស ដែលអាចយកធ្វើជាមូលហេតុនៃការផ្តាច់កំជាប់ពាក្យនេះ ភាគីដែលធ្វើអោយមានកំហុសនេះ អាចប្តឹងទាមទារត្រឹមសំណងជំនូនមកវិញ ប៉ុន្តែមិនអាចទាមទារសំណងនៃការខូចខាតផ្សេងៗបានទេ។

[10] មាត្រា ៩៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី២
# អាពាហ៍ពិពាហ៍

## ផ្នែកទី១ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍អាចកើតមានឡើងបានគឺដោយសារតែបុរស និង ស្ត្រីមានសេចក្ដីស្រលាញ់ចំពោះគ្នាទៅវិញទៅមក ហើយមានឆន្ទៈចង់បង្កើតគ្រួសារមួយជាមួយគ្នា និងបានព្រមព្រៀងគ្នាថានឹងរៀបការ ហើយបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយគ្នា។វាគឺជាច្បាប់ធម្មជាតិដែលតំរូវអោយបុរស និង ស្ត្រី មានមនោសញ្ចេតនា និងការស្រលាញ់ ដើម្បីមើលថែរក្សាគ្នា ជួយទុក្ខធុរៈគ្នាទៅវិញទៅមក ព្រមទាំងបង្កើតកូនចៅជំនាន់ក្រោយជាមួយគ្នា។ ដើម្បីអោយរស់នៅជាមួយគ្នាបានបុរស និង ស្ត្រី ត្រូវចេះជួយបំពេញបន្ថែម និង ពឹងពាក់គ្នាហើយត្រូវចេះយោគយល់ អធ្យាស្រ័យអត់អោនអោយគ្នាទៅវិញទៅមក មានន័យថាបុរសត្រូវការស្ត្រី ហើយស្ត្រីក៏ត្រូវការបុរសដែរ។

អាពាហ៍ពិពាហ៍ គឺចំណងផ្លូវច្បាប់ដែលបញ្ជាក់ពីការពឹងពាក់គ្នាទៅវិញទៅមកនៃបុរស និង ស្ត្រី។ អាពាហ៍ពិពាហ៍ គឺជាការរួមចូលគ្នា ខាងសេដ្ឋកិច្ច សង្គម និង មនោសញ្ចេតនាស្នេហាដ៏ជ្រាលជ្រៅបំផុតដែលនៅក្នុងឧត្តមគតិ អនុញ្ញាតអោយបុរស និង ស្ត្រីបានចម្រើនលូតលាស់ជាមួយគ្នា។ អាពាហ៍ពិពាហ៍ គឺជាការរួមគ្នាដើម្បីចិញ្ចឹមបុត្រធីតាអោយក្លាយជាពលរដ្ឋល្អ។

ដោយហេតុថាបុរស និងស្ត្រីពឹងពាក់គ្នាទៅវិញទៅមក និង ដោយហេតុថា កូនពឹងពាក់លើឪពុកម្ដាយ ជាការសំខាន់ដែលច្បាប់ត្រូវតែបញ្ជាក់អោយបានច្បាស់នូវសិទ្ធិ និង កាតព្វកិច្ចរៀងៗខ្លួនរបស់សមាជិកគ្រួសារ។ ដូច្នេះ ទោះបីជានៅក្នុងទិដ្ឋភាពខ្លះ អាពាហ៍ពិពាហ៍ គឺជារឿងដែលមានការយកចិត្តទុកដាក់ជាសាធារណៈដែលរដ្ឋាភិបាលត្រូវដាក់កម្រិតជាបញ្ញត្តិតាមរយៈច្បាប់។ ក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ ត្រូវបានប្រកាសអោយប្រើប្រាស់ជាផ្លូវការដោយច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណីកាលពីខែធ្នូ ឆ្នាំ២០១១ បានចូលមកជំនួសច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារចាស់ ដែលត្រូវបានដាក់អោយនិរាករណ៍ដោយច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី។

អាពាហ៍ពិពាហ៍ ជាកិច្ចសន្យាមួយ និង ជាកិច្ចព្រមព្រៀងដែលធ្វើឡើងដោយសេរីរវាងមនុស្សពីរនាក់ ដែលមានអានុភាពដល់សិទ្ធិ និង កាតព្វកិច្ចរបស់គេ ហើយដែលរដ្ឋនឹងទទួលស្គាល់និងបង្គាប់អោយអនុវត្តតាមរយៈប្រព័ន្ធច្បាប់។ ទោះបីជាអាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាមួយបែបដែលមិនដូចកិច្ចសន្យាដទៃទៀតក៏ដោយ ក៏ភាគីមិនអាចរំលាយអាពាហ៍ពិពាហ៍តាមទំនើងចិត្តបានទេ។ ផ្ទុយទៅវិញ ភាគីអាចត្រឹមតែបញ្ចប់អាពាហ៍ពិពាហ៍របស់គេបាន ដោយស្របទៅតាមវិធាន និង នីតិវិធីជាក់លាក់ដែលមានចែងនៅក្នុងច្បាប់ប៉ុណ្ណោះ។ ដូច្នេះ បន្ថែមលើភាពជាកិច្ចសន្យា មួយ

អាពាហ៍ពិពាហ៍ជាទំនាក់ទំនងយូរអង្វែងតទៅ ដែលស្ថិតនៅរហូតទាល់តែត្រូវបានបញ្ចប់ដោយច្បាប់ ឬ ដោយមរណភាពរបស់សហព័ទ្ធណាមួយ។

ដោយហេតុថា អាពាហ៍ពិពាហ៍ជាការប្ដេជ្ញាដ៏មុឹងម៉ាត់ ដែលនឹងកំណត់នូវសិទ្ធិ និង កាតព្វកិច្ចអនាគតរបស់ប្ដី និង ប្រពន្ធ ជាការសំខាន់ដែលភាគីទាំង២ ត្រូវមានសមត្ថភាពនៅពេលចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ដើម្បីយល់ និង ផ្ដល់ការយល់ព្រមចំពោះការប្ដេជ្ញាដែលគេបានធ្វើ។ ដូច្នេះ រដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការដាក់លក្ខខណ្ឌកម្រិតសម្រាប់ការរៀបអាពាហ៍ពិពាហ៍។

## កថាខណ្ឌទី១ និយមន័យនៃអាពាហ៍ពិពាហ៍

**អាពាហ៍ពិពាហ៍** អាចសរសេរម្យ៉ាងទៀតថា **អាវាហៈវិវាហៈ**
**អាវាហៈ** មានន័យថា ការនាំកូនស្រីមកខាងលំនៅកូនប្រុស
**វិវាហៈ** មានន័យថា ការនាំកូនប្រុសត្រឡប់ទៅខាងលំនៅកូនស្រីវិញ
**អាវាហៈវិវាហៈ** មានន័យថា មង្គលការគូរបុរសស្ត្រីបាននាំមកហើយនាំត្រឡប់ទៅវិញ[11]។

**ចំណងអាពាហ៍ពិពាហ៍** គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និង ស្ត្រីម្នាក់ដែលប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនបានឡើយ[12]។

## កថាខណ្ឌទី២ និយមន័យនៃគ្រួសារ

**គ្រួសារ** មានន័យទូលាយជាងពាក្យ "អាពាហ៍ពិពាហ៍" ព្រោះគ្រួសារមានមនុស្សច្រើន ហើយគ្រួសារកើតឡើងអាស្រ័យដោយមូលដ្ឋាននៃចំណងអាពាហ៍ពិពាហ៍ ញាតិលោហិត និងការចិញ្ចឹមបីបាច់ថែរក្សាគ្នាហើយសិទ្ធិ និង កាតព្វកិច្ចរបស់គ្រួសារត្រូវបានច្បាប់កំណត់។

**គ្រួសារ** គឺជាកោសិការបស់សង្គម អនុវត្តភារៈសំខាន់របស់សង្គម គឺភារៈពីការបង្កើតការអប់រំ និង ភារៈពីការកសាងសេដ្ឋកិច្ច។

[11] វចនានុក្រមខ្មែរ របស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥
[12] មាត្រា ៣ នៃច្បាប់ស្ដីពីឯកពន្ធភាព

**គ្រួសារ** គឺជាបណ្តុំមនុស្សដែលកើតឡើងដោយមូលដ្ឋាននៃចំណងអាពាហ៍ពិពាហ៍ ញាតិលោហិត និង ការចិញ្ចឹមបីបាច់ថែរក្សាគ្នា ហើយសិទ្ធិ និង កាតព្វកិច្ចរបស់គ្រួសារត្រូវបានច្បាប់កំណត់។

## ផ្នែកទី២ ការបង្កើតអាពាហ៍ពិពាហ៍

ដើម្បីអោយអាពាហ៍ពិពាហ៍ អាចប្រព្រឹត្តទៅបាន ភាគីទាំងពីរ ត្រូវតែអនុវត្ត និង គោរពតាមលក្ខខណ្ឌដែលក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ និងវិធានដទៃទៀតរបស់ព្រះរាជាណាចក្រកម្ពុជា តម្រូវអោយមានមុននឹងអនុញ្ញាតអោយបុគ្គលទាំងពីរ រៀបអាពាហ៍ពិពាហ៍បាន។ ម៉្យាងទៀតដើម្បីអោយអាពាហ៍ពិពាហ៍មានសុពលភាព កិច្ចអាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រីនោះត្រូវតែគោរពតាមលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ផងដែរ។

តើអ្វីទៅជាលក្ខខណ្ឌគ្រឹះ និង អ្វីទៅជាលក្ខខណ្ឌទម្រង់? ហើយតើលក្ខខណ្ឌទាំងពីរនេះមាននីតិវិធីយ៉ាងណាខ្លះចំពោះការបង្កើតអាពាហ៍ពិពាហ៍?

ចំពោះអត្ថន័យ និង ខ្លឹមសារ ក៏ដូចជានីតិវិធីដែលទាក់ទងទៅនឹងលក្ខខណ្ឌទាំងពីរនេះ និងត្រូវបានបកស្រាយ និង ធ្វើការរៀបរាប់យ៉ាងលម្អិតនៅខាងក្រោមនេះដូចតទៅ៖

### កថាខណ្ឌទី១ លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍

លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍ គឺជាលក្ខខណ្ឌដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ហើយបានថែងទាក់ទងទៅនឹងលក្ខណៈធម្មជាតិ រួមទាំងលក្ខណៈពាក់ព័ន្ធនឹងសីលធម៌របស់គូភាគីទាំង២។ ហើយលក្ខខណ្ឌទាំងអស់នោះមានដូចជា៖

#### ១. ភេទរបស់ភាគី

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់អំពីភេទរបស់ភាគីដែលត្រូវរៀបអាពាហ៍ពិពាហ៍ ត្រូវតែមានភេទផ្ទុយគ្នា គឺត្រូវតែជាបុរស និង ស្ត្រី។ មាត្រា ៩៤៨ ចែងថា "បុរស និង នារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ"។

រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា និង ច្បាប់ស្តីពីឯកពន្ធភាព ក៏បានកំណត់អំពីភេទរបស់ភាគីដែលអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវតែជា បុរស និង ស្ត្រី[13]។

[13] មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ២ នៃច្បាប់ស្តីពីឯកពន្ធភាព

ក្រមរដ្ឋប្បវេណី មិនទទួលស្គាល់អ្នកដែលរៀបអាពាហ៍ពិពាហ៍ត្រូវមានភេទដូចគ្នា ឬ ហៅថា "ភេទទី៣" នោះទេ។ ប៉ុន្តែបណ្ដាប្រទេសជាច្រើនទៀតនៅលើពិភពលោក បានចាប់ផ្ដើមទទួលស្គាល់ និង ផ្ដល់សិទ្ធិដល់អ្នកមានភេទដូចគ្នា អាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឬ រស់នៅជាមួយគ្នាស្របច្បាប់បាន។

នៅក្នុងករណីជាក់ស្ដែងខ្លះ នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ហើយរហូតដល់មានការចុះផ្សាយនៅតាមបណ្ដាញសារពត៌មានទៀតផងដែរ។មានមនុស្សដែលភេទដូចគ្នាបានរួមរស់ជាមួយគ្នាដោយខ្លះបានរៀបអាពាហ៍ពិពាហ៍ជាផ្លូវការ និង អ្នកខ្លះមិនមានការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ទោះបីជាអាជ្ញាធរមិនទទួលស្គាល់ ឬ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍អោយក៏ដោយ។ ពួកគេទាំងអស់នោះស្រលាញ់គ្នា ឬ រស់នៅជាមួយគ្នាតាមរបៀបអនីតិសង្វាស។

ដូចនេះ ការរៀបអាពាហ៍ពិពាហ៍ គឺចាំបាច់ត្រូវធ្វើឡើងជាមួយបុរសម្នាក់ និង នារីម្នាក់ដែលមានភេទផ្ទុយគ្នា ទើបស្របទៅតាមផ្លូវច្បាប់។ ក្នុងករណីដែលមានការរៀបអាពាហ៍ពិពាហ៍ជាមួយភេទដូចគ្នានោះ គេចាត់ទុកថាជាអំពើខុសច្បាប់ ហើយវាអាចធ្វើអោយប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ខ្មែរផងដែរ។

## ២. គោលការណ៍ស្ម័គ្រចិត្ត

បុរស និង ស្ត្រីដែលបានសម្រេចចិត្តថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំពីឪពុកម្ដាយ ឬ អាណាព្យាបាល។ ភាគីមួយមិនអាចបង្ខំភាគីម្ខាងទៀតអោយរៀបអាពាហ៍ពិពាហ៍ផ្ទុយនឹងឆន្ទៈរបស់គេបានឡើយ។ អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំត្រូវហាមឃាត់ជាដាច់ខាត។ គោលការណ៍ស្ម័គ្រចិត្ត ដើម្បីរៀបអាពាហ៍ពិពាហ៍នេះត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ដែលច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជាបានចែងថា "អាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និង តាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយប្រពន្ធមួយ"[14]។

ការអនុវត្តជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជា ការជ្រើសរើសគូស្រករដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ឬ មិនស្ម័គ្រចិត្តនោះពេលខ្លះមានការពិបាកអនុវត្ត និង ពិបាកកំណត់ណាស់។ សង្គមខ្មែរមានប្រពៃណីដ៏សម្បូរបែប និង មានវ័យចំណាស់តាំងពីយូរលង់ណាស់មកហើយនៅភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។ បុត្រធីតាដែលសង្គមខ្មែរអោយតម្លៃថាល្អ គឺស្ដាប់បង្គាប់ឪពុកម្ដាយជីដូនជីតា ជាពិសេសក្នុងរឿងអាពាហ៍ពិពាហ៍ មានពាក្យទំនៀមបុរាណមួយនិយាយថា "នំមិនធំ

[14] មាត្រា ៩៥ វាក្យខណ្ឌទី៤ នៃ រដ្ឋធម្មនុញ្ញ

ជាងនាឡិ៉។ មានន័យថា នៅពេលសម្រេចចិត្តជ្រើសរើសគូស្រករ គឺទុកអោយឪពុក ឬ ម្តាយ ជាអ្នកសម្រេចចិត្តជំនួសសាមីខ្លួន បើគាត់សម្រេចអោយរៀបអាពាហ៍ពិពាហ៍នឹងបុរស ឬ ស្ត្រីណាគឺត្រូវធ្វើតាមគាត់ ហើយបើគាត់សម្រេចមិនអោយរៀបអាពាហ៍ពិពាហ៍ ក៏ត្រូវធ្វើតាមគាត់ដែរ។

ជួនកាលមនុស្សម្នាក់យល់ព្រមទាំងទើសទាល់នឹងធ្វើអ្វីមួយដែលគេពិតជាមិនចង់ធ្វើ។ ជួនកាលមនុស្សត្រូវគេគាបសង្កត់គំរាមកំហែងអោយធ្វើអ្វីម្យ៉ាងតាមវិធីតឹងរឹង ឬ ហិង្សា ដែលការព្រមព្រៀងនោះមិនមែនជាការព្រមព្រៀងដោយស្ម័គ្រចិត្តឡើយ។

ប៉ុន្តែនៅពេលសព្វថ្ងៃនេះ កូនចៅប្រុសស្រីមានសិទ្ធិសេរីភាពជាងមុនក្នុងការសម្រេចចិត្តជ្រើសរើសគូរស្រករ ដោយសារតែមានការរីកចម្រើននៃសិទ្ធិសេរីភាព ការសិក្សាអប់រំ បរិយាកាសសង្គម បញ្ហាសកលភាវូបនីយកម្មសេដ្ឋកិច្ច និង បច្ចេកវិទ្យា ការចម្លងវប្បធម៌ពីបរទេសខ្លះបានធ្វើអោយយុវជនកម្ពុជាខ្លះបានរត់ទាន់ទៅនឹងវប្បធម៌បរទេសការមិនយកចិត្តទុកដាក់អ្វីដែលជាវប្បធម៌ និង ប្រពៃណីជាតិខ្មែរ។

## ៣. អាយុសំរាប់រៀបអាពាហ៍ពិពាហ៍

បុរស និង ស្ត្រីដែលចង់រៀបអាពាហ៍ពិពាហ៍ ត្រូវតែមានអាយុពេញលេញតាមការកំណត់របស់ច្បាប់ ប៉ុន្តែមានករណីលើកលែងមួយចំនួនតាមបញ្ញាត្តិច្បាប់។ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចែងតម្រូវអោយបុរស និង ស្ត្រីមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅដូចគ្នា ដោយមិនបែងចែករវាងបុរស និង ស្ត្រីឡើយ ដោយហេតុថាបុរស និង ស្ត្រីមានសិទ្ធិស្មើគ្នា[15]។

ការដែលក្រមរដ្ឋប្បវេណីថ្មី ដែលបានកំណត់អាយុសម្រាប់អ្នកដែលមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ត្រឹម ១៨ឆ្នាំនេះ គឺដោយសារទំនោររបស់ប្រទេសជាច្រើន និង ដោយផ្អែកលើស្មារតីនៃអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់ចោលនូវរាល់ទម្រង់នៃការរើសអើងស្ត្រី និង ខ្លឹមសាររដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា។ ជាពិសេស ការរីកចម្រើននៃវ័យរបស់មនុស្ស ការផ្លាស់ប្តូរនូវវ័យរបស់មនុស្ស ដែលមនុស្សកាន់តែមានអាយុតិចឡើង មានការទទួលខុសត្រូវ និង ការរួមភេទជាមួយគ្នា។

[15] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ៤. ការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

ភាគីដែលជាអនីតិជនដែលមិនទាន់គ្រប់អាយុ១៨ឆ្នាំ តែត្រូវមានអាយុយ៉ាងតិច១៦ឆ្នាំឡើងទៅ ទើបច្បាប់អនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍បាន និង មានលក្ខខណ្ឌមួយចំនួនដូចខាងក្រោមៈ

- អនីតិជនអាចរៀបអាពាហ៍ពិពាហ៍ជាមួយនីតិជនបាន។
  នៅក្នុងករណីដែលភាគីម្ខាងបានឈានដល់នីតិភាព (មានអាយុ១៨ឆ្នាំយ៉ាងតិច) ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំ អាចអាពាហ៍ពិពាហ៍បាន បើមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា (ឪពុកម្តាយ) ឬ អ្នកអាណាព្យាបាលរបស់អនីតិជន។

- អនីតិជនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអនីតិជនដែលទទួលបានអគ្គាធីនភាព។
  នៅក្នុងករណីដែលភាគីម្ខាងបានឈានដល់នីតិភាពដោយការទទួលបានអគ្គាធីនភាពតាមមាត្រា២១ នៃក្រមរដ្ឋប្បវេណី (មានអាយុពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ) ហើយភាគីម្ខាងទៀតជាអនីតិជន ដែលមានអាយុមិនតិចជាង១៦ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន បើមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា (ឪពុកម្តាយ) ឬ អ្នកអាណាព្យាបាលរបស់អនីតិជន[16]។

## ៥. ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាល (ជនវិកលចរិត) ហើយដែលជានីតិជន ច្បាប់អនុញ្ញាតអោយជនប្រភេទនេះ ក៏អាចរៀបអាពាហ៍ពិពាហ៍បានដែរ ប្រសិនបើជននេះមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈចង់រៀបអាពាហ៍ពិពាហ៍ ក្នុងកម្រិតអប្បបរមាដែលគេអាចទទួលយកបាន។

ជនវិកលចរិត ដែលចង់រៀបអាពាហ៍ពិពាហ៍អាចសម្រេចចិត្តដោយខ្លួនឯងផ្ទាល់បាន គេត្រូវគោរពសេចក្តីសម្រេចចិត្តនោះ ហើយអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅដែលគ្រប់គ្រងជនវិកលចរិតនោះទេ[17]។

---

[16] មាត្រា ៩៥៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[17] មាត្រា ៩៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ៦. ការយល់ព្រមលើការរៀបអាពាហ៍ពិពាហ៍

បុគ្គលដែលមានបំនងរៀបអាពាហ៍ពិពាហ៍ ទោះបីជានីតិជន ឬ អនីតិជន ត្រូវមានការស្រុះស្រួល ឬ ការយល់ព្រមរវាងក្រុមគ្រួសារ និង សាមីខ្លួន ដែលត្រូវគោរពនូវគោលការណ៍ដូចខាងក្រោមនេះ៖

- បុគ្គលដែលជានីតិជន មានបំណងរៀបអាពាហ៍ពិពាហ៍ ច្បាប់មិនតម្រូវអោយមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា (ឪពុកម្តាយ) ឬ អ្នកអាណាព្យាបាលរបស់ខ្លួនឡើយ។
- បុគ្គលដែលជាអនីតិជន មានបំណងរៀបអាពាហ៍ពិពាហ៍ទាមទារអោយមានការយល់ព្រមពីអ្នកដែលមានអំណាចមេបាទាំងពីរ ប៉ុន្តែបើអ្នកដែលមានអំណាចមេបាម្ខាងមិនយល់ព្រមទេ គឺច្បាប់អនុញ្ញាតអោយអ្នកដែលមានអំណាចមេបាតែម្ខាងយល់ព្រម ឬ អ្នកអាណាព្យាបាលរបស់អនីតិជនយល់ព្រមក៏បានដែរ។
- ក្នុងករណីអនីតិជន មានបំណងរៀបអាពាហ៍ពិពាហ៍ ហើយអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលរបស់អនីតិជនមិនយល់ព្រមដោយគ្មានមូលហេតុសមរម្យ ហើយអនីតិជននៅតែមានបំណងរៀបអាពាហ៍ពិពាហ៍ អនីតិជនអាចស្នើសុំទៅតុលាការ ដើម្បីសម្រេចជំនួសអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលរបស់អនីតិជនបាន[18]។

អត្តាធិនភាព សំដៅដល់ស្ថានភាពមួយដែលផ្តល់អោយអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ រួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ។

## ៧. ករណីលើកលែងសមត្ថភាពផ្លូវកាយ និង ស្មារតី

ក្រមរដ្ឋប្បវេណី បានលើកលែងចំពោះបុរស និង ស្ត្រីដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នាដោយក្រមមិនតម្រូវអោយមានសមត្ថភាពផ្លូវកាយដែលច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចាស់បានចែងហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍ឡើយ។ សមត្ថភាពផ្លូវកាយរបស់ភាគីនេះ គឺក្រមរដ្ឋប្បវេណីបានផ្តល់អាទិភាពដល់គូភាគី ដោយឈរលើគោលការណ៍ស្ម័គ្រចិត្តរបស់ភាគីដើម្បីសម្រេចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និង ការយល់ថាអាចរស់នៅដោយសុខដុមជាមួយគ្នាបាន។ ក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ មិនតម្រូវអោយមានសមត្ថភាពខាងស្មារតី ដើម្បីយល់ព្រមអាពាហ៍ពិពាហ៍ទេ[19]។

---

[18] មាត្រា ៩៥៣ វាក្យខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[19] ទំព័រ ៣៩-៤០ ឥន យឿន,នីតិគ្រួសារ និង អាពាហ៍ពិពាហ៍ ២០១៣

ករណីលើកលែងទាំងនោះមានដូចជា៖

- បុរសដែលមានអពលានុភាពនៃលិង្គ
- ភាគីនីមួយៗដែលមានជម្ងឺឃ្លង់ របេង មហារីក កាមរោគ អេដស៍
- ភាគីនីមួយៗទោះបីជាមនុស្សវិកលចរិត និង ជាមនុស្សមានវិបត្តិស្មារតី ដែលធ្វើអោយជននោះមិនអាចយល់អំពីអ្វីដែលគេកំពុងធ្វើ ប៉ុន្តែគេអាចមានសមត្ថភាពត្រឹមផ្តល់ការយល់ព្រមដោយស្ម័គ្រចិត្តចំពោះអាពាហ៍ពិពាហ៍បាន។

នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចាស់ បានហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍ ចំពោះបុគ្គលដែលមានលក្ខខណ្ឌទាំងបីខាងលើនេះ[20]។

## ៨. ការយល់ព្រមចំពោះការរៀបអាពាហ៍ពិពាហ៍នៅពេលសហព័ទ្ធអវត្តមាន ឬ ការបាត់ខ្លួន

ករណីសហព័ទ្ធណាម្នាក់អវត្តមាន ឬ បាត់ខ្លួនធ្វើអោយសហព័ទ្ធម្ខាងទៀតដែលនៅរស់មានការលំបាកក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ក៏ដូចជាកូននៅក្នុងបន្ទុក ជាពិសេសការសម្រេចចិត្តដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។

**អវត្តមាន** សំដៅដល់បុគ្គលណាម្នាក់ដែលបានចេញពីលំនៅឋាន ឬ និវេសនដ្ឋានហើយដែលគ្មានបំណងនឹងត្រឡប់មកវិញឡើយ ។

**ការបាត់ខ្លួន** គឺជាព្រឹត្តិការណ៍ទាំងឡាយដែលអាចឱ្យគេសន្និដ្ឋានថា ជននោះបានបាត់បង់ជីវិតពិតប្រាកដ។ ព្រឹត្តិការណ៍ទាំងនោះជាស្ថានភាពដែលបង្កឱ្យមានលក្ខណៈធ្ងន់ធ្ងរដល់អាយុជីវិតដូចជាការលិចលង់នាវាក្នុងសមុទ្រ សង្គ្រាម ធ្លាក់យន្តហោះ រញ្ជួយដី អគ្គីភ័យ។ល។ ទោះបីជាសាកសពរកមិនឃើញក៏ដោយ តែតាមពត៌មានដែលទទួលបានគេអាចសន្និដ្ឋានបានថា ជននោះពិតជាស្លាប់[21]។

ក្នុងករណីដែលបុគ្គលបានអវត្តមាន ឬ បាត់ខ្លួន ដែលគេគ្មានសង្ឃឹមថា នឹងត្រលប់មកវិញ សហព័ទ្ធម្ខាងទៀតអាចនឹងរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានដូចតទៅ:

### ៨.១. បុគ្គលអវត្តមានលើសពី៥ឆ្នាំ

ក្នុងករណីអ្នកដែលអវត្តមាននោះ មានរយៈពេលលើសពី ៥ឆ្នាំទៅ ហើយគេពុំមានដំណឹងច្បាស់លាស់ថា អ្នកដែលអវត្តមាននោះនៅរស់ ឬ ទទួលមរណភាពទេ សហព័ទ្ធដែលនៅរស់ ឬ

[20] មាត្រា ៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

[21] ទំព័រ៦ អម សុផាណារ៉ាត,នីតិរដ្ឋប្បវេណី២០១២

ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ឬ អ្នកមានផលប្រយោជន៍ផ្សេងទៀត អាចស្នើសុំទៅតុលាការដើម្បីប្រកាសអំពីការបាត់ខ្លួនរបស់អ្នកដែលអវត្តមានយូរនេះបាន ហើយសហព័ទ្ធដែលនៅរស់អាចនឹងរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ឬ ប្រពន្ធថ្មីបាន ក្រោយពេលតុលាការប្រកាសសាលក្រមអំពីការបាត់ខ្លួននេះ[22]។

### ៩.២. បុគ្គលបាត់ខ្លួនក្រោយជួបឧបទ្ទវហេតុលើសពី១ឆ្នាំ

ក្នុងករណីបុគ្គលដែលបានជួបនឹងឧបទ្ទវហេតុដូចជា ចូលទៅក្នុងតំបន់សង្គ្រាម លិចនាវា ការរញ្ជួយផែនដី អគ្គិភ័យ ស៊ូណាមី ជាដើម ហើយពុំមានដំណឹងច្បាស់លាស់ថា បុគ្គលនោះនៅរស់ ឬ ទទួលមរណភាព ដែលមានរយៈពេលលើសពី១ឆ្នាំទៅ ក្រោយពីជួបឧបទ្ទវហេតុនោះ។ តុលាការអាចប្រកាសអំពីការបាត់ខ្លួនរបស់បុគ្គលនោះ តាមពាក្យសុំរបស់សហព័ទ្ធដែលនៅរស់ ឬ ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ឬ បុគ្គលមានផលប្រយោជន៍ផ្សេងទៀត ហើយសហព័ទ្ធដែលនៅរស់ អាចនឹងរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ឬ ប្រពន្ធថ្មីបាន ក្រោយពេលតុលាការប្រកាសសាលក្រមអំពីការបាត់ខ្លួននេះ[23]។ ទោះបីបុគ្គលដែលត្រូវបានតុលាការប្រកាសអំពីការបាត់ខ្លួននោះ នៅរស់ហើយត្រឡប់មកវិញក៏ដោយក្នុងករណីដែលភាគីម្ខាងទៀត បានរៀបអាពាហ៍ពិពាហ៍ជាមួយប្តី ឬ ប្រពន្ធថ្មីហើយ បុគ្គលដែលនៅរស់នោះ មិនអាចប្តឹងលុបអាពាហ៍ពិពាហ៍ថ្មីនោះបានទេ ហើយអាពាហ៍ពិពាហ៍ថ្មីនោះ មានអានុភាពលុបអាពាហ៍ពិពាហ៍មុន[24]។

ក្រមរដ្ឋប្បវេណី បានអនុញ្ញាតឱ្យការបាត់ខ្លួនរបស់សហព័ទ្ធណាមួយបញ្ចប់អាពាហ៍ពិពាហ៍ពីមុន ដោយមានហេតុផលយ៉ាងតិច ២ យ៉ាង។ ទី១ ច្បាប់បានផ្តល់ដល់សហព័ទ្ធដែលមិនបាត់ខ្លួន និង កូនណាមួយមានឱកាសចាប់ផ្តើមជីវិតថ្មីបាន។ ទី២ ច្បាប់ផ្តល់ដល់គូភាគីដែលបានរៀបអាពាហ៍ពិពាហ៍ជាលើកទី២ ថាការរៀបអាពាហ៍ពិពាហ៍របស់គេពិតជាមានលក្ខណៈត្រឹមត្រូវតាមច្បាប់។ ជាការពិត នៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា កាវិនិច្ឆ័យថាសហព័ទ្ធមុនបាន "បាត់ខ្លួនពិតមែន" មិនអាចធ្វើការកែប្រែបានទេ។ ទោះបីបានសហព័ទ្ធដែលបាត់ខ្លួននោះ នៅពេលក្រោយមក បានវិលត្រលប់មកវិញក៏ដោយ ក៏គេមិនអាចប្តឹងជំទាស់សេចក្តីសម្រេចរបស់តុលាការពីមុនបានទេ។

[22] មាត្រា ៩១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[23] មាត្រា ៩១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[24] មាត្រា ៩៤ វាក្យខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## កថាខណ្ឌទី២ លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍

លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍ គឺជាលក្ខខណ្ឌដែលច្បាប់បានកំណត់នឹងតម្រូវអោយគូភាគីទាំងពីរអនុវត្តតាមនីតិវិធីនោះអោយត្រឹមត្រូវ ដើម្បីអោយអាពាហ៍ពិពាហ៍មានសុពលភាព និង អាចប្រព្រឹត្តទៅបានត្រឹមត្រូវតាមច្បាប់។ នៅក្នុងលក្ខខណ្ឌទម្រង់នេះផងដែរ មានលក្ខខណ្ឌតូចៗជាច្រើនទៀត ដូចជាៈ

### ១. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

មុនពិធីរៀបអាពាហ៍ពិពាហ៍ បុរស និង ស្ត្រី ដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា ត្រូវធ្វើលិខិតបញ្ជាក់ពីឃុំ សង្កាត់ ខាងលំនៅរបស់ភាគីរៀងៗខ្លួនអំពីភាពនៅលីវ ឬ មេម៉ាយ ឬ ពោះម៉ាយ ដោយមិនមានការជាប់ជំពាក់ជាមួយបុគ្គលណាផ្សេងឡើយ។

ក្រោយពីទទួលបានលិខិតបញ្ជាក់នេះហើយ ដោយមានទាំងឪពុកម្ដាយនៅរស់ ឬ អាណាព្យាបាលរួមជាមួយផង ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅខាងឃុំ ឬ សង្កាត់នៃលំនៅដ្ឋាន ភាគីខាងស្រីរស់នៅ។ ក្រោយពីមេឃុំ ឬ ចៅសង្កាត់ទទួលពាក្យស្នើសុំនោះហើយ ក្នុងឋានៈលោកជាមន្ត្រីអត្រានុកូលដ្ឋាន ត្រូវចេញលិខិតអនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍ និង ចេញប័ណ្ណប្រកាសសម្រាប់ការរៀបអាពាហ៍ពិពាហ៍អោយទៅភាគីទាំងពីរយកទៅបិទផ្សាយជាសាធារណៈទៀតផង[25]។

### ២. ប័ណ្ណប្រកាសជាសាធារណៈ

ការបិទប្រកាសនេះ មានគោលដៅបង្កលទ្ធភាពដល់ជនដែលមានប្រយោជន៍នៅក្នុងរឿងនេះដឹងឮ ហើយអាចប្ដឹងទាស់នឹងអាពាហ៍ពិពាហ៍នេះបាន ប្រសិនបើមានការមិនយល់ព្រម ឬ ក៏ការរៀបអាពាហ៍ពិពាហ៍នោះប៉ះពាល់ដល់សិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ហើយត្រូវបានច្បាប់ការពារសិទ្ធិ និង ផលប្រយោជន៍ទាំងនោះ។

មេឃុំ ចៅសង្កាត់ដែលមានមុខងារជាមន្ត្រីអត្រានុកូលដ្ឋាននៅក្នុងឃុំសង្កាត់ខាងស្រីរស់នៅ ជាអ្នកចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និង ជាអ្នកចេញប័ណ្ណប្រកាសការរៀបអាពាហ៍ពិពាហ៍។ ប័ណ្ណប្រកាសជាសាធារណៈនៃអាពាហ៍ពិពាហ៍ ដែលមានគម្រោងនឹងរៀបអាពាហ៍ពិពាហ៍ ត្រូវតែបិទផ្សាយក្នុងរយៈពេល ១០ ថ្ងៃ នៅលំនៅឋានខាងស្រី និង នៅសាលា

[25] មាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឃុំសង្កាត់ខាងស្រី ហើយប័ណ្ណប្រកាសពីរទៀត ត្រូវផ្ញើទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ខាងបុរស ដើម្បីយកទៅបិទនៅលំនៅបុរស និង សាលាឃុំ ឬ សង្កាត់របស់ខ្លួន[26]។

ប័ណ្ណប្រកាសត្រូវតែមានចុះពត៌មានដូចខាងក្រោមៈ

- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង ទីលំនៅដ្ឋានរបស់អនាគតប្តី និង ប្រពន្ធ
- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និង ទីលំនៅដ្ឋានរបស់ឪពុកម្តាយនៃអនាគតប្តីប្រពន្ធ។ បើឪពុកម្តាយណាមួយស្លាប់ ត្រូវដាក់ថា "ស្លាប់"។
- ដាក់រយៈពេលកំនត់ អោយភាគីដែលពាក់ព័ន្ធអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍បាន (រយៈពេល១០ថ្ងៃ គិតចាប់ពីថ្ងៃបិទប័ណ្ណប្រកាសផ្សាយជាសាធារណៈ) ។

### ៣. រយៈពេលរង់ចាំ

ភាគីទាំងពីរដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ ត្រូវរង់ចាំរយៈពេល១០ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ជាសាធារណៈ ហើយបើក្នុងរយៈពេល១០ថ្ងៃនេះ គ្មាននរណាប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍របស់ពួកគេទេ នោះពិធីរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន។ ប៉ុន្តែបើមានបណ្តឹងទាស់ ការរៀបអាពាហ៍ពិពាហ៍នោះមិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើបណ្តឹងទាស់នោះមិនត្រូវបានដោះស្រាយចប់។

### ៤. ជនអាចប្តឹងជំទាស់អាពាហ៍ពិពាហ៍

បើសិនមានជនណាម្នាក់ដាក់ពាក្យប្តឹងជំទាស់ទៅនឹងគម្រោងរៀបអាពាហ៍ពិពាហ៍ មន្ត្រីនៃស្ថាប័នពាក់ព័ន្ធត្រូវដោះស្រាយបណ្តឹងនោះអោយចប់សព្វគ្រប់សិន ទើបអាចរៀបអាពាហ៍ពិពាហ៍បាន។ ជនដែលមានប្រយោជន៍ អាចជាសាច់ញាតិ ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ឬ តតិយជនណាម្នាក់ដែលអាចមានការពាក់ព័ន្ធជាមួយអាពាហ៍ពិពាហ៍ដោយផ្ទាល់ ដូចជាភាគីដែលគ្រោងរៀបអាពាហ៍ពិពាហ៍ធ្លាប់ជាប្តីប្រពន្ធរបស់ខ្លួន ហើយមកលួចរៀបអាពាហ៍ពិពាហ៍ជាថ្មី ឬ ធ្លាប់រស់នៅជាមួយគ្នាពីមុនដោយមិនបានរៀបអាពាហ៍ពិពាហ៍ជាដើម អាចប្តឹងជំទាស់គម្រោងអាពាហ៍ពិពាហ៍ក្នុងចន្លោះ១០ថ្ងៃ ចាប់ពីការបិទប័ណ្ណប្រកាសអំពីអាពាហ៍ពិពាហ៍ ដែលគ្រោងនឹងរៀបចំនេះ។

[26] មាត្រា ១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

## ៥. មូលហេតុជំទាស់នឹងគម្រោងអាពាហ៍ពិពាហ៍

អត្រានុកូលដ្ឋាន មានសិទ្ធិបដិសេធមិនទទួលយកសំណើសុំរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីមានមូលហេតុណាមួយដូចខាងក្រោមនេះ ៖

- អនាគតប្តី ឬ ប្រពន្ធមិនទាន់ដល់នីតិភាព (អាយុក្រោម១៨ឆ្នាំ) ឬ ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតមានអាយុក្រោម ១៦ឆ្នាំ។
- ករណីភាគីមានសហាព័ទ្ធហើយ (មានប្តី ឬ ប្រពន្ធ)។
- អំឡុងពេលហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ក្នុងករណីដែលនារីត្រូវបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍មុន ហើយនៅមិនទាន់គ្រប់រយៈ១២០ថ្ងៃ។
- ករណីដែលអាពាហ៍ពិពាហ៍បានធ្វើឡើងរវាងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិត។
- ករណីដែលអាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងញាតិពន្ធនៃខ្សែផ្ទាល់ ឬ អាពាហ៍ពិពាហ៍គ្រោងធ្វើឡើងរវាងសាខាញាតិពន្ធ។
- អាពាហ៍ពិពាហ៍របស់អនីតិជនដែលមិនមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។
- អាពាហ៍ពិពាហ៍របស់ជនវិកលចរិត (ជននៅក្រោមអាណាព្យាបាលទូទៅ) ដែលមិនមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមាបាន។

នៅក្នុងករណីទាំងអស់ខាងលើនេះ មន្ត្រីអត្រានុកូលដ្ឋានមានសិទ្ធិមិនអនុញ្ញាតអោយរៀបអាពាហ៍ពិពាហ៍ ឬ មានសិទ្ធិប្តឹងជំទាស់មិនអោយរៀបអាពាហ៍ពិពាហ៍បាន[27]។

## ៦. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ ដំណាក់កាលចុងក្រោយក្នុងការបង្កើតអោយមានអាពាហ៍ពិពាហ៍ស្របច្បាប់មួយ ដែលទទួលស្គាល់ដោយច្បាប់ គឺ "ការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន" ខាងលំនៅឋានរបស់នារី។ នីតិវិធីបែបនេះអ្នកខ្លះហៅថា "ការចុះអេតាស៊ីវិល"។ អនុក្រឹត្យលេខ១០៣ អនក្រប.ក ស្តីពីអត្រានុកូលដ្ឋានចែងថា អនាគតប្តីប្រពន្ធ រួមទាំងសាក្សី ២នាក់ ដែលមានអាយុឈានដល់នីតិភាព ត្រូវចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ១រូប ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះកិច្ចសន្យានោះ ក្នុងសៀវភៅអាពាហ៍ពិពាហ៍របស់ឃុំសង្កាត់ ហើយភាគីត្រូវផ្តិតមេដៃ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះហត្ថលេខា និងបោះត្រាលើសៀវភៅនោះផងដែរ។

---

[27] មាត្រា ៩៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទោះជាយ៉ាងណា អនាគតប្ដី ឬ ប្រពន្ធត្រូវបញ្ជាក់ប្រាប់មន្ត្រីអត្រានុកូលដ្ឋានថា "អាពាហ៍ពិពាហ៍របស់គេធ្វើឡើងដោយស្ម័គ្រចិត្ត"។ ពិធីខាងសាសនាពុំមានលក្ខណចាំបាច់ដែលតម្រូវអោយធ្វើដូចជាបណ្ដាប្រជាជនដែលកាន់សាសនាគ្រិស្តនោះឡើយ ហើយដែលពិធីខាងសាសនា ត្រូវបានគេរៀបចំធ្វើក្នុងពិធីរៀបអាពាហ៍ពិពាហ៍រួចហើយ។ ការនេះពុំមែនមានន័យថា ពិធីទាំងខាងសាសនានោះ គ្មានសារៈសំខាន់ត្រូវបានគេបំភ្លេចចោល ឬ មើលរំលងនោះទេ ការពិតវាមានសារៈសំខាន់យ៉ាងខ្លាំង ហើយដែលគេបានរៀបចំក្នុងពិធីរៀបអាពាហ៍ពិពាហ៍រួចហើយ។

### ៧. ការចេញសំបុត្រអាពាហ៍ពិពាហ៍

នៅក្រោយពេលសាមីខ្លួន អនាគតប្ដីនិងប្រពន្ធបានមករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ បន្ទាប់មកត្រូវប្រគល់អោយសាមីខ្លួនប្ដីប្រពន្ធនូវសំបុត្រមួយហៅថា "សំបុត្រអាពាហ៍ពិពាហ៍" ជាច្បាប់ដើមមួយច្បាប់និង "សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍" មួយចំនួនទៀតតាមការស្នើសុំរបស់ភាគី។

នៅក្នុង "សំបុត្រអាពាហ៍ពិពាហ៍" មានចុះឈ្មោះរបស់សហព័ទ្ធ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ថ្ងៃខែឆ្នាំចុះសំបុត្រអាពាហ៍ពិពាហ៍ជាដើម។ "សំបុត្រអាពាហ៍ពិពាហ៍" នេះមានសារៈសំខាន់ខ្លាំង ដើម្បីបញ្ជាក់ធម្មានុរូបនៃប្ដីប្រពន្ធដែលកើតចេញពីអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់[28]។

## កថាខណ្ឌទី៣ លក្ខខណ្ឌហាមឃាត់ការរៀបអាពាហ៍ពិពាហ៍

ក្រមរដ្ឋប្បវេណីថ្មី បានហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍សម្រាប់លក្ខខណ្ឌមួយចំនួនដូចខាងក្រោមៈ

### ១. ការហាមមិនឱ្យមានទ្វេពន្ធភាព

បុគ្គលដែលមានប្ដី ឬ ប្រពន្ធហើយ ចំណងអាពាហ៍ពិពាហ៍នោះនៅមានសុពលភាពនៅឡើយ ឬ មិនទាន់លែងលះគ្នាដាច់ស្រឡះ។ ហើយចង់រៀបអាពាហ៍ពិពាហ៍ប្ដី ឬ ប្រពន្ធថ្មីមួយទៀត ក្រមរដ្ឋប្បវេណី មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ[29]។

ការចែងរបៀបនេះ គឺស្របជាមួយរដ្ឋធម្មនុញ្ញសព្វថ្ងៃ ដែលច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៤៥ ដែលមានគោលបំណងសំខាន់ក្នុងការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ មាត្រានេះចែងថា "បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាលើគ្រប់វិស័យ ជាពិសេសក្នុង

[28] ទំព័រ ៨០ ឥន យឿន,នីតិគ្រួសារ និង អាពាហ៍ពិពាហ៍ ២០១៣

[29] មាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អាពាហ៍ពិពាហ៍ និង គ្រួសារ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និង តាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយ ប្រពន្ធមួយ”។

ទោះបីជារដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និង ក្រមរដ្ឋប្បវេណីបច្ចុប្បន្ន បានហាមឃាត់មិនឱ្យបុរស ឬ ស្ត្រី មានប្ដី ឬ ប្រពន្ធ ២ ឬ ៣ យ៉ាងដូច្នេះក៏ដោយ ប៉ុន្តែការរស់នៅក្នុងសង្គមជាក់ស្តែង មានបុរសដែលបានរស់នៅក្នុងពេលតែមួយជាមួយប្រពន្ធ ២ ឬ លើសនេះក៏មាន ដែលអ្នកខ្លះបាន រៀបអាពាហ៍ពិពាហ៍ តែអ្នកខ្លះទៀតមិនបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវ ហើយភាគីខាងស្ត្រីព្រមព្រៀងរស់នៅជាមួយគ្នា ដោយមិនប្ដឹងផ្ដល់។

ការដែលច្បាប់បានហាមឃាត់មិនអោយរៀបនៅក្នុងករណីដែលអាពាហ៍ពិពាហ៍មុនត្រូវបាន បញ្ចប់ដោយមរណភាព លែងលះ ឬ មោឃអាពាហ៍ពិពាហ៍រវាងប្ដីមួយប្រពន្ធច្រើននាក់ ឬ ប្ដីច្រើននាក់ប្រពន្ធមួយនេះគឺហាមចំពោះអាជ្ញាធរមិនត្រូវចេញលិខិតអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍របៀបនេះឡើយ ប៉ុន្តែក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាធ្វើរបៀបនេះ អាស្រ័យលើភាគីអាចរស់នៅ ជាមួយគ្នាបាន តែច្បាប់មិនមានចែងថា ការមានប្ដី ឬ ប្រពន្ធច្រើនជាការខុសច្បាប់ ហើយមិនត្រូវមានទោសឡើយ លើកលែងតែមានការប្ដឹងផ្ដល់ពីភរិយាដើម។

## ២. អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី

ភាពនៃអាពាហ៍ពិពាហ៍នោះ បុរសម្នាក់អាចរៀបអាពាហ៍ពិពាហ៍ជាថ្មីម្ដងទៀត នៅពេលណាក៏បានក្រោយការបញ្ចប់អាពាហ៍ពិពាហ៍មុន។ ទោះជាយ៉ាងណាក៏ដោយស្ត្រីដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ម្ដងទៀត ត្រូវរង់ចាំ ១២០ថ្ងៃ បន្ទាប់ពីការបញ្ចប់អាពាហ៍ពិពាហ៍លើកមុន[30]។

បើសិនជាតុលាការបានសម្រេចឱ្យប្ដីប្រពន្ធលែងលះតាមផ្លូវច្បាប់ មុនពេលសម្រេចឱ្យលែងលះគ្នា រយៈពេលរង់ចាំត្រូវរាប់ចាប់តាំងពីថ្ងៃមានសាលក្រម ឬ សាលដីកាឱ្យនៅបែកគ្នា។ ច្បាប់តម្រូវឱ្យស្ត្រីរង់ចាំ ១២០ថ្ងៃ ដើម្បីកំណត់បិតុភាពនៃកូនដែលលកើតនៅក្នុងឆ្នាំបន្ទាប់ពីការបញ្ចប់អាពាហ៍ពិពាហ៍លើកមុន។ ប្រសិនបើស្ត្រីម្នាក់បានរៀបអាពាហ៍ពិពាហ៍ឆាប់រហ័សពេក ក្រោយការបញ្ចប់អាពាហ៍ពិពាហ៍លើកមុនរបស់ខ្លួន ហើយកូនដែលកើតមកក្រោយពេលរៀបអាពាហ៍ពិពាហ៍ថ្មីហើយ ធ្វើឱ្យកើតមានបញ្ហាស្ដីពីការកំណត់បិតុភាពរបស់កូននោះថា ជាកូនរបស់ប្ដីមុន ឬ ជាកូនរបស់ប្ដីក្រោយ។

អំឡុងពេលដែលត្រូវរង់ចាំ ដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មីនេះត្រូវលើកលែងផងដែរ ក្នុងករណីពីរយ៉ាងដូចខាងក្រោម:

[30] មាត្រា ៩៥០ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ករណីទី១ : ស្ត្រីនោះមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍ចាស់ត្រូវបានរំលាយ ឬ លុបចោល ឬ ប្ដីស្លាប់ ហើយបានសម្រាលកូន គឺស្ត្រីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានដោយមិនបាច់រង់ចាំរយៈពេល១២០ថ្ងៃទេ ពីព្រោះកូននោះត្រូវសន្មតថា ជាកូនរបស់ប្ដីមុនហើយ។

ករណីទី២ : ស្ត្រីដែលបានលែងលះគ្នា ឬ ប្ដីស្លាប់ចោលនោះមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិតថា គ្មានផ្ទៃពោះ ស្ត្រីរូបនោះក៏អាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន ដោយមិនបាច់រង់ចាំរយៈពេល ១២០ ថ្ងៃដែរ[31]។

## ៣. ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ក្នុងញាតិលោហិត

**ញាតិលោហិត** សំដៅដល់ញាតិដែលមានឈាមជ័រជាមួយគ្នាដូចជា ឪពុក និង កូន ឬ ម្ដាយ និងកូន ជាដើម។

**សាខាញាតិ** សំដៅដល់ញាតិដែលចែកជាមែកធាងពីអ្នកបង្កើតរួម ដូចជា បងប្អូនបង្កើត មីង មា ក្មួយ បងប្អូនជីដូនមួយ...។

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិតគ្នា ដោយសារមូលហេតុនៃសីលធមិសង្គម។

បុរស និង ស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នាមិនត្រូវមានជាប់ចំនងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតរហូតដល់ថ្នាក់ទី៣។ ទោះបីក្នុងករណីដែលមានការបញ្ចប់នូវ ទំនាក់ទំនងរវាងឪពុកម្ដាយនឹងកូនបង្កើត ឬ ការកាត់កាល់រវាងឪពុកម្ដាយចិញ្ចឹមនឹងកូនសុំហើយក៏ដោយ។

មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណីបានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិដែលមានទំនាក់ទំនងគ្នា ចំពោះករណីមួយចំនួនដូចខាងក្រោម៖

### ៣.១. ហាមការរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់

មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណីបានចែងថា "ហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតខ្សែផ្ទាល់គ្រប់ថ្នាក់ទាំងអស់" ដែលមានដូចជា៖

- រវាងជីលាជាមួយចៅលា (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៥)
- រវាងជីលួតជាមួយចៅលួត (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៤)
- រវាងជីទួតជាមួយចៅទួត (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី៣)

[31] មាត្រា ៩៥០ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- រវាងជីតា ឬជីដូនជាមួយចៅ (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី២)
- រវាងឪពុកម្តាយជាមួយកូន (ញាតិលោហិតខ្សែផ្ទាល់ថ្នាក់ទី១)

### ៣.២. ហាមការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិត

ក្រមរដ្ឋប្បវេណីបានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិលោហិតក្នុង ៣ ថ្នាក់ រាប់ទាំងថ្នាក់ទី៣[32] នេះផង មានដូចជា៖

- រវាងបងប្អូនបង្កើត (សាខាញាតិថ្នាក់ទី២)
- រវាងពូ ឬ មីងជាមួយក្មួយ (សាខាញាតិថ្នាក់ទី៣)

ប៉ុន្តែសម្រាប់សាខាញាតិលោហិតចាប់ពីថ្នាក់ទី៤ ទៅអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដូចជា បងប្អូនជីដូនមួយ ឬ ជីទួតមួយជាដើម។

### ៣.៣.ហាមការរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬ ម្តាយបង្កើតជាមួយអតីតកូនបង្កើត

ច្បាប់ហាមមិនអោយរៀបអាពាហ៍ពិពាហ៍រវាងអតីតឪពុក ឬ ម្តាយបង្កើតជាមួយអតីតកូនបង្កើត ដែលបានបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើតដោយសារការបង្កើតសុំកូនពេញលេញ[33]។ មានន័យថា ក្នុងករណីដែលអតីតឪពុកបង្កើត ឬ អតីតម្តាយបង្កើត ត្រូវបានបញ្ចប់នូវភាពជាឪពុក ឬ ម្តាយបង្កើតដោយសារមូលហេតុណាក៏ដោយ ក៏អតីតឪពុកបង្កើត ឬ អតីតម្តាយបង្កើត មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអតីតកូនបង្កើតរបស់ខ្លួនបានដែរ។

### ៣.៤.ហាមការរៀបអាពាហ៍ពិពាហ៍អតីតឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមជាមួយកូនសុំ

ច្បាប់ហាមមិនអោយរៀបអាពាហ៍ពិពាហ៍រវាងឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមជាមួយកូនសុំ។ ទោះបីជាទំនាក់ទំនងញាតិត្រូវបានកាត់ផ្តាច់ហើយ ដោយសារមូលហេតុណាក៏ដោយ ក៏អតីតឪពុកចិញ្ចឹម ឬ អតីតម្តាយចិញ្ចឹម មិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយអតីតកូនចិញ្ចឹមបានដែរ[34]។

---

[32] មាត្រា ៩៥១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[33] មាត្រា ៩៥១ វាក្យខណ្ឌទី២ និង មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[34] មាត្រា ៩៥១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ៤. ការហាមឃាត់មិនអោយរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

**ញាតិពន្ធ** សំដៅដល់ ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និង ញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត ឬហៅថា "សាច់ថ្លៃ"។

**ឧទាហរណ៍** : ឪពុកម្ដាយក្មេក និង កូនប្រសា បងថ្លៃប្អូនថ្លៃ (ខាងប្ដី ឬ ខាងប្រពន្ធ)។

**ញាតិពន្ធខ្សែផ្ទាល់** សំដៅដល់ ញាតិលោហិតផ្ទាល់ខាងសាច់ថ្លៃដែលកើតតពីមួយទៅមួយតាមលំដាប់ ដូចជា ជីដូនជីតាក្មេក ឪពុកម្ដាយក្មេក កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត។

បុរស និង ស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នា មិនត្រូវមានជាប់ចំណងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះបីជានៅថ្នាក់ណាក៏ដោយ ដែលក្រមរដ្ឋប្បវេណីបានហាមឃាត់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ទេ។ ទោះបីជាញាតិពន្ធខ្សែផ្ទាល់បានបញ្ចប់ទំនាក់ទំនងញាតិពន្ធហើយក៏ដោយ ច្បាប់មិនអនុញ្ញាតឱ្យញាតិពន្ធខ្សែផ្ទាល់នោះ អាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានដែរ។ អាពាហ៍ពិពាហ៍ ពុំអាចធ្វើបានឡើយ រវាងញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធនៅក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ ផង[35]។

ការរៀបអាពាហ៍ពិពាហ៍ រវាងញាតិពន្ធ គឺជាអាពាហ៍ពិពាហ៍មួយដែលច្បាប់ហាមឃាត់។ ប្រសិនមានភាគីណាបានរៀបអាពាហ៍ពិពាហ៍ជាមួយញាតិពន្ធនោះគឺជាអំពើល្មើសច្បាប់ ហើយច្បាប់ក៏មិនទទួលស្គាល់ផងដែរ។

### ៤.១. ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់

ច្បាប់បានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ទាំងអស់ ហើយទោះបីទំនាក់ទំនងញាតិពន្ធខ្សែផ្ទាល់ត្រូវបានបញ្ចប់ហើយក៏ដោយ មានដូចជា:

- រវាងឪពុកម្ដាយក្មេក និង កូនប្រសា
- រវាងជីដូនជីតាក្មេក និង ចៅប្រសា
- រវាងជីដូនជីតាទួតក្មេក និង ចៅទួតប្រសា
- រវាងជីលួតក្មេក និង ចៅលួតប្រសា
- រវាងជីលាក្មេក និង ចៅលាប្រសា

[35] មាត្រា ៩៥២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- រវាងអតីតឪពុកម្ដាយក្មេក និង អតីតកូនប្រសា
- រវាងអតីតជីដូនជីតាក្មេក និង អតីតចៅប្រសា
- រវាងអតីតជីដូនជីតាទួតក្មេក និង អតីតចៅទួតប្រសា
- រវាងអតីតជីលួតក្មេក និង អតីតចៅលួតប្រសា
- រវាងអតីតជីលាក្មេក និង អតីតចៅលាប្រសា

## ៤.២. ការហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ

ក្រមរដ្ឋប្បវេណី បានហាមមិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធនៅក្នុង៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣នេះផង[36] ហើយទោះបីទំនាក់ទំនងញាតិពន្ធត្រូវបានបញ្ចប់ហើយក៏ដោយ ក៏មិនអាចរៀបអាពាហ៍ពិពាហ៍បានដែរ មានដូចជា៖

- រវាងបងថ្លៃប្អូនថ្លៃ (សាខាញាតិពន្ធថ្នាក់ទី២)
- រវាងអតីតបងថ្លៃ និង អតីតប្អូនថ្លៃ
- រវាងពូ ឬ មីងក្មេក ជាមួយក្មួយប្រសា (សាខាញាតិថ្នាក់ទី៣)
- រវាងអតីតពូមីងក្មេកជាមួយអតីតក្មួយប្រសា
- រវាងបងប្អូនបង្កើតរបស់ប្ដីជាមួយបងប្អូនបង្កើតរបស់ប្រពន្ធ
- រវាងអតីតបងប្អូនបង្កើតរបស់ប្ដីជាមួយអតីតបងប្អូនបង្កើតរបស់ប្រពន្ធ

ដោយសាខាញាតិពន្ធនេះ មាននិន្នាការបង្កើតទំនាក់ទំនងញាតិជារូមដែលមានលក្ខណៈជិតស្និតស្រដៀងគ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និង សាខាញាតិលោហិតដែរ។ប៉ុន្តែដោយសារនៅក្នុងប្រទេសកម្ពុជា មានករណីការរៀបអាពាហ៍ពិពាហ៍ជាមួយបងថ្លៃ ឬ ប្អូនថ្លៃ ដូចជាករណីប្ដីបានទទួលមរណភាពទៅ ហើយប្រពន្ធបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយបង ឬ ប្អូនប្រុសដែលនៅលីវរបស់សពប្ដី ឬ ករណីដែលប្រពន្ធបានទទួលមរណភាពទៅ បងស្រី ឬ ប្អូនស្រីរបស់សពប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយបងថ្លៃ ឬ ប្អូនថ្លៃប្រុស នោះដើម្បីមើលថែទាំកូនរបស់បុគ្គលដែល

[36] មាត្រា ៩៥២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទទួលមរណភាពជាដើម។ ម្យ៉ាងទៀត មានការរៀបអាពាហ៍ពិពាហ៍រវាងបងប្អូនបង្កើតរបស់ប្តីជាមួយបងប្អូនបង្កើតរបស់ប្រពន្ធ ក៏កើតមានផងដែរ ទើបក្រមរដ្ឋប្បវេណីថ្មីបានបញ្ញត្តិហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ករណីទាំងនោះ។

### ៤.៣. ការហាមមិនរៀបអាពាហ៍ពិពាហ៍រវាងឪពុកម្តាយចុងជាមួយកូនចុង

ចំពោះករណីឪពុកចុង ឬ ម្តាយចុង ឬ ជាមួយកូនចុង ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានហាមឃាត់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានទេ។ ករណីនេះទាក់ទងនឹងបញ្ញត្តិហាមឃាត់ញាតិពន្ធខ្សែផ្ទាល់ ដែលរួមមានទាំងរវាងឪពុកចុង ឬ ម្តាយចុងជាមួយកូនចុង។

### ៤.៤. ករណីលើកលែងអាចរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធ

ក្នុងករណីដែលសហព័ទ្ធណាម្នាក់ (ប្តីឬប្រពន្ធ) បានទទួលមរណភាព ហើយសហព័ទ្ធម្ខាងទៀតនៅរស់ អាចរៀបអាពាហ៍ពិពាហ៍ជាមួយសាខាញាតិរបស់សហព័ទ្ធម្ខាងទៀតបាន ត្រឹមថ្នាក់ទី ៣ ពោលគឺ អាចរៀបអាពាហ៍ពិពាហ៍រវាងអតីតពូមីងក្មេកជាមួយអតីតក្មួយប្រសាបាន។ ប៉ុន្តែមិនអាចរៀបអាពាហ៍ពិពាហ៍ រវាងអតីតបងថ្លៃ និង អតីតប្អូនថ្លៃបានទេ[37]។

## ផ្នែកទី៣ អានុភាពនៃអាពាហ៍ពិពាហ៍

ក្រោយពីរៀបអាពាហ៍ពិពាហ៍បុរស និង ស្ត្រីនោះនឹងក្លាយជាប្តីប្រពន្ធស្របតាមប្រពៃណី ប៉ុន្តែករណីដែលពិសេសជាងនេះទៅទៀតនោះ គឺ ការចុះសំបុត្រអាពាហ៍ពិពាហ៍នឹងធ្វើឱ្យជីវិតប្តីប្រពន្ធរបស់ពួកគេកាន់តែមានអានុភាពចំពោះមុខច្បាប់ថែមទៀត។ អានុភាពទាំងនោះ គឺបានកំណត់នូវសិទ្ធិ និង ករណីកិច្ចរបស់សហព័ទ្ធនៅក្នុងគ្រួសារ ដើម្បីឱ្យប្តីប្រពន្ធនៅក្នុងគ្រួសារមានសិទ្ធិ និង កាតព្វកិច្ចដូចគ្នា។

### កថាខណ្ឌទី១ នាមត្រកូលរបស់ប្តីប្រពន្ធ

ដោយផ្អែកតាមការកំណត់"នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍

[37] មាត្រា ៩៥២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បាន″ [38]។ មាត្រានេះគោរពសិទ្ធិស្វ័យសម្រេចចំពោះនាមត្រកូល និង សិទ្ធិបុគ្គល និង ធានារបប ដែលប្តីប្រពន្ធអាចជ្រើសរើសប្រើនាមត្រកូលខុសគ្នា។ ជាគោលការណ៍ ប្តីប្រពន្ធនៅប្រទេសកម្ពុជា ប្រើនាមត្រកូលខុសគ្នា ដោយសារតែនាមត្រកូលបង្ហាញឱ្យតំណខ្សែលោហិត និង ឫសគល់នៃ ឪពុកម្តាយ និង ដូនតា ហើយដោយសារតែវាមានតួនាទីសម្គាល់អត្តសញ្ញាណរបស់ជនគ្រប់រូប ជាមួយនឹងនាមខ្លួន ទើបយើងសម្រេចយកយន្តការដែលជនគ្រប់រូបអាចជ្រើសរើសដោយសេរី នូវនាមត្រកូល បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច។ នៅប្រទេសកម្ពុជា កូនកើតមក តាមទំនៀមទំលាប់ គឺដាក់ឈ្មោះតាមឪពុក ជីតា ឬ បុព្វជនដែលចាស់ជាងនេះទៀត ក៏ប៉ុន្តែការអនុវត្តយកនាមត្រកូលគ្រួសារពុំច្បាស់លាស់ទេ។ ទោះជាដូច្នេះក្តី ផ្នែកដំបូងនៃឈ្មោះហាក់ដូចជាត្រូវចាត់ទុកថាជា នាមត្រកូល ឬ ត្រកូល ហើយនៅពេលចុះបញ្ជី ក៏ចាំបាច់ត្រូវធ្វើការបែងចែកនាមត្រកូល និង នាមខ្លួន ហើយដោយផ្អែកលើលទ្ធផលនៃការស្ទង់មតិយោបល់ដែលថាការទទួលស្គាល់ការជ្រើសរើសឈ្មោះរបស់ប្តីប្រពន្ធជាការសមរម្យ ទើបយើងសម្រេចថា ការប្រើនាមត្រកូលរួម ឬ នាមត្រកូលដោយឡែកក៏មិនមានបញ្ហាអ្វីដែរ[39]។

## កថាខណ្ឌទី២ ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក

ប្តីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក។មាន ន័យថា អាពាហ៍ពិពាហ៍ គឺជាសម្ព័ន្ធភាពផ្លូវចិត្ត រាងកាយ សេដ្ឋកិច្ច នៃប្តីប្រពន្ធ។

ប្តីប្រពន្ធត្រូវមានភាពស្មើភាពគ្នាលើគ្រប់ទស្សនៈ ហើយប្តីប្រពន្ធមានករណីយកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នា និង ជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាព ព្រមទាំងកសាងគ្រួសារមួយ មានសាមគ្គីភាព និង ប្រកបដោយសុភមង្គល។ សហព័ទ្ធទាំងសងខាង ត្រូវជួយសង្គ្រោះគ្នា ទាំងផ្នែកសំភារៈ និង ថវិការ ឬ ចែកការងារគ្នាដោយម្ខាងជាអ្នករកប្រាក់ ហើយម្ខាងទៀត ធ្វើការងារផ្ទះ មើលថែរក្សាកូន និង ធ្វើម្ហូបអាហារជាដើម[40]។

## កថាខណ្ឌទី៣ សេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ

ប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាព នយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន។ ដើម្បីសម្រេចឱ្យបានជាក់ស្តែងនូវភាពស្មើគ្នា ច្បាប់បាន

[38] មាត្រា ៩៦៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[39] មាត្រា ៩៦៥ សេចក្តីកំនត់ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[40] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ទទួលស្គាល់ឱ្យប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ និង សិទ្ធិចូលរួមប្រាស្រ័យដោយសេរីក្នុងសកម្មភាព នយោបាយ វប្បធម៌ និង សង្គម។ ច្បាប់ទទួលស្គាល់ដោយគោរពនូវសិទ្ធិបុគ្គលចំពោះសេរីភាពក្នុងការជ្រើសរើសការចូលរួមក្នុងវិជ្ជាជីវៈក្នុងនាមជាដៃគូជាមួយភាគីម្ខាងទៀត សិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ និង សង្គម[41]។

សេរីភាពសហព័ទ្ធ មាន៣ធំៗ គឺ ៖

- សេរីភាពជ្រើសរើសវិជ្ជាជីវៈ ៖ ក្នុងឆ្នាំ ១៩២០ ស្ត្រីដែលចង់ប្រកបវិជ្ជាជីវៈ ត្រូវសុំការអនុញ្ញាតពីប្តី។ប៉ុន្តែចាប់ពីឆ្នាំ ១៩៨១ រហូតមកដល់បច្ចុប្បន្ន ស្ត្រីអាចប្រកបវិជ្ជាជីវៈ ដោយសេរីមិនចាំបាច់សុំការអនុញ្ញាតពីប្តីឡើយ។ នៅអឺរ៉ុប ស្ត្រីដែលប្រកបរបររកស៊ីផ្លូវភេទ គឺមិនត្រូវបានអនុញ្ញាតអោយរៀបការទេ លុះត្រាតែស្ត្រីនោះលះបង់វិជ្ជាជីវៈនោះ ហើយមកប្រកបវិជ្ជាជីវៈថ្មីផ្សេងទៀត ក្រៅពីមុខរបរនោះ។
- សេរីភាពជ្រើសរើសនយោបាយ ៖ ប្តី និង ប្រពន្ធ មានសិទ្ធិជ្រើសរើសបក្សនយោបាយ ដែលខ្លួនពេញចិត្ត ដោយមិនមានការបង្ខិតបង្ខំពីសហព័ទ្ធ ឬ ពីជនណាម្នាក់ឡើយ។ មានន័យថានៅពេលដែលសហព័ទ្ធណាម្នាក់ធ្វើការជ្រើសរើសបក្សនយោបាយណាមួយដែលខ្លួនស្រលាញ់ពេញចិត្ត ភាគីដែលជាសហព័ទ្ធម្ខាងទៀតមិនអាចមានសិទ្ធិជំទាស់ រារាំង នឹងការសម្រេចចិត្តនេះបានឡើយ ឬ មិនអាចធ្វើការបង្ខិតបង្ខំអោយប្តី ឬ ប្រពន្ធផ្លាស់ប្តូរការសម្រេចចិត្តផ្ទាល់ខ្លួនហើយងាកមកស្របតាមការជ្រើសរើសរបស់ខ្លួនបានឡើយ។ ត្រង់នេះចង់បង្ហាញថា ប្តីគ្មានសិទ្ធិបង្ខំប្រពន្ធ ហើយប្រពន្ធក៏គ្មានសិទ្ធិបង្ខំប្តីដែរ។ ព្រោះថាបុគ្គលម្នាក់ៗមានសិទ្ធិសេរីភាពពេញលេញក្នុងការជ្រើសរើសបក្សនយោបាយដែលខ្លួនពេញចិត្ត និងអាចមានសិទ្ធិចូលរួមសកម្មភាពនយោបាយតាមរយៈការបង្កើតគណបក្សនយោបាយជាដើម។
- សេរីភាពសាសនា៖ សាសនា គឺផ្ទេរតាមខ្សែលោហិត និង ធ្វើការផ្សព្វផ្សាយសាសនានោះឡើង ដើម្បីកុំអោយសាសនានោះសាបរលាប។ សាសនាព្រះពុទ្ធផ្ទេរពីញាតិ ទៅ ញាតិ មានន័យថាឪពុកម្តាយកាន់សាសនាអ្វីកូនក៏ត្រូវកាន់សាសនានោះដែរ។ ប្តីប្រពន្ធ មានសិទ្ធិពេញលេញជ្រើសរើសសាសនាតាមខ្លួនពេញចិត្ត។

[41] មាត្រា ៩៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## កថាខណ្ឌទី៤ សិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើទ្រព្យរួម

ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នឹងគ្នា ទោះប្រពន្ធ ឬ ប្ដីរកបានទ្រព្យសម្បត្តិ ប្រាក់កាសជាចំណូលក្នុងគ្រួសារច្រើន ឬ តិចជាងប្ដី ឬ ប្រពន្ធក៏ដោយ ទ្រព្យសម្បត្តិ និង ប្រាក់កាស ជាចំណូលទាំងនោះចាត់ទុកថា ជាទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធទាំងពីរ។ ក្នុងករណីដែលប្រពន្ធពុំបានចេញទៅរកស៊ី ប៉ុន្តែប្រពន្ធនោះមានតួនាទីជាមេផ្ទះថែរក្សាអប់រំកូន ការងារគេហកិច្ចទាំងនេះត្រូវចាត់ទុកស្មើនឹងការងារផលិតកម្មរបស់ប្ដី។

សិទ្ធិស្មើគ្នានេះមានន័យថា សហព័ទ្ធទាំងពីរនាក់ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិជាមួយគ្នា។ សហព័ទ្ធម្នាក់ៗអាចប្រើប្រាស់សំភារៈដែលទ្រព្យសម្បត្តិរួម និង អាចលក់ដូរ ឬ ធ្វើអំណោយបានលុះត្រាតែមានការព្រមព្រៀងពីសហព័ទ្ធម្នាក់អាចទាមទារឱ្យសហព័ទ្ធម្នាក់ទៀតយល់ព្រមពីវិធានការណ៍ចាំបាច់ ដើម្បីថែរក្សាទ្រព្យសម្បត្តិរួម ឬ រក្សាទុកតំលៃរបស់ទ្រព្យសម្បត្តិនោះ។

ប្ដីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម។ សហព័ទ្ធនីមួយៗ មានសិទ្ធិប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនបាន។ សហព័ទ្ធ មានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព។ សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួម ដោយសហការគ្នា[42]។ សហព័ទ្ធម្ខាងអាចទាមទារចំពោះភាគីម្ខាងទៀត ឱ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួមបាន។ បើការពិភាក្សាអំពីការគ្រប់គ្រង ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធមិនបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ ភាគីម្ខាងទៀតអាចទាមទារទៅតុលាការឱ្យធ្វើការចាត់ចែងចំពោះការគ្រប់គ្រង និង ប្រើប្រាស់ទ្រព្យសម្បត្តិរួមបាន។

ទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ មានបន្ទុកដោះស្រាយបញ្ហាដូចខាងក្រោមៈ

- ការផ្គត់ផ្គង់គ្រួសារ និង ចំណាយដើម្បីអប់រំ និង បណ្ដុះបណ្ដាលកូន
- បំណុល និង កាតព្វកិច្ចទាំងឡាយណា ដែលសហព័ទ្ធទាំងពីរបានព្រមព្រៀងគ្នាសំរេច ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។
- ការថែទាំ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរួម។

[42] មាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

# ផ្នែកទី៤ មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

ទោះបីជាមនុស្សពីរនាក់បានរៀបអាពាហ៍ពិពាហ៍នឹងគ្នារួចហើយ និង ចុះលិខិតអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឃុំឬសង្កាត់ ក៏ដោយ ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនានា ធ្វើឱ្យអាពាហ៍ពិពាហ៍កើតឡើងដោយមិនបំពេញលក្ខណច្បាប់ដែលនាំអោយមានផលវិបាកមួយចំនួនចំពោះអាពាហ៍ពិពាហ៍ពោលគឺ "អាពាហ៍ពិពាហ៍ទុកជាមោឃៈ" ឬ "ការលុបចោលអាពាហ៍ពិពាហ៍"។

## កថាខណ្ឌទី១ មោឃភាពនៃអាពាហ៍ពិពាហ៍

**មោឃភាព** គឺជាភាពពុំមានអានុភាពតាមផ្លូវច្បាប់នៃសកម្មភាពគតិយុត្តដែលផ្ទុយនឹងបញ្ញត្តិអំពីនីតិវិធីនៃបណ្តឹង។ ហើយជាទណ្ឌកម្មដែលប្រកាសដោយចៅក្រមលុបបំបាត់ចោលជាប្រតិសកម្ម នូវលិខិតគតិយុត្តិមិនបានបំពេញលក្ខខណ្ឌដែលច្បាប់កំណត់ ឬ សកម្មភាពណាមួយដែលផ្ទុយនីតិវិធីនៃច្បាប់[43]។ បើនិយាយអោយខ្លីមក"មោឃភាព" គឺជាការរំលាយចោលកិច្ចសន្យាតាមរយៈសាលក្រមតុលាការ។

មោឃភាពនៃអាពាហ៍ពិពាហ៍ មានន័យថា អាពាហ៍ពិពាហ៍នឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើគូភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និងមូលហេតុផ្សេងៗទៀត។ ហើយប្រសិនបើភាគី មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬ មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍។ ប៉ុន្តែប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍នេះ មិនត្រូវបានរារាំងដោយសារហេតុនោះឡើយ។

បើពិនិត្យក្នុងអត្ថន័យនៃក្រមរដ្ឋប្បវេណី ចំពោះមោឃភាពនៃអាពាហ៍ពិពាហ៍ មានពីរយ៉ាងទៀត គឺ "មោឃភាពដាច់ខាត" និង "មោឃភាពមិនដាច់ខាត"។

---

[43] សន្ទានុក្រមពាក្យច្បាប់ ឆ្នាំ ២០១២

## ១. មោឃភាពដាច់ខាត

មោឃភាពដាច់ខាត គឺសំដៅដល់រាល់អាពាហ៍ពិពាហ៍ទាំងឡាយណាដែលច្បាប់ហាមឃាត់តែម្តង។ កំហុសធ្ងន់ធ្ងរក្នុងការរៀបអាពាហ៍ពិពាហ៍ ដែលអាចស្ថិតក្នុងចំនុចនៃមោឃភាពដាច់ខាតនោះមានដូចតទៅ៖

### ១.១. ការភាន់ច្រឡំលើមនុស្ស

ក្នុងករណីដែលភាគីមានបំណងនឹងរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលម្នាក់ ដោយសារការភាន់ច្រឡំទៅលើមនុស្សដែលខ្លួនត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយនោះ តែបែរជាខ្លួនត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយ ដូចជាកូនភ្លោះដែលមានមុខមាត់ដូចគ្នា ឬ ភាន់ច្រឡំលើមនុស្សដែលមានឈ្មោះដូចគ្នាជាដើម។ ការភាន់ច្រឡំលើមនុស្សដែលជាកម្មវត្ថុសំខាន់នៃអាពាហ៍ពិពាហ៍បែបនេះ ភាគីអាចស្នើសុំរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍នោះបាន។

ប៉ុន្តែការភាន់ច្រឡំលើមនុស្សដែរ តែភាន់ច្រឡំលើអត្តចរិក ឬ អាកប្បកិរិយាមនុស្សនោះ ដោយគិតថា មនុស្សនោះចិត្តល្អ តែក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយបែរជាចិត្តមិនល្អវិញ ភាគីដែលភាន់ច្រឡំបែបនេះ មិនអាចសុំមោឃភាពនៃអាពាហ៍ពិពាហ៍បានទេ[44]។

### ១.២. ការបង្ខិតបង្ខំ

ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំពីភាគីម្ខាងទៀត ពីឪពុកម្តាយ ពីអាណាព្យាបាល ឬ ពីតតិយជនណាមួយឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្ស ដែលខ្លួនមិនមានបំនងនឹងរៀបអាពាហ៍ពិពាហ៍ជាមួយ ឬ គ្មានឆន្ទៈនឹងរៀបអាពាហ៍ពិពាហ៍ជាមួយ គឺជាការផ្ទុយពីស្មារតីនៃរដ្ឋធម្មនុញ្ញដែលចែងថា "អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយ ប្រពន្ធមួយ"[45]។ អាពាហ៍ពិពាហ៍ដែលបានធ្វើឡើងដោយភាគីគ្មានសេរីភាពក្នុងការជ្រើសរើសទាល់តែសោះបែបនេះបង្ហាញនូវករណីកម្រិតខ្ពស់និងកំហុសខ្លាំងនៃសកម្មភាពរំលោភរដ្ឋធម្មនុញ្ញធ្ងន់ធ្ងរដែលភាគីស្នើសុំមោឃភាពនៃអាពាហ៍ពិពាហ៍នោះបាន។

[44] មាត្រា ៩៥៨ វាក្យខណ្ឌ ក នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[45] មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ

## ២. មោឃភាពមិនដាច់ខាត

មោឃភាពមិនដាច់ខាត គឺសំដៅដល់រាល់អាពាហ៍ពិពាហ៍ទាំងឡាយណាដែលច្បាប់ហាមឃាត់ តែអាចកើតមានឡើងវិញពេលបានបំពេញគ្រប់លក្ខខណ្ឌ។

នៅក្នុងករណីភាគីដែលបានរៀបអាពាហ៍ពិពាហ៍ មិនបានបំពេញតាមទម្រង់ច្បាប់នូវនីតិវិធីមួយចំនួន នាំឱ្យអាពាហ៍ពិពាហ៍ អាចទុកជាមោឃៈបាន ឬ អាចបន្តអនុវត្តក៏បាន ហៅថា មោឃភាពមិនដាច់ខាតនៃអាពាហ៍ពិពាហ៍ ដោយសារតែកំហុសមិនមានលក្ខណធ្ងន់ធ្ងរ។ ប៉ុន្តែ ប្រការដែលក្រមរដ្ឋប្បវេណីថ្មីបានកំណត់លក្ខខណ្ឌខាងផ្លូវច្បាប់បន្តិចបន្តួចដូចជា ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ភាគីមិនបានជូនដំណឹងជាសាធារណៈ ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ជាដើម។ ហើយនាំឱ្យភាគីអាចស្នើសុំរំលាយអាពាហ៍ពិពាហ៍នោះចោល ទាំងអស់ហាក់ដូចជាមិនសមហេតុឡើយសម្រាប់ការអនុវត្តនៅប្រទេសកម្ពុជា[46]។

### ២.១. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ដោយមិនបានសុំច្បាប់ដើម្បីរៀបអាពាហ៍ពិពាហ៍ពីមេឃុំ ចៅសង្កាត់ គេអាចស្នើសុំលុបអាពាហ៍ពិពាហ៍ចោលបាន ឬ មិនស្នើសុំរំលាយចោលក៏បាន។ ប៉ុន្តែច្បាប់មិនបានកំណត់ច្បាស់ថា អ្នកណាជាអ្នកមានសិទ្ធិប្តឹងលុបចោលអាពាហ៍ពិពាហ៍ដែលមិនបានដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍នោះទេ។

### ២.២. ភាគីមិនបានជូនដំណឹងជាសាធារណៈ

ជនដែលសុំការអនុញ្ញាត ដើម្បីរៀបអាពាហ៍ពិពាហ៍ហើយ ប៉ុន្តែមិនជូនដំណឹងជាសាធារណៈនូវអាពាហ៍ពិពាហ៍ដូចការកំណត់របស់ច្បាប់ គឺរយៈពេល១០ថ្ងៃ នៅមុនពេលរៀបអាពាហ៍ពិពាហ៍ការខកខានប្រកាសដំណឹងអាពាហ៍ពិពាហ៍នេះ អាពាហ៍ពិពាហ៍នោះអាចលុបចោលបាន ឬ មិនស្នើសុំរំលាយចោលក៏បាន ដោយសារកំហុសបន្តិចបន្តួចដែលភាគីអាចស្នើសុំមោឃភាព ហើយមិនមែនជាមោឃភាពដាច់ខាតដែលត្រូវតែលុបចោលនោះទេ។

បើសិនជាការរំលោភលើនីតិវិធីនោះតិចតួច ប្រហែលជាមិនប៉ះពាល់ដល់ភាពពេញលក្ខណច្បាប់របស់អាពាហ៍ពិពាហ៍ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីទេ។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចាស់ បានតម្រូវឱ្យមានរយៈពេលរង់ចាំ ១០ថ្ងៃ ពីថ្ងៃបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

[46] មាត្រា ៩៥៨ វាក្យខណ្ឌ ខ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ដែលបានស្នើសុំរហូតដល់ថ្ងៃរៀបចំពិធីមង្គលការ ហើយប្រសិនបើមន្ត្រីអត្រានុកូលដ្ឋាន បានអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍មុនរយៈពេលរង់ចាំ១០ថ្ងៃដែលច្បាប់បានកំណត់នោះ[47]។ ក្រមរដ្ឋប្បវេណី មិនបានលើកច្បាស់លាស់ នូវផលប៉ះពាល់នៃការខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃនីតិវិធីដែលបានកើតឡើងខាងលើនេះទេ។ ប៉ុន្តែហាក់ដូចជាទំនងណាស់ថាអាពាហ៍ពិពាហ៍នោះនឹងត្រូវចាត់ទុកថាមានលក្ខណត្រឹមត្រូវតាមច្បាប់។ ដើម្បីជួយជំរុញដល់អាពាហ៍ពិពាហ៍ និងការធ្វើឱ្យមានការសង្ឃឹមទុករបស់សហព័ទ្ធឱ្យនៅមានតម្លៃតាមផ្លូវច្បាប់ការបំពេញជាដុំកំភួននូវលក្ខខណ្ឌតម្រូវនៃនីតិវិធីច្បាប់ជាទូទៅគឺជាការគ្រប់គ្រាន់នឹងធ្វើឱ្យអាពាហ៍ពិពាហ៍មួយមានលក្ខណត្រឹមត្រូវតាមច្បាប់។

### ២.៣. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍

ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ហើយ នឹងចាត់ទុកជាការត្រឹមត្រូវតាមលក្ខណច្បាប់បានលុះត្រាតែបុរស និង នារី បានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ខាងលំនៅឋានរបស់នារី ដោយមានសាក្សីពេញនីតិភាព២នាក់ផង។ ក្នុងករណីភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានទេ គេអាចស្នើសុំលុបអាពាហ៍ពិពាហ៍នោះបាន[48]។

### ២.៤. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍

នៅក្រោយពេលភាគីបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានរបស់នារី ហើយច្បាប់តម្រូវឱ្យភាគីត្រូវយកកិច្ចសន្យានេះត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍របស់មន្ត្រីអត្រានុកូលដ្ឋាន ហើយត្រូវចុះហត្ថលេខាដោយសាក្សីគ្រប់អាយុ២នាក់ផង។ ក្នុងករណីដែលភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍នេះទេ គេអាចស្នើសុំលុបអាពាហ៍ពិពាហ៍ចោលបាន។

## កថាខណ្ឌទី២ ការលុបចោលអាពាហ៍ពិពាហ៍

ការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងតាមនីតិវិធីច្បាប់ ឬ ស្របតាមបទបញ្ញត្តិផ្សេងៗទៀតដែលទាក់ទងទៅនឹងអាពាហ៍ពិពាហ៍នោះ។ ការរៀបអាពាហ៍ពិពាហ៍មិនត្រូវផ្ទុយទៅនឹងបទបញ្ញត្តិ

[47] មាត្រា១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

[48] ទំព័រ ៨៨,ឥន យឿន នីតិគ្រួសារ និង អាពាហ៍ពិពាហ៍ ២០១៣

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ឡើយ។ម្យ៉ាងវិញទៀត ក៏មិនត្រូវផ្ទុយនឹងបទបញ្ញត្តិផ្សេងៗទៀតដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ផងដែរ។ មិនដូច្នោះទេ អាពាហ៍ពិពាហ៍នោះនឹងត្រូវលុបចោល ឬ ក៏មោឃភាពចោល។

រីឯមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍វិញ ចែកចេញជាពីរប្រភេទ។ ប្រភេទទី១ គឺមូលហេតុនៃការលុបចោលដែលមានលក្ខណៈជាផលប្រយោជន៍សាធារណៈ ដូចជាការលុបចោលអាពាហ៍ពិពាហ៍នៃជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ ទ្វេពន្ធភាព អាពាហ៍ពិពាហ៍ដែលបានធ្វើឡើងក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត និង អាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិត។ រីឯប្រភេទទី២ គឺជាមូលហេតុដែលមានលក្ខណៈជាផលប្រយោជន៍ឯកជន ដូចជាការឆបោក និង គំរាម[49]។

## ១. អាពាហ៍ពិពាហ៍មិនគ្រប់អាយុ

អាពាហ៍ពិពាហ៍រវាងបុរសក្រោម១៨ឆ្នាំ និង នារីក្រោមអាយុ១៨ឆ្នាំ អាចលុបចោលបានដោយសារមានភាពផ្ទុយនឹងផលប្រយោជន៍សាធារណៈ។ ក៏ប៉ុន្តែក្នុងករណីដែលជនមិនគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានដល់នីតិភាពរៀបអាពាហ៍ពិពាហ៍ សិទ្ធិទាមទារលុបចោលនោះត្រូវរលត់។

ទោះបីជាជនដែលមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានដល់អាយុរៀបអាពាហ៍ពិពាហ៍ហើយក៏ដោយ ជននោះក៏នៅតែអាចទាមទារឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ នៅក្នុងអំឡុងពេល ៣ខែ ចាប់ពីពេលជននោះបានគ្រប់អាយុ លើកលែងតែក្នុងអំឡុងពេលនេះ ជននោះបានធ្វើសច្ចានុម័ត (ការសុខចិត្តយល់ព្រមទទួលស្គាល់ដែលមានអានុភាពប្រតិសកម្ម) លើអាពាហ៍ពិពាហ៍នោះ[50]។

ក៏ប៉ុន្តែ អាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន អាចទៅជាមានលក្ខណត្រឹមត្រូវតាមច្បាប់ ឬ បុរស និង ស្ត្រីនោះទទួលបានអត្តាធិនភាព។អ្នកដែលមានសិទ្ធិទាមទារឱ្យលុបចោលមានដូចជា ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ តំណាងអយ្យការ អាចប្តឹងទាមទារទៅតុលាការឱ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន។

[49] មាត្រា ៩៥៩ នៃសេចក្តីកំនត់ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[50] មាត្រា ៩៦១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ២. ការមានទ្វេពន្ធភាព

បុគ្គលដែលមានប្តី ឬ ប្រពន្ធហើយ ហើយចំណងអាពាហ៍ពិពាហ៍មុននៅមានសុពលភាពនៅឡើយ (មិនទាន់លែងលះគ្នាដាច់ស្រឡះ) ហើយបានរៀបអាពាហ៍ពិពាហ៍ប្តី ឬ ប្រពន្ធថ្មីមួយទៀត គេអាចស្នើលុបចោលអាពាហ៍ពិពាហ៍នោះបាន។

អ្នកដែលមានសិទ្ធិទាមទារអោយលុបចោលមានដូចជា ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ តំណាងអយ្យការអាចទាមទារទៅតុលាការឱ្យលុបចោលបាន។

បើសិនមានសហព័ទ្ធណាមួយ បានរៀបអាពាហ៍ពិពាហ៍រួចទៅហើយ ហើយអាពាហ៍ពិពាហ៍នោះមិនទាន់បានរំលាយជាផ្លូវការអាពាហ៍ពិពាហ៍ក្រោយអាចទុកជាមោឃៈ។ ប៉ុន្តែអាពាហ៍ពិពាហ៍ក្រោយអាចទៅជាពេញលក្ខណច្បាប់ បើអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយមុនមានការប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍[51]។

## ៣. ការលុបចោលអាពាហ៍ពិពាហ៍ធ្វើក្នុងអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ម្តងទៀត ក្នុងពេលមិនទាន់ផុតរយៈពេលត្រូវរង់ចាំចំនួន ១២០ថ្ងៃ បន្ទាប់ពីអាពាហ៍ពិពាហ៍លើកមុនត្រូវបានរំលាយ អាពាហ៍ពិពាហ៍នេះអាចត្រូវបានលុបចោលផងដែរ។ ក៏ប៉ុន្តែ សិទ្ធិទាមទារឱ្យលុបចោលត្រូវរលត់ ប្រសិនបើនារីដែលបានរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលហាមឃាត់ (រយៈពេល ១២០ថ្ងៃ)នោះ ហើយអំឡុងពេលនោះបានកន្លងផុតទៅដោយគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ក្នុងអំឡុងពេល ១២០ថ្ងៃ បើផុតរយៈពេលនោះ ហើយភាគីមិនបានស្នើសុំលុបចោល សិទ្ធិលុបនោះក៏ត្រូវរលត់ដែរ។ សិទ្ធិទាមទារឱ្យលុបចោលត្រូវរលត់ផងដែរ ក្នុងករណីនារីដែលបានរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលហាមឃាត់ ១២០ថ្ងៃ ហើយស្ត្រីនោះគ្មានផ្ទៃពោះ ឬ មានផ្ទៃពោះក្រោយពីបានរៀបអាពាហ៍ពិពាហ៍ថ្មីទៀត។ ដោយហេតុថា ស្ត្រីនោះគ្មានផ្ទៃពោះ ឬ មានផ្ទៃពោះក៏ដោយ បញ្ហាបិតុភាពលែងចោទជាបញ្ហាទៀត ហើយដោយសារតែទារកក្នុងគភ៌នោះ អាចបញ្ជាក់ថា ជាកូនរបស់ប្តីមុន ឬ ជាកូនរបស់ប្តីក្រោយហើយ។ នៅក្នុងករណីដែលអាពាហ៍ពិពាហ៍មុនត្រូវបានបញ្ចប់ដោយមរណភាព លែងលះ ឬ មោឃភាពនៃអាពាហ៍ពិពាហ៍នោះ បុរសម្នាក់អាចរៀបការជាថ្មីម្តងទៀតនៅពេលណាក៏បាន ក្រោយការបញ្ចប់អាពាហ៍ពិពាហ៍មុន។ បើសិនជាតុលាការបានសម្រេចឱ្យប្តីប្រពន្ធលែងលះតាមផ្លូវច្បាប់ រយៈពេលរង់ចាំត្រូវរាប់ចាប់តាំងពីថ្ងៃមានសាលក្រម ឬ មានសាលដីកាឱ្យនៅបែកគ្នា។ ច្បាប់តម្រូវឱ្យ

---

[51] មាត្រា ៩៦០ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ស្ត្រីរង់ចាំ ១២០ថ្ងៃ ដើម្បីកំណត់បិតុភាពនៃកូនដែលកើតមកនៅក្នុងឆ្នាំបន្ទាប់ពីការបញ្ចប់អាពាហ៍ពិពាហ៍លើកមុន។ អ្នកដែលមានសិទ្ធិទាមទារឱ្យលុបចោលមានដូចជា ភាគីនីមួយៗ សហព័ទ្ធរបស់ភាគី ឬ សហព័ទ្ធមុន ញាតិសន្តានរបស់ជននោះ តំណាងអយ្យការ អាចទាមទារទៅតុលាការឱ្យលុបចោលបាន[52]។

## ៤. ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិលោហិត

បុរស និង ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ដោយមានជាប់ចំណងញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតរហូតដល់ថ្នាក់ទី៣ ត្រូវហាមឃាត់។ **ឧទាហរណ៍** ការរៀបអាពាហ៍ពិពាហ៍រវាងឪពុកម្ដាយ និង កូនបង្កើត ឬ រវាងឪពុកម្ដាយចិញ្ចឹម និង កូនសុំហើយទោះបីក្នុងករណីមានការបញ្ចប់នូវទំនាក់ទំនងរវាងឪពុកម្ដាយនឹងកូនបង្កើត ឬ ការកាត់កាល់រវាងឪពុកម្ដាយចិញ្ចឹម និង កូនសុំហើយក៏ដោយ អាពាហ៍ពិពាហ៍ទាំងអស់នេះអាចត្រូវបានលុបចោលផងដែរ[53]។

អាពាហ៍ពិពាហ៍រវាងមនុស្សដែលជាប់សាច់ញាតិនឹងគ្នា ក្នុងថ្នាក់ណាមួយដែលច្បាប់ហាមឃាត់ អាពាហ៍ពិពាហ៍នោះត្រូវលុបចោល។ ច្បាប់មិនបានកម្រិតពេលវេលា សម្រាប់ឱ្យបុគ្គលដាក់ពាក្យប្ដឹងសុំលុបចោលនូវអាពាហ៍ពិពាហ៍ប្រភេទនោះទេ។ អ្នកដែលមានសិទ្ធិទាមទារឱ្យលុបចោលមានដូចជា ភាគីនីមួយៗ ញាតិសន្តានរបស់ជននោះ តំណាងអយ្យការអាចទាមទារទៅតុលាការឱ្យលុបចោលបាន។

## ៥. ការលុបចោលអាពាហ៍ពិពាហ៍រវាងញាតិពន្ធ

បុរស និង ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ហើយមានជាប់ចំណងញាតិពន្ធក្នុងខ្សែផ្ទាល់ ដែលក្រមរដ្ឋប្បវេណីបានហាមឃាត់មិនអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍នឹងគ្នា អាពាហ៍ពិពាហ៍នោះអាចលុបចោលបាន។ ទោះបីក្នុងករណីញាតិពន្ធខ្សែផ្ទាល់បានបញ្ចប់ទំនាក់ទំនងញាតិពន្ធហើយក៏ដោយ ច្បាប់មិនអនុញ្ញាតឱ្យញាតិពន្ធខ្សែផ្ទាល់នោះអាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាដែរ ហើយអាពាហ៍ពិពាហ៍នោះអាចលុបចោលបាន។

ការរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិពន្ធរហូតដល់ថ្នាក់ទី៣ ហើយទោះបីទំនាក់ទំនងរវាងញាតិពន្ធត្រូវបញ្ចប់ហើយក៏ដោយក៏អាពាហ៍ពិពាហ៍នោះអាចលុបចោលបាន[54]។

---

[52] មាត្រា ៩៦២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[53] មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[54] មាត្រា ៩៦០ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ៦. ការលុបចោលអាពាហ៍ពិពាហ៍ដោយការឆបោក

បុរស និង ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ដោយការឆបោករបស់ភាគីម្ខាងទៀត ឬ តតិយជន ដោយមធ្យោបាយធ្វើឱ្យភាគីម្ខាងទៀតធ្លាក់ទៅក្នុងការភាន់ច្រឡំ ភាគីដែលបានបង្ហាញឆន្ទៈដោយការឆបោកនោះ អាចស្នើទៅតុលាការដើម្បីលុបចោលអាពាហ៍ពិពាហ៍។

សិទ្ធិនៃការស្នើសុំលុបចោលអាពាហ៍ពិពាហ៍នោះ មានរយៈពេល៣ខែ ចាប់តាំងក្រោយថ្ងៃដែលភាគីបានរកឃើញការឆបោកនោះ។ បើផុតរយៈពេល៣ខែនោះ ភាគីមិនបានស្នើទៅតុលាការដើម្បីរំលាយអាពាហ៍ពិពាហ៍ ឬ ក្នុងអំឡុងពេលដែលបានរកឃើញអំពើឆបោកនោះ ភាគីបានធ្វើសច្ចានុម័ត ភាគីនោះរលត់សិទ្ធិ ដើម្បីប្តឹងលុបចោលអាពាហ៍ពិពាហ៍[55]។

## ៧. ការលុបចោលអាពាហ៍ពិពាហ៍ដោយការគំរាម

បុរស និង ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាដោយការគំរាមរបស់ភាគីម្ខាងទៀត ឬ របស់តតិយជន តាមគ្រប់មធ្យោបាយធ្វើឱ្យភាគីម្ខាងទៀតភិតភ័យ សុខចិត្តទទួលយកការរៀបអាពាហ៍ពិពាហ៍ដោយខុសពីឆន្ទៈរបស់ខ្លួន ភាគីដែលបានបង្ហាញឆន្ទៈដោយការគំរាមកំហែងនោះ អាចស្នើទៅតុលាការ ដើម្បីលុបចោលអាពាហ៍ពិពាហ៍បាន។

សិទ្ធិស្នើសុំលុបចោលអាពាហ៍ពិពាហ៍នេះ មានរយៈពេល៣ខែ ចាប់តាំងក្រោយថ្ងៃដែលភាគីបានគេចចេញពីការគំរាមនោះ។ បើផុតរយៈពេល៣ខែនោះ ភាគីមិនបានស្នើទៅតុលាការដើម្បីរំលាយអាពាហ៍ពិពាហ៍ ឬ ក្នុងអំឡុងពេលដែលបានគេចចេញពីការគំរាមនោះ ភាគីបានធ្វើសច្ចានុម័ត ភាគីនោះរលត់សិទ្ធិ ដើម្បីប្តឹងលុបចោលអាពាហ៍ពិពាហ៍[56]។

## ៨. អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ មានអានុភាពគតិយុត្តមួយចំនួន ដែលមានដូចជា៖

- ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលឡើយ ពោលគ្រាន់តែមានអានុភាពតែទៅលើអនាគតប៉ុណ្ណោះ។ មានន័យថា គេមិនអាចធ្វើអ្វីឱ្យមានលក្ខណដូចកាលពីមុនមិនទាន់រៀបអាពាហ៍ពិពាហ៍ ដូចជាភាពនៅកំលោះ ឬ ភាពនៅក្រមុំ ឬ ភាពមិនមាន កូន។ ចំពោះកូនដែលកើតមកត្រូវសន្មតថា ជាកូនរបស់ប្តីមុន[57]។

---

[55] មាត្រា ៩៦៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[56] មាត្រា ៩៦៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[57] មាត្រា ៩៦៤ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

- ភាគីដែលមិនបានដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើបានទទួលទ្រព្យសម្បត្តិដោយការរៀបអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិនោះត្រឹមកម្រិតនៃផលប្រយោជន៍ដែលបានទទួលទៅឱ្យភាគីម្ខាងទៀតវិញ[58]។

- ភាគីដែលបានដឹងអំពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ត្រូវសងនូវផលប្រយោជន៍ទាំងអស់ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ។ ប្រសិនបើ ភាគីម្ខាងទៀតសុចរិតវិញ ត្រូវទទួលខុសត្រូវចំពោះសំណងខូចខាតនោះ[59]។

- ក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល មានអានុភាពដល់ការកំណត់បិតុភាពរបស់ទារកផងដែរ។ ក្រមរដ្ឋប្បវេណីចែងកំណត់ថា៖
  ទី១ ទារកនៅក្នុងគភ៌របស់ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ត្រូវសន្មតថាជាកូនរបស់ប្តីនោះ។
  ទី២ ប្រសិនបើក្នុងករណីកូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ថ្ងៃគិតចាប់ពីថ្ងៃ ដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល៣០០គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល ៣០០ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ច្បាប់បានសន្មតថា ស្ត្រីនោះមានគភ៌ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ។
  ទី៣ ក្នុងករណីដែលកូននោះមិនអាចកំណត់ឪពុកបាន តាមចំណុចទី១ និង ទី២ ខាងលើនេះទេ កូននោះត្រូវច្បាប់សន្មតថា ជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ[60]។

- នៅក្រោយពេលដែលអាពាហ៍ពិពាហ៍ត្រូវបានលុបចោលទ្រព្យសម្បត្តិរបស់ភាគីទាំងពីរត្រូវយកមក ត្រូវធ្វើការបែងចែកគ្នាផងដែរ[61]។

[58] មាត្រា ៩៦៤ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[59] មាត្រា ៩៦៤ វាក្យខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[60] មាត្រា ៩៦៤ វាក្យខណ្ឌទី៤ និង មាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[61] មាត្រា ៩៦៤ វាក្យខណ្ឌទី៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

# ជំពូកទី៣
# ការលែងលះ

## ផ្នែកទី១ សញ្ញាណនៃការលែងលះ

ជាទូទៅអាពាហ៍ពិពាហ៍កើតចេញពីការស្ម័គ្រចិត្តរបស់មនុស្សពីរនាក់[62]។

ចំណងអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងដោយគោរពទៅតាមលក្ខខណ្ឌច្បាប់ត្រឹមត្រូវយ៉ាងណាវិញ ដើម្បីរំលាយនូវចំណងអាពាហ៍ពិពាហ៍មួយដែលបានកើតឡើង ក៏ត្រូវតែអាស្រ័យទៅលើលក្ខខណ្ឌច្បាប់ដែលតម្រូវផងដែរ ដែលស្ថានភាពនេះហើយដែលនាំឲ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ ។ ការលែងលះគ្នាត្រូវបានគេចាត់ទុកថា ជាសាលក្រម ឬ សាលដីការបស់តុលាការ ដែលប្រកាសថា ចំណងអាពាហ៍ពិពាហ៍ដែលបានគោរពទៅតាមផ្លូវច្បាប់ត្រូវបានបញ្ចប់ ដែលជាហេតុធ្វើឲ្យសហព័ទ្ធទាំងពីរលែងមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាតទៅទៀតហើយ ។

សាលក្រម ឬ សាលដីកា ជាសេចក្តីសម្រេចរបស់តុលាការដែលបានធ្វើការពិចារណាទៅលើភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងបញ្ហាដែលតុលាការត្រូវសម្រេចក្នុងរឿងវិវាទនៃអាពាហ៍ពិពាហ៍[63]។

### កថាខណ្ឌទី១ និយមន័យ

ការលែងលះ គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងប្តី និង ប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលមានការចុះសំបុត្រអាពាហ៍ពិអាហ៍នៅចំពោះមុខក្រុមប្រឹក្សាឃុំសង្កាត់បានត្រឹមត្រូវ ហើយអាស្រ័យដោយមានការព្រមព្រៀងពីសហព័ទ្ធទាំងពីរ[64]។ ការលែងលះគឺបណ្តាលមកពីការរស់នៅមិនចុះសម្រុងគ្នានូវប្រការណាមួយដែលមានមូលហេតុកំណត់ជាក់លាក់ដែលឈានដល់ការលែងលះ។ ក្រោយពីបានរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ហើយ ប្រសិនបើសហព័ទ្ធណាមួយយល់ឃើញថា ជីវិតអាពាហ៍ពិពាហ៍របស់ខ្លួន ពុំអាចបន្តរស់នៅជាមួយគ្នាតទៅទៀតបាន ដោយបានលើកឡើងនូវមូលហេតុ មកធ្វើការសំអាងយ៉ាងច្បាស់លាស់តាមបញ្ញត្តិដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[62] មាត្រា ៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

[63] ទំព័រ ១៨៥ ឥន យឿន, នីតិគ្រួសារ និង អាពាហ៍ពិពាហ៍ ២០១៣

[64] មាត្រា ៣៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

## កថាខណ្ឌទី២ ប្រភេទនៃការលែងលះ

សហព័ទ្ធ អាចធ្វើការលែងលះគ្នាដោយមានការព្រមព្រៀងពីសំណាក់ភាគីទាំងសងខាងដោយគ្មានកំហុសរបស់សហព័ទ្ធណាមួយឡើយ តែផ្ទុយទៅវិញ គឺជាការព្រមព្រៀងរវាងសហព័ទ្ធទាំងសងខាងដោយយល់ឃើញថាជីវិតអាពាហ៍ពិពាហ៍របស់ពួកគាត់មិនអាចបន្តទៅមុខទៀតបានឡើយ។

### ១. ការលែងលះជាឯកតោភាគី

ការលែងលះជាឯកតោភាគី គឺមានន័យថា សហព័ទ្ធម្ខាងអាចធ្វើការសម្រេចចិត្តសុំប្តឹងលែងលះពីសំណាក់ភាគីម្ខាងទៀតដោយឯកឯងបាន ដោយមិនចាំបាច់មានការព្រមព្រៀងពី សហព័ទ្ធដែលត្រូវប្តឹងនោះទេ ក្នុងករណីដែលសហព័ទ្ធនោះបានរកឃើញនូវកំហុសរបស់សហព័ទ្ធ ឬ សហព័ទ្ធណាម្ខាងបានប្រព្រឹត្តិនូវអំពើណាមួយមិនគប្បីទៅលើសហព័ទ្ធម្ខាងទៀតជាដើម ។ ដែលជាហេតុនាំឲ្យ សហព័ទ្ធដែលជាជនរងគ្រោះដាក់ពាក្យបណ្តឹងសុំលែងលះ ដើម្បីស្នើសុំឲ្យតុលាការរំលាយចំណងអាពាហ៍ពិពាហ៍ទៅតាមផ្លូវច្បាប់ ។ បណ្តឹងនេះកើតឡើងពីសហព័ទ្ធម្ខាង ជាដើមបណ្តឹងក្នុងការទាមទារលែងលះ ។

### ២. ការលែងលះជាទ្វេភាគី

ការរៀបអាពាហ៍ពិពាហ៍ថ្មីត្បិតតែគឺជាការព្រមព្រៀងរវាងបុរស និង ស្ត្រីដែលសច្ចាថានឹងរួមរស់ក្នុងជីវិតជាស្វាមីភរិយាដែលប្រកបទៅដោយសុភមង្គលក៏ពិតមែន ប៉ុន្តែការសច្ចាស្បថស្បែនោះក៏នឹងមិនអាចបិតថេរជានិរន្តដែរ ។ សហព័ទ្ធមួយចំនួនដែលបានរួមរស់ជាមួយគ្នា ខ្លះក៏ទទួលបាននូវភាពសុខដុមរមនា ប៉ុន្តែសហព័ទ្ធខ្លះទៀតមានភាពរកាំរកូសជាច្រើននៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ វាអាចបណ្តាលមកពីការមិនចុះសម្រុងនឹងគ្នា ការមិនចេះអធ្យាស្រ័យគ្នាទៅវិញទៅមកមានចិត្តគំនិតផ្ទុយគ្នា ដែលជាហេតុធ្វើឲ្យអ្នកទាំងពីរ មានផលវិបាកក្នុងការរស់នៅជាមួយគ្នាបន្តទៀត ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺការលែងលះជាទ្វេភាគី គឺមានភាពល្អប្រសើរដោយហេតុថា ការសម្រេចចិត្តថានឹងធ្វើការលែងលះ មិនមែនជាឆន្ទៈរបស់សហព័ទ្ធណាមួយឡើយ តែផ្ទុយទៅវិញគឺសហព័ទ្ធទាំងពីរ មានឆន្ទៈដូចគ្នាក្នុងការលែងលះ ដោយអ្នកទាំងពីរ មានការព្រមព្រៀងទាំងសងខាង ដោយមិនមានការបង្ខំពីសហព័ទ្ធណាម្ខាងទៅសហព័ទ្ធណាមួយទៀត អោយធ្វើការយល់ព្រមលែងលះនោះទេ ។ ពោលគឺ ការលែងលះជាលក្ខណៈទ្វេភាគីនេះ ជាការសម្រេចចិត្តក្នុងការលែងលះ គឺស្ថិតនៅលើសហព័ទ្ធទាំងសងខាងផ្ទាល់តែម្តង ប្រសិនបើសហព័ទ្ធទាំងពីរ យល់ឃើញថាចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរ ត្រូវតែបញ្ចប់ដោយមិនអាចបដិទានបានឡើងវិញនោះ

សហព័ទ្ធទាំងសងខាងអាចសម្រេចចិត្តធ្វើការលែងលះបាន[65] ។ បន្ទាប់ពីធ្វើការសម្រេចចិត្តដ៏ជាក់លាក់មួយហើយ សហព័ទ្ធដែលជាភាគីនៃអាពាហ៍ពិពាហ៍ អាចធ្វើការដាក់ពាក្យបណ្ដឹងលែងលះទៅតុលាការបាន ក្នុងករណីដែលភាគីទាំងសងខាងពិតជាបានព្រមព្រៀងគ្នាអំពីការលែងលះនោះមែន ។ ប៉ុន្តែតុលាការអាចឲ្យលែងលះគ្នាបាន ក្រោយយល់ឃើញថា ភាគីទាំងសងខាងមាន ឆន្ទៈពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ។ ជាការពិតណាស់ ទោះបីជាសហព័ទ្ធទាំងពីរបាននិយាយថាខ្លួនមានការព្រមព្រៀងគ្នាក្នុងការលែងលះក៏ពិតមែន ប៉ុន្តែវាមិនអាចយកជាការភ្លាមៗក្នុងការផ្ដាច់ការចំណងអាពាហ៍ពិពាហ៍នោះទេ តុលាការនឹងធ្វើការស្វែងយល់អំពីសហព័ទ្ធទាំងពីរយ៉ាងម៉ត់ចត់ ប្រសិនបើតុលាការយល់ឃើញថា សហព័ទ្ធទាំងពីរ ពិតជាមានឆន្ទៈស្របគ្នា ក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ពិតប្រាកដមែន នោះតុលាការនឹងអនុញ្ញាតឲ្យធ្វើការរំលាយចំណងអាពាហ៍ពិពាហ៍នោះបាន ។

ផ្ទុយទៅវិញ ទោះបីជាក្នុងករណីណាក៏ដោយ ទោះបីជាមានការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរក្ដី ប្រសិនបើតុលាការយល់ឃើញថា ការលែងលះគ្នានោះបណ្ដាលឲ្យ ការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូនក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលមិនអាចទ្រាំទ្របានតុលាការអាចច្រានចោលការទាមទារលែងលះគ្នាដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន ។

## ផ្នែកទី២ មូលហេតុ និង នីតិវិធីនៃការលែងលះ

### កថាខណ្ឌទី១ មូលហេតុនៃការលែងលះ

ក្រមរដ្ឋប្បវេណីថ្មីរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានកំណត់អំពីគោលការណ៍ នៃការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារវាងបុរស និង នារី ឬសិទ្ធិលើទ្រព្យសម្បត្តិជាដើម[66] ។ នេះសបញ្ជាក់ឲ្យឃើញថា ក្រមបានគោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គលដែលរួមមានដូចជា ការរៀបអាពាហ៍ពិពាហ៍ ឬ ការលែងលះ គឺសុទ្ធសឹងតែជាការព្រមព្រៀងដែលកើតចេញពីឆន្ទៈរបស់បុគ្គលម្នាក់ៗដោយមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ។ ជាការពិតណាស់ ក្រមរដ្ឋប្បវេណីរបស់យើងបានផ្ដល់សិទ្ធិសេរីភាពពេញលេញដល់បុរសនិងនារីអោយរៀបអាពាហ៍ពិពាហ៍បានប្រសិនបើពួកគេមានឆន្ទៈដូចគ្នាក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍មួយ ប៉ុន្តែអាពាហ៍ពិពាហ៍នោះត្រូវតែមិនមានការបង្ខិតបង្ខំឡើយ ។ ទោះបីជាចំណងអាពាហ៍ពិពាហ៍មួយដែលកើតឡើងដោយផុសចេញពី

[65] មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[66] មាត្រា ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ក្រអៅបេះដូងរបស់ភាគីទាំងសងខាងក៏ដោយ ក៏ពេលខ្លះចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរ នឹងមានការរកាំរកូស ដែលជាហេតុនាំឲ្យមានការបែកបាក់ ហើយការបែកបាក់ ប្រេះស្រាំទាំងនោះ អាចកើតឡើងដោយមូលហេតុជាច្រើនយ៉ាង ដែលបញ្ហាខ្លះនាំឲ្យទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ពួកគាត់ត្រូវបែកបាក់ដោយគ្មានសង្ឃឹម នឹងអាចបដិទានបានឡើយ ។

ដូច្នេះហើយបានជាក្រុមអនុគ្រោះផងដែរ ក្នុងករណីដែលសហាព័ទ្ធមួយត្រូវបានសហាព័ទ្ធម្ខាងទៀតរំលោភបំពានយ៉ាងធ្ងន់ធ្ងរទាំងផ្លូវកាយ និង ផ្លូវចិត្ត ជាហេតុនាំឲ្យពួកគាត់ទាំងពីរនាក់មិនអាចបន្តនូវចំណងអាពាហ៍ពិពាហ៍តទៅទៀតបាន ។ ដូចនេះ ការលែងលះអាចសម្រេចទៅបានលុះត្រាតែមានមូលហេតុណាមួយច្បាស់លាស់ដូចដែលមានចែងក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាដែលមានអត្ថន័យដូចតទៅ :

ប្ដី ឬ ប្រពន្ធ អាចដាក់ពាក្យបណ្ដឹងលែងលះគ្នាបាន តែក្នុងករណីដែលបានកំណត់ដូចខាងក្រោម :

- បើបានប្រព្រឹត្តអំពើផិតទៅលើសហាព័ទ្ធ
- បើបានបោះបង់សហាព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ
- បើមិនដឹងច្បាស់ថាសហាព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាងមួយឆ្នាំ
- បើសហាព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេលជាងមួយឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍
- ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទាន[67]ឡើងវិញបាន ។

## កថាខណ្ឌទី២ នីតិវិធីនៃការលែងលះ

### ១. បណ្ដឹងនៃការលែងលះ

ការលែងលះដែលស្របច្បាប់ គឺត្រូវតែទទួលស្គាល់បណ្ដឹងនៃការលែងលះ ចាប់ផ្ដើមនៅពេលដែលសហាព័ទ្ធម្ខាង ឬ សហាព័ទ្ធទាំងពីរបានដាក់ពាក្យបណ្ដឹងសុំលែងលះទៅតុលាការ ។ បណ្ដឹង គឺជាឯកសារផ្លូវច្បាប់ដែលភាគីមួយដាក់ដើម្បីជំទាស់នឹងភាគីមួយទៀតដោយបង្ហាញនូវការកើតទុក្ខមិនសុខចិត្តដើម្បីសុំឲ្យប្រព័ន្ធច្បាប់ជួយធ្វើការអន្តរាគមន៍ និង សម្រេចឲ្យបានសមរម្យនឹងត្រឹមត្រូវ ហើយការដាក់ពាក្យបណ្ដឹងសុំលែងលះនេះត្រូវដាក់តាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់ក៏បាន ឬ អាចដាក់បណ្ដឹងទៅតុលាការដោយផ្ទាល់ក៏បាន[68] ។

[67] បដិទាន: ការស្ដារឡើងវិញនូវស្ថានភាពដើម ឬ ការប្រគល់ត្រលប់វិញ (សន្ទានុក្រមផ្នែករដ្ឋប្បវេណី)

[68] មាត្រា ៩១ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ

### ១.១. អ្នកមានសិទ្ធិប្ដឹងលែងលះ

រឿងក្ដីនៃបណ្ដឹងលែងលះ គឺមានតែសហព័ទ្ធទាំងពីរតែប៉ុណ្ណោះ (ប្ដី និង ប្រពន្ធ) ដែលជាភាគីនៃបណ្ដឹង[69] ។ បុគ្គលដែលមិនមែនជាសហព័ទ្ធ គឺមិនអាចក្លាយទៅជាភាគីនៃបណ្ដឹងបានឡើយទោះបីជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ។

ភាគីនៃបណ្ដឹង គឺជាជនដែលទាមទារឲ្យតុលាការដោះស្រាយវិវាទរបស់ខ្លួនដោយការសម្រេចចេញនូវសាលក្រម ឬ សាលដីកា ។ ដោយសារតែភាគី គឺជាប្រធាននៃនីតិវិធីបណ្ដឹងរដ្ឋប្បវេណី ហេតុនេះភាគីទាំងសងខាងតម្រូវឲ្យចូលរួមក្នុងនីតិវិធី ដើម្បីចូលរួមស្ដាប់ និងធ្វើការអះអាង ពិនិត្យ និង ដាក់ភស្តុតាងធ្វើការតទល់រួចចេញសាលក្រម ។

ដូចនេះសហព័ទ្ធដែលជាភាគី ត្រូវទទួលស្គាល់សិទ្ធិមូលដ្ឋាននៃនីតិវិធី ដែលមានសិទ្ធិទាមទារឲ្យសាកសួរជាដើម ។ ហើយភាគីនោះដែរ គឺជាចំណុចដែលត្រូវសរសេរបញ្ជាក់នៅក្នុងពាក្យបណ្ដឹងផងដែរ ។ ប្រសិនបើ ក្នុងករណីដែលសហព័ទ្ធចង់សុំប្ដឹងធ្វើការលែងលះ តែការលែងលះគ្នានោះនឹងបណ្ដាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូនក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយ ។ ដូចនេះ ក្នុងស្ថានភាពបែបនេះ សហព័ទ្ធនោះពុំមានសិទ្ធិក្នុងការសុំប្ដឹងលែងលះនោះបានឡើយ ។

### ១.២. ទម្រង់នៃបណ្ដឹងលែងលះ

ទម្រង់នៃបណ្ដឹង គឺជាចំណុចទាំងឡាយណាដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង។ ភាពត្រឹមត្រូវនៃពាក្យបណ្ដឹង គឺធ្វើឡើងជាលាយលក្ខណ៍អក្សរ បានសេចក្ដីថា បណ្ដឹងត្រូវសរសេរឡើងផ្អែកទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីដែលគេហៅថា ជាចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង ។

ដើមចោទត្រូវសរសេរបញ្ជាក់អំពីចំណុចសំខាន់នៅក្នុងពាក្យបណ្ដឹងរួមមាន ឈ្មោះ ឬ នាមករណ៍ និង អាស័យដ្ឋានរបស់ភាគីដែលជាសហព័ទ្ធ ខ្លឹមសារនៃសាលក្រមដែលសហព័ទ្ធដើមចោទទាមទារឲ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ។ ជាងនេះទៅទៀត សហព័ទ្ធដើមចោទ គប្បីសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារសុំបណ្ដឹងលែងលះ និងតាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង សហព័ទ្ធដើមបណ្ដឹងគប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង[70] ។

---

[69] មាត្រា ៣២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[70] មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

នៅក្នុងពាក្យបណ្តឹង ប្រសិនបើសហព័ទ្ធជាដើមចោទចង់ទាមទារឲ្យតុលាការកាត់សេចក្តីបែបណា ដើមចោទគួរតែបញ្ជាក់ឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃបណ្តឹងដែលខ្លួនទាមទារ ។

**ឧទាហរណ៍:** សុំប្តឹងទាមទារលែងលះជាមួយភាគី "A" ដោយផ្តាច់ចំណងអាពាហ៍ពិពាហ៍ និង បែងចែកទ្រព្យជា ២ ចំណែកស្មើគ្នា ។ ការសរសេរបញ្ជាក់អំពីបំណងដែលខ្លួនចង់ឲ្យតុលាការចេញយ៉ាងច្បាស់លាស់បែបនេះ វាមានភាពងាយស្រួល ហើយក៏ជាវិធីមួយក្នុងការបង្ហាញពីឆន្ទៈរបស់ខ្លួននូវអ្វីដែលខ្លួនចង់បាន ប៉ុន្តែការសម្រេចតាម ឬ មិនសម្រេចតាមស្ថិតនៅក្រោមការត្រិះរិះពិចារណារបស់ចៅក្រម ។

សរុបមក ពាក្យបណ្តឹងគប្បីសរសេរឲ្យបានច្បាស់លាស់ លម្អិតឲ្យបានគ្រប់ចំណុច និងមានភាពងាយស្រួលយល់ ហើយអង្គហេតុទៀតសោត មិនត្រូវសរសេរច្របូកច្របល់ឡើយ ។

## ២. សមត្ថកិច្ចក្រុមប្រឹក្សាឃុំ-សង្កាត់

ដោយយោងតាមមាត្រា ៩៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់ថា ភាគីអាចដាក់ពាក្យបណ្តឹងសុំលែងលះ ទៅក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋាន ឬ ទីសំណាក់របស់សហព័ទ្ធចុងចម្លើយដែលមានទំនាក់ទំនងឋានៈបុគ្គល ដែលពាក់ព័ន្ធនឹងបណ្តឹងនោះ[71] ឬ លំនៅឋាននាពេលភាគីនោះទទួលមរណភាព[72] ។ នៅត្រង់ចំណុចខាងលើនេះចង់បញ្ជាក់ឲ្យឃើញនៅក្នុងករណីដែលសហព័ទ្ធជាចុងចម្លើយពុំមានទីសំណាក់ ឬ ទីសំណាក់ពុំច្បាស់លាស់ សមត្ថកិច្ចត្រូវកំណត់ទៅតាមលំនៅចុងក្រោយរបស់សហព័ទ្ធ ។

នៅពេលដែលក្រុមប្រឹក្សាឃុំសង្កាត់ទទួលបានពាក្យសុំលែងលះគ្នាហើយ ក្រុមប្រឹក្សាឃុំ-សង្កាត់អាចធ្វើការបញ្ចុះបញ្ចូលឲ្យសះជាគ្នាបានក្នុងកំឡុងពេល ១៥ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនោះ[73] ។ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីដែលមានតួនាទីក្នុងការទទួលបន្ទុកគឺជា មេឃុំ-ចៅសង្កាត់ ។ មេឃុំ ឬ ចៅសង្កាត់ត្រូវធ្វើការជូនដំណឹងទៅដល់សហព័ទ្ធទាំងសងខាង ដើម្បីចូលខ្លួនមកធ្វើការរៀបរាប់អំពីមូលហេតុដែលខ្លួនប្តឹងសុំលែងលះ ឬ វិបត្តិនានាដែលនាំឲ្យចំណងអាពាហ៍ពិពាហ៍ត្រូវបញ្ចប់ ។ នៅក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវប្រើប្រាស់វិធីសាស្ត្ររបស់ខ្លួនដើម្បីការផ្សះផ្សាបញ្ចុះបញ្ចូលឲ្យសហព័ទ្ធសះជាគ្នាឡើងវិញ។

[71] មាត្រា ៩៨២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[72] មាត្រា ១០ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[73] មាត្រា ៩៨២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ប្រសិនបើ ការផ្សះផ្សានោះបានសម្រេចដោយអ្នកទាំងពីរត្រូវរូវគ្នាវិញនោះ ពាក្យបណ្ដឹងនោះពុំចាំបាច់បញ្ជូនទៅតុលាការនោះទេ ពីព្រោះបញ្ហានោះត្រូវបានដោះស្រាយចប់សព្វគ្រប់នៅត្រឹមក្រុមប្រឹក្សាឃុំ-សង្កាត់ហើយនោះ សហព័ទ្ធនៃបណ្ដឹងត្រូវដកបណ្ដឹងនោះចេញវិញ ។

ប៉ុន្តែ ប្រសិនបើក្រុមប្រឹក្សាឃុំ-សង្កាត់មិនអាចបញ្ចុះបញ្ចូលឲ្យសះជាគ្នាបានទេ ទោះបីជាខិតខំប្រឹងប្រែង បញ្ចុះបញ្ចូលជាច្រើនលើកច្រើនសារ ក៏នៅតែមិនព្រមសះជានោះ នោះក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបញ្ជូនពាក្យបណ្ដឹងនោះទៅតុលាការជាបន្ទាន់[74] ។ ក្រុមប្រឹក្សាឃុំ-សង្កាត់មានសមត្ថកិច្ចត្រឹមធ្វើការបញ្ចុះបញ្ចូលឲ្យសះជាគ្នាតែប៉ុណ្ណោះ ព្រោះគ្មានសិទ្ធិអំណាចសម្រេចក្នុងរឿងលែងលះឡើយ ។

## ៣. សមត្ថកិច្ចសាលាដំបូងរាជធានី-ខេត្ត

ដូចដែលបានបកស្រាយខាងលើ នៅពេលដែលពាក្យសុំលែងលះ បានដាក់ជូនទៅក្រុមប្រឹក្សាឃុំ-សង្កាត់ហើយ នៅពេលដែលក្រុមប្រឹក្សាឃុំ-សង្កាត់ បានខិតខំប្រើវិធីសាស្ត្រយ៉ាងណាដើម្បីធ្វើការបញ្ចុះបញ្ចូលឲ្យសហព័ទ្ធទាំងពីរសះជាគ្នា ប៉ុន្តែបើមិនបានជោគជ័យនោះ ពាក្យបណ្ដឹងរបស់សហព័ទ្ធនឹងត្រូវបញ្ជូនមកសាលាដំបូងរាជធានី-ខេត្ត ខាងលំនៅឋាន ឬ ទីសំណាក់របស់សហព័ទ្ធចុងចម្លើយ[75] ។ ប្រសិនបើពាក្យបណ្ដឹងលែងលះរបស់សហព័ទ្ធដើមចោទ មិនបានឆ្លងកាត់ការផ្សះផ្សានៅក្រុមប្រឹក្សាឃុំ-សង្កាត់ក៏ដោយ ក៏សហព័ទ្ធនោះអាចដាក់ពាក្យបណ្ដឹងសុំប្ដឹងលែងលះរបស់ខ្លួនទៅកាន់តុលាការដោយផ្ទាល់តែម្ដងក៏បាន ។ ក្រោយទទួលបានពាក្យបណ្ដឹង តុលាការត្រូវចាត់តាំងសមាសភាពចៅក្រមដើម្បីបន្ទុកលើរឿងក្ដីនេះ នឹងធ្វើការស្រាវជ្រាវ និង ដោះស្រាយទៅតាមនីតិវិធីច្បាប់ជាបន្តបន្ទាប់ដូចដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាអាទិ៍ ។

ទោះជាយ៉ាងណាក៏ដោយ មុននឹងឈានដល់ការដោះស្រាយតាមនីតិវិធីច្បាប់ ចៅក្រមដែលទទួលបន្ទុកត្រូវធ្វើការផ្សះផ្សាជាមុនសិន ដែលការផ្សះផ្សានោះសម្រុះសម្រួលនោះត្រូវធ្វើឡើងចំនួន ២ដងយ៉ាងតិច ទោះបីជាភាគីម្ខាងទៀតនៅតែចចេសទាមទារលែងលះក៏ដោយ ។ ក្នុងករណីពិសេសដែលតុលាការរកឃើញថា សហព័ទ្ធមានកូនជាអនីតិជន ឬ សហព័ទ្ធណាមួយកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ។

---

[74] មាត្រា ៩៨២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[75] មាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

### ៣.១. ការដាក់ពាក្យបណ្តឹង

ពាក្យបណ្តឹងសុំលែងលះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយពាក្យបណ្តឹងនោះទៀតសោត ត្រូវតែធ្វើទៅតាមមាត្រាបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។ ការិយាល័យក្រឡាបញ្ជីនៃតុលាការខាងលំនៅឋានចុងចម្លើយ គឺជាកន្លែងដែលត្រូវដាក់ពាក្យបណ្តឹងសុំលែងលះ ។ បន្ទាប់ពីបណ្តឹងនោះត្រូវបានបោះត្រា និង ចុះកាលបរិច្ឆេទនៃការដាក់ពាក្យបណ្តឹងនោះ ព្រមទាំងចុះលេខរៀងក្នុងសៀវភៅបណ្តឹង និង លើពាក្យបណ្តឹងរបស់សហព័ទ្ធដោយយកក្របសំណុំរឿងមកគៀបសំណុំរឿងនោះ ។ នៅក្នុងពាក្យបណ្តឹងលែងលះ សហព័ទ្ធដែលដាក់ពាក្យបណ្តឹងហៅថា ដើមចោទ និងសហព័ទ្ធដែលត្រូវបានគេប្តឹងហៅថា ចុងចម្លើយ[76] ។

អ្នកដែលមានសិទ្ធិក្នុងការធ្វើបណ្តឹងលែងលះ គឺមានតែសហព័ទ្ធទាំងសងខាងតែប៉ុណ្ណោះដែលមានសិទ្ធិ ចំណែកឯតតិយជនវិញពុំអាចធ្វើបណ្តឹង ឬ ធ្វើជាតំណាងឲ្យភាគីណាមួយដូចបណ្តឹងរដ្ឋប្បវេណីដទៃទៀតបានទេ ប៉ុន្តែសហព័ទ្ធអាចពឹងពាក់មេធាវីឲ្យធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ខ្លួនបាន ។ សំបុត្រអាពាហ៍ពិពាហ៍ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរវាងសហព័ទ្ធទាំងពីរ ត្រូវតែភ្ជាប់មកជាមួយនឹងពាក្យបណ្តឹងលែងលះ ។

### ៣.២. ការពិនិត្យពាក្យបណ្តឹង

ការពិនិត្យពាក្យបណ្តឹង គឺជាការពិនិត្យស្តីពីភាពស្រប ឬ មិនស្របនឹងលក្ខខណ្ឌនៃទម្រង់តែប៉ុណ្ណោះ ។ ប្រសិនបើចៅក្រមពិនិត្យឃើញថា ពាក្យបណ្តឹងនោះបានគោរពលក្ខខណ្ឌត្រឹមត្រូវ អង្គហេតុច្បាស់លាស់ មានបញ្ជាក់ពីចំណុចសំខាន់ៗដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹងរួចរាល់អស់ហើយ ចៅក្រមទទួលពាក្យបណ្តឹងលែងលះមិនចាំបាច់បង្គាប់ឲ្យភាគីដែលជាសហព័ទ្ធដើមចោទ ធ្វើការកែតម្រូវនៅក្នុងពាក្យបណ្តឹងរបស់ខ្លួនឡើយ ។ ផ្ទុយទៅវិញបើ ចៅក្រមរកឃើញថាមានភាពខ្វះចន្លោះ ដូចជាករណី ពន្ធដាក់ពាក្យសុំមិនត្រូវបានបង់ អង្គហេតុនៃការទាមទារមិនច្បាស់លាស់ ឬ ដោយកំហុសចៅក្រមដែលទទួពាក្យបណ្តឹងលែងលះ ត្រូវបង្គាប់ឲ្យសហព័ទ្ធនៃដើមចោទធ្វើការកែតម្រូវពាក្យបណ្តឹងរបស់ខ្លួនជាបន្ទាន់ ដោយការបង្គាប់ឲ្យកែតម្រូវដោយកំណត់នូវអំឡុងពេលសមរម្យដើម្បីធ្វើការកែតម្រូវ[77] ។
ប្រសិនបើ សហព័ទ្ធដើមចោទមិនបានធ្វើការកែតម្រូវក្នុងអំឡុងពេលនៃការកំណត់ទេ តុលាការត្រូវលើកចោលបណ្តឹងលែងលះដោយដីការសម្រេច[78] ។

---

[76] មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[77] មាត្រា ៧៨ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[78] មាត្រា ៧៨ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

### ៣.៣. ការទទួលពាក្យបណ្តឹង

ក្រឡាបញ្ជីជាអ្នកទទួលបន្ទុកក្នុងការទទួលពាក្យបណ្តឹង ដែលដើមចោទបានដាក់ទៅតុលាការ ហើយក្រឡាបញ្ជីត្រូវតែអនុវត្ត តាមជំហានដូចខាងក្រោមនេះ ៖

- វាយត្រាលើពាក្យបណ្តឹងដែលបានទទួលនោះ រួចធ្វើការចុះថ្ងៃ ខែ ឆ្នាំដែលបានទទួលពាក្យបណ្តឹង
- បន្ទាប់មកចុះលេខរៀងនៅក្នុងសៀវភៅបណ្តឹង និងលើពាក្យបណ្តឹងផងដែរ
- បន្ទាប់មកទៀត ក្រឡាបញ្ជីត្រូវយកក្របសំបុត្រសំណុំរឿងមកត្រៀមសំណុំរឿងនោះ រួចហើយបញ្ជូនសំណុំរឿងទៅតុលាការ

ដើម្បីកុំឲ្យជួបប្រទះភាពខ្វះខាតនូវចំណុច ដែលបានកំណត់តាមបញ្ញាត្តិច្បាប់ ដែលបានតម្រូវឲ្យសរសេរនៅក្នុងពាក្យបណ្តឹង ក្រឡាបញ្ជីត្រូវបានអនុញ្ញាតឲ្យធ្វើជាអ្នកផ្តលយោបល់ចំពោះបញ្ហានៃការខ្វះខាតនោះ ដែលចំណុចខ្វះខាតទាំងនោះមានដូចជា ឈ្មោះរបស់គូភាគ ឬអាសយដ្ឋានមិនច្បាស់លាស់ ដែលផ្ទុយនឹងកថាខណ្ឌទី២ នៃមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។
ជាកំណត់សម្គាល់ ក្រឡាបញ្ជីអាចត្រឹមតែជាអ្នកផ្តល់យោបល់ ចំពោះភាពខ្វះចន្លោះតែប៉ុណ្ណោះ គាត់ពុំមានសិទ្ធិខាងផ្លូវច្បាប់ក្នុងការពិនិត្យពាក្យបណ្តឹងឡើយ ។ ពោលគឺ ដោយសារតែក្រឡាបញ្ជីជាបុគ្គលមួយរូបដែលមានវិជ្ជាជីវៈខាងផ្លូវច្បាប់ដែរ ដូចនេះគាត់អាចសំរួលដល់អ្នកដែលដាក់ពាក្យបណ្តឹងដោយផ្តល់ជាយោបល់ ឬ ដំបូន្មានខ្លះៗចំពោះពាក្យបណ្តឹងនោះបាន ដោយធ្វើការបង្ហាញនូវហេតុផលសមរម្យដូចជា ប្រាប់នូវកង្វះខាតថាត្រង់ចំណុចនេះខ្វះ ប្រសិនណាបើដាក់ពាក្យបណ្តឹងទាំងអញ្ចឹងអាចនឹងមានការយឺតយ៉ាវជាដើម ។

### ៣.៤. ការបញ្ជូនពាក្យបណ្តឹង

នៅក្នុងដំណាក់កាលនេះ តុលាការបានធ្វើការពិនិត្យបណ្តឹងនៃការលែងលះរួចរាល់ហើយ តែប្រសិនបើតុលាការយល់ឃើញថាបណ្តឹងនោះបានបំពេញតាមលក្ខណគ្រប់គ្រាន់ហើយនោះ តុលាការត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងទៅសហព័ទ្ធចុងចម្លើយជាចាំបាច់ ព្រោះថាការបញ្ជូនពាក្យបណ្តឹងនេះ គឺជាការផ្តល់ឱកាសឲ្យសហព័ទ្ធម្ខាងទៀតបានដឹងអំពីបណ្តឹងថា តើបុគ្គលណាជាអ្នកប្តឹង កម្មវត្ថុនៃបណ្តឹងគឺជាអ្វី និង មធ្យោបាយតទល់របស់ដើមចោទជាដើម ហើយវាក៏ជាការផ្តល់ឱកាសឲ្យសហព័ទ្ធចុងចម្លើយ ឆ្លើយដោះសារ និង រៀបចំមធ្យោបាយសម្រាប់ការពារខ្លួនផងដែរ ។

ការបញ្ជូនពាក្យបណ្តឹង គឺជាលក្ខខណ្ឌមួយដែលមានសារៈសំខាន់ណាស់ ដោយហេតុថា

ពេលពាក្យបណ្ដឹងត្រូវបានបញ្ជូនទៅសហាព័ន្ធចុងចម្លើយ[79]ទើបបណ្ដឹងនោះត្រូវបានចាត់ការទៅតាមនីតិវិធីរបស់តុលាការ ។

ការបញ្ជូនពាក្យបណ្ដឹងអាចប្រព្រឹត្តិទៅបានលុះត្រាតែ សហាព័ន្ធដើមចោទបានត្រៀមនូវឯកសារចម្លងនៃពាក្យបណ្ដឹងមួយច្បាប់ ហើយតុលាការនឹងបញ្ជូនច្បាប់ចម្លងនៃពាក្យបណ្ដឹងលែងលះនោះទៅសហាព័ន្ធចុងចម្លើយ ដើម្បីឲ្យសហាព័ន្ធចុងចម្លើយដឹងអំពីដំណើររឿង ឬ មូលហេតុដែលសហាព័ន្ធដើមចោទបានប្ដឹងគាត់ ហើយតុលាការត្រូវរក្សាទុកនូវច្បាប់ដើមនៃពាក្យបណ្ដឹងនោះ ។ ដោយឡែកចំពោះ ករណីដែលពាក្យបណ្ដឹងមិនអាចបញ្ជូនទៅបាន ដោយសារអាសយដ្ឋានរបស់សហាព័ន្ធចុងចម្លើយដែលសហាព័ន្ធដើមចោទផ្ដល់ឲ្យនោះ មានភាពមិនច្បាស់លាស់ ឬ ក្នុងករណីដែលសហាព័ន្ធដើមចោទមិនបានបង់ប្រាក់សម្រាប់បញ្ជូនពាក្យបណ្ដឹងទុកជាមុន ។ ម៉្យាងវិញទៀត ក្នុងករណីដែលសហាព័ន្ធដើមចោទ ទោះបីបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវរុករកលំនៅឋាន ឬ ទីសំណាក់ ឬ កន្លែងផ្សេងទៀតដែលត្រូវធ្វើការបញ្ជូនក៏ដោយក៏នៅតែមិនអាចរកឃើញនោះ សហាព័ន្ធដើមចោទអាចដាក់ពាក្យសុំដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន[80] ។ ការបញ្ជូននេះត្រូវតែបញ្ជូនឲ្យទៅដល់សហាព័ន្ធដែលជាចុងចម្លើយ បើមិនដូច្នោះទេនីតិវិធីនឹងមិនអាចដំណើរការបានទេ ។

## ៣.៥. នីតិវិធីត្រៀមសម្រាប់ទាញហេតុផល

ជាដំណាក់កាលដំបូងមួយនៃនីតិវិធីរដ្ឋប្បវេណី ដែលធ្វើឡើងដើម្បីផ្ដល់ឱកាសដល់តុលាការក្នុងការរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីមិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដីនោះ ហើយក៏ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្ដី នៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលដោយផ្ទាល់មាត់ឲ្យបានល្អិតល្អន់[81] ។ នីតិវិធីត្រៀមសម្រាប់ទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន[82]។ បន្ទាប់ពីបានកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលរួចហើយ តុលាការត្រូវកោះហៅភាគី ដែលជាសហាព័ន្ធទាំងសងខាងឲ្យចូលខ្លួនដើម្បីធ្វើការទាញហេតុផលដោយគោរពតាមគោលការណ៍ចំពោះមុខ[83]។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលមិនចាំបាច់បើកជាសាធារណៈទេ គឺដោយសារតែកាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផលតុលាការ គ្រាន់តែធ្វើការកំណត់នូវចំណុចវិវាទតាមរយៈការរៀបចំអះអាងរបស់សហាព័ន្ធរៀបចំនូវ

[79] មាត្រា ៧៩ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[80] មាត្រា ២៥៥ វាក្យខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[81] មាត្រា១០៣ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[82] មាត្រា១០៥ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[83] មាត្រា៣ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

ភស្តុតាងដែលត្រូវត្រួតពិនិត្យតែប៉ុណ្ណោះ ។ សម្រាប់នីតិវិធីត្រៀមទាញហេតុផល តុលាការត្រូវឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុនៅគ្រប់កាលបរិច្ឆេទនីមួយៗ[84] ។

នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផលត្រូវកត់ត្រានូវចំណុចដូចជា: សញ្ញាណរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជីត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ[85] ។ ប្រសិនបើ សហាព័ទ្ធប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រា នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផលនោះ ក្រឡាបញ្ជីត្រូវកត់សេចក្តីប្តឹងតវ៉ានោះនៅក្នុងកំណត់ហេតុនោះ[86] ។ បញ្ញាត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលកំណត់ហេតុនោះវិនាស ឬ បាត់ ។

### ៣.៦. នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់

នៅក្នុងនីតិវិធីនេះ សហាព័ទ្ធត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[87] ។ ការអះអាងអង្គហេតុ ការរៀបចំចំណុចវិវាទ និង ការពិនិត្យជាភស្តុតាងជាការទាញហេតុផលផ្ទាល់មាត់ សហាព័ទ្ធគ្រាន់តែធ្វើសេចក្តីថ្លែងការណ៍នៃនីតិវិធីត្រៀមនោះវាជាការគ្រប់គ្រាន់ទៅហើយ ។

សេចក្តីថ្លែងការណ៍ ត្រូវធ្វើឡើងដោយភាគី ប៉ុន្តែដោយសារសេចក្តីថ្លែងការណ៍នេះ មិនមែនជាសកម្មភាពបណ្តឹង យើងមិនចាំបាច់ដាក់កំហិតដាច់ខាតឲ្យសហាព័ទ្ធជាអ្នកអះអាងនោះទេ ។ រាល់សកម្មភាពដែលធ្វើឡើងនៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល សុទ្ធតែមានកត់ត្រានៅក្នុងកំណត់ហេតុនៃនីតិវិធីត្រៀមនោះស្រាប់ ដូចនេះសហាព័ទ្ធដើមចោទ សហាព័ទ្ធចុងចម្លើយ ឬ តុលាការអាចធ្វើសេចក្តីថ្លែងការណ៍នេះបានដែរ ។ សេចក្តីថ្លែងការណ៍អាចធ្វើឡើងដោយសង្ខេបទៅលើការអះអាងអំពី អង្គហេតុ ការដាក់ភស្តុតាងលទ្ធផលនៃការពិនិត្យភស្តុតាងលទ្ធផលនៃការរៀបចំចំណុចវិវាទដែលបានធ្វើឡើងនៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលនោះ ។

### ៣.៧. ការប្រកាសសាលក្រម

ការប្រកាសសាលក្រម គឺជាដំណាក់កាលដែលតុលាការធ្វើការសម្រេចសេចក្តីលើរឿងក្តី ហើយបានចេញជាលទ្ធផល និងប្រកាសឲ្យសហាព័ទ្ធទាំងសងខាងបានដឹង ។ ហើយការប្រកាសសាលក្រមនៃបណ្តឹងលែងលះបានបែងចែកជាពីរ គឺ ការប្រកាសសាលក្រមចំពោះមុខ និង ការប្រកាសសាលក្រមកំបាំងមុខ។

[84] មាត្រា១០៩ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[85] មាត្រា១១០ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[86] មាត្រា១១២ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[87] មាត្រា១១២ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

### ៣.៧.១. សាលក្រមចំពោះមុខ

ការប្រកាសសាលក្រមត្រូវធ្វើឡើងតាមការបរិច្ឆេទ នៅក្នុងសវនាការដែលជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ជាអ្នកអានសេចក្ដីសម្រេចបញ្ចប់ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម ។ ប្រសិនបើប្រធានក្រុមប្រឹក្សាជំនុំជម្រះមានធុរៈដោយមិនអាចចូលរួមបាន អាចអនុញ្ញាតឲ្យចៅក្រមប្រឹក្សាអានជំនួសប្រធានក្រុមប្រឹក្សាជំនុំជម្រះនូវសាលក្រមនោះបាន ។ ហើយការអានជំនួសនេះពុំមានឥទ្ធិពលអ្វីដែលធ្វើឲ្យផ្លាស់ប្ដូរនូវអត្ថន័យនៃសេចក្ដីសម្រេចរបស់សាលក្រមឡើយ ព្រោះក្រុមប្រឹក្សាជំនុំជម្រះបានពិភាក្សា និង សម្រេចរួចហើយ[88] ។ ដូចនេះការអាន គឺជាការប្រកាសចំពោះការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះតែប៉ុណ្ណោះ ។ ជាងនេះទៅទៀតក្រុមប្រឹក្សាជំនុំជម្រះ អាចអានសំអាងហេតុនៃសាលក្រម ឬក៏អាចពន្យល់ខ្លឹមសារនៃសំអាងហេតុនោះដោយផ្ទាល់មាត់បាន ។

### ៣.៧.២. សាលក្រមកំបាំងមុខ

នៅពេលដែលមានការអវត្តមានរបស់សហព័ទ្ធចុងចម្លើយ ដែលអវត្តមាននោះគ្មានមូលហេតុត្រឹមត្រូវ ឬ មិនបានជូនដំណឹងដល់តុលាការទេ នោះតុលាការអាចសម្រេចក្នុងការប្រកាសសាលក្រមបាន[89] ដែលនេះជាសាលក្រមកំបាំងមុខ ។ តែផ្ទុយទៅវិញ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ បើសហព័ទ្ធមិនបានបង្ហាញខ្លួន ព្រោះតែសហព័ទ្ធមិនបានទទួលបានការកោះហៅស្របច្បាប់ ឬ សហព័ទ្ធពិតជាមានមូលហេតុដែលមិនអាចបង្ហាញខ្លួនបានមែនដោយសារតែគ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈផ្សេងទៀតដែលមិនអាចចៀសវាងបាន[90] ។ ដោយមូលហេតុនេះ សហព័ទ្ធអាចធ្វើការប្ដឹងចំពោះសាលក្រមនោះបាន ដែលបណ្ដឹងទាស់នេះត្រូវធ្វើឡើងក្នុងពេល ២សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ[91] ដោយមិនអាចពន្យាបានឡើយ ។

ជាចុងក្រោយ តុលាការនឹងធ្វើការប្រកាសសាលក្រមលើបណ្ដឹងលែងលះគ្នានោះ ដែលបញ្ជាក់នូវលទ្ធផលអាច ឬមិនអាចលែងលះគ្នាបាន ។

- អាចលែងលះគ្នាបាន : នៅពេលដែលតុលាការរកឃើញថា ការលែងលះគ្នានោះបានកើតឡើងដោយឆន្ទៈពិតប្រាកដរបស់សហព័ទ្ធទាំងសងខាង ដោយពុំមាន ឥទ្ធិពលនៃការគំរាមកំហែងបង្ខិតបង្ខំទេ ពោលគឺដោយការស្ម័គ្រចិត្តពិតប្រាកដ ក្នុងការបញ្ចប់ចំណងអាពាហ៍ពិពាហ៍នេះពិតមែន នោះតុលាការនឹងសម្រេចឲ្យលែងលះគ្នាបាន ។

[88] មាត្រា ១៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នា ២០០៦
[89] មាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
[90] មាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦
[91] មាត្រា ២០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

- មិនអាចលែងលះគ្នាបាន : នៅពេលដែលចៅក្រមយល់ឃើញថា ការលែងលះរបស់សហព័ទ្ធនឹងបណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន តុលាការអាចសម្រេចច្រានចោលការទាមទារការលែងលះគ្នា ដោយពិចារណាទៅលើស្ថានភាពទាំងឡាយបាន ។ ជាបញ្ចប់ តុលាការនឹងធ្វើការសម្រេចសេចក្តីតាមការទាមទារ ឬមិនតាមការទាមទារ ដោយផ្អែកទៅលើការពិនិត្យការ វិនិច្ឆ័យទៅតាមដំណាក់កាលតាំងពីដំបូង រហូតដល់ការបញ្ចប់នៃរឿងក្តីនៃបណ្តឹងលែងលះ ដោយសម្រេចទៅតាមការពិចារណា ការគិតគូយ៉ាងល្អិតល្អន់ និងការផ្តល់នូវភាពយុត្តិធម៌ជូនដល់គូភាគីទាំងពីរ ។

## ផ្នែកទី៣ អានុភាពនៃការលែងលះ

### កថាខណ្ឌទី១ ការរំលាយចំណងអាពាហ៍ពិពាហ៍

នៅពេលដែលសាលក្រមលែងលះចូលជាស្ថាពរវាមានអានុភាពរំលាយចំណងអាពាហ៍ពិពាហ៍រវាងគូភាគី ដែលគិតចាប់ពីថ្ងៃដែលប្រកាសសាលក្រមស្ថាពរ ។
ដូច្នេះ ចំណងគតិយុត្តិអំពីបុគ្គលនៃអ្នកទាំងពីរត្រូវបានកាត់ផ្តាច់លែងមានសិទ្ធិ និងករណីយកិច្ចរវាងគ្នានឹងគ្នា ដូចកាលនៅមានចំណងអាពាហ៍ពិពាហ៍នឹងគ្នាទៀតហើយ ។ ការរំលាយចំណងអាពាហ៍ពិពាហ៍ ជាមូលហេតុធ្វើឲ្យចំណងគតិយុត្តិ ដែលមានការទាក់ទងដទៃទៀតប្រែប្រួល និងផ្លាស់ប្តូរដែរ មានដូចជាការបែងចែកទ្រព្យសម្បត្តិជាដើម ។

### កថាខណ្ឌទី២ ការបែងចែកទ្រព្យ

នៅពេលដែលសហព័ទ្ធជាប្តីប្រពន្ធលែងលះគ្នា វាធ្វើឲ្យមានការពិបាកនៅក្នុងការបែងចែកទ្រព្យ ។ សហព័ទ្ធម្ខាងតែងតែទាមទារចង់បានចំណែកច្រើនរៀងៗខ្លួន ដែលវាជាបញ្ហាដែលពិបាកដោះស្រាយបំផុតចំពោះការបែងចែក ។ ដោយយោងទៅតាមក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ បានកំណត់ការបែងចែកទ្រព្យជាពីរគឺ ការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀង និង ការបែងចែកទ្រព្យសម្បត្តិដោយគ្មានការព្រមព្រៀង ។

#### ១. ការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀង

នៅពេលដែលគូភាគីបានធ្វើការលែងលះ ការបែងចែកទ្រព្យសម្បត្តិក៏កើតមានឡើងដោយផ្អែកទៅតាមការពិភាក្សារបស់សហព័ទ្ធទាំងសងខាងផងដែរ ។ ហើយការបែងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀងនេះ មានលក្ខណងាយស្រួលសម្រាប់ចៅក្រមក្នុងការសម្រេចសេចក្តី ។

ដោយយោងទៅតាមបញ្ញាត្តិច្បាប់នៃក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ បានអនុញ្ញាតឲ្យសហព័ទ្ធទាំងពីរអាចព្រមព្រៀងគ្នាចុះកិច្ចសន្យានៅលើទ្រព្យសម្បត្តិនៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បានដោយមិនឲ្យផ្ទុយនឹងអាហាកាតព្វកិច្ច និងភាគបម្រុងឡើយ ហើយការបែងចែកទ្រព្យសម្បត្តិគឺ ត្រូវតែផ្អែកទៅកិច្ចព្រមព្រៀងរបស់ភាគីដែលបានចែងក្នុងកិច្ចសន្យានោះផងដែរ ។ ការធ្វើបែបនេះវាអាចជានីតិវិធីមួយ ដែលជាភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលដែលសហព័ទ្ធធ្វើការលែងលះគ្នា ដោយសារតែភាគីបានព្រមព្រៀងគ្នាចុះកិច្ចសន្យាជាមុនរួចហើយ ហើយពួកគាត់អាចធ្វើការបែងចែកទ្រព្យសម្បត្តិដោយផ្អែកទៅតាមកិច្ចសន្យាដែលសហព័ទ្ធបានចុះជាមួយគ្នានោះ។[92]
ក្នុងករណីដែលសហព័ទ្ធទាំងពីរ បានពិភាក្សាព្រមព្រៀងគ្នាតាមឆន្ទៈរបស់អ្នកទាំងពីរហើយ តុលាការនឹងធ្វើការបែងចែកទ្រព្យសម្បត្តិទាំងនោះ ដោយយុត្តិធម៌ដែលផ្អែកទៅតាមការពិភាក្សារបស់សហព័ទ្ធទាំងសងខាង ។ ចំពោះការព្រមព្រៀងតាមការពិភាក្សាគ្នានេះ តុលាការត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ ដោយពិនិត្យមើលឲ្យច្បាស់ថា ការព្រមព្រៀងនោះកើតឡើងដោយការបង្ខិតបង្ខំ ឬការគំរាមកំហែងដែលសកម្មភាពបែបនេះមិនមែនជាការព្រមព្រៀងដែលផុសចេញពីឆន្ទៈរបស់សហព័ទ្ធនោះទេ ។ តែប្រសិនបើ ការព្រមព្រៀងនោះ ពិតជាឯកភាពតាមការពិភាក្សាមែននោះ តុលាការត្រូវបែងចែកដោយយុត្តិធម៌ដោយផ្អែកទៅតាមការពិភាក្សានោះ ទោះបីជាទ្រព្យសម្បត្តិនោះជាទ្រព្យរួម ឬ ទ្រព្យដោយឡែកក៏ដោយ ។

### ២. ការបែងចែកទ្រព្យសម្បត្តិដោយគ្មានការព្រមព្រៀង

ក្នុងករណីដែលសហព័ទ្ធទាំងសងខាងមិនអាចធ្វើការពិភាក្សាគ្នាបានទេ ត្រូវបែងចែកទ្រព្យសម្បត្តិ ដោយផ្អែកតាមតាមចំណុចនីមួយៗដូចកំណត់ខាងក្រោមនេះ ៖

- សហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែក ដែលពួកគាត់មានមុនពេលអាពាហ៍ពិពាហ៍ ដូចដែលបានកំណត់ក្នុងមាត្រា៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ហើយទ្រព្យសម្បត្តិដោយឡែកនោះរួមមាន ៖
  - ទ្រព្យសម្បត្តិដែលសហព័ទ្ធមាន នៅមុនពេលអាពាហ៍ពិពាហ៍
  - ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍
  - ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ។

[92] មាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

- បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែកសហព័ទ្ធនីមួយៗមានសិទ្ធិទទួលពាក់កណ្តាលនៃទ្រព្យសម្បត្តិរួម ។ ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចចែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើតទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូនជាអាទិ៍ ។ ជាងនេះទៅទៀត ការងារគេហកិច្ច ក៏ត្រូវបានចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះ។

ចំពោះបញ្ហាបំណុលដែលសហព័ទ្ធទាំងសងខាង ជំពាក់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ សហព័ទ្ធអាចធ្វើការពិភាក្សាដោយផ្អែកតាមការព្រមព្រៀងគ្នា ក្នុងការសងបំណុលបាន។ ម៉្យាងវិញទៀតតុលាការនៅតែមានសិទ្ធិសម្រេចសេចក្តី នៅពេលដែលសហព័ទ្ធមិនអាចពិភាក្សាគ្នាបាន ឬ បំណុលនោះអាចបែងចែកជាការសងពាក់កណ្តាលម្នាក់ក៏បានដែរ ជាងនេះថែមទៀត តុលាការក៏ត្រូវសម្រេចនូវអំណាចមេបាផងដែរ ក្នុងការបីបាច់ថែរក្សាកូនដែលជាអនីតិជន នឹងធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ។

## កថាខណ្ឌទី៣ ការបែងចែកកូន

### ១. ការបែងចែកកូនដោយមានការព្រមព្រៀងរបស់ភាគី

កូនជាកត្តាសំខាន់សម្រាប់សហព័ទ្ធដែលលែងលះគ្នា បើមានការព្រមព្រៀងគ្នាក្នុងការប្រគល់ និងទទួលយកកូនរបស់សហព័ទ្ធទាំងពីរ នោះតុលាការត្រូវសម្រេចសេចក្តីទៅតាមការព្រមព្រៀងរបស់សហព័ទ្ធ[93] ។ រាល់ការសម្រេចអំពីអំណាចមេបានៅពេលដែលសហព័ទ្ធលែងលះគ្នាត្រូវកំណត់យកឪពុក ឬ ម្តាយជាអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្តាយ ។ ផ្ទុយទៅវិញ បើឪពុកម្តាយបានលែងលះគ្នាមុនកំណើតរបស់កូន នោះម្តាយជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតនោះ ។ ហើយឪពុកម្តាយអាចធ្វើការពិភាក្សាគ្នា ប្រសិនបើគាត់ធ្វើការលែងលះក្រោយកំណើតរបស់កូន ដោយកំណត់យកឪពុកជាអ្នកមានអំណាចមេបា[94] ។

[93] មាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[94] មាត្រា ១០៣៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ២. ការបែងចែកកូនដោយមិនមានការព្រមព្រៀងរបស់ភាគី

ប្រសិនបើករណីខាងលើពុំអាចសម្រេច ឬ ពុំអាចពិភាក្សាបានទេ ច្បាប់បានធ្វើការផ្តល់អំណាចឆន្ទានុសិទ្ធិទៅតុលាការ ដើម្បីកំណត់អ្នកមានអំណាចមេបាក្នុងការអប់រំថែរក្សា ដោយគិតដល់ផលប្រយោជន៍របស់កូន មានន័យថា បើតុលាការស៊ើបអង្កេតឃើញថាសហព័ទ្ធម្ខាងមានជីវភាពធូធារ ដែលមានលទ្ធភាពក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនបានល្អដោយមិនឲ្យខូចប្រយោជន៍របស់កូន នោះតុលាការមានឆន្ទានុសិទ្ធិក្នុងការប្រគល់កូនឲ្យសហព័ទ្ធនោះជាអ្នកថែរក្សា[95] ។ ជាគោលការណ៍ កូនដែលនៅបៅដោះនៅពេលដែលឪពុកម្តាយលែងលះគ្នា ត្រូវបានទៅនៅខាងម្តាយដែលជាអ្នកថែរក្សា ពីព្រោះម្តាយជាអ្នកមានទឹកដោះដើម្បីចិញ្ចឹមកូន និង មានភាពស្ទាត់ជំនាញខាងថែរក្សាទារកជាងបុរសដែលជាឪពុក ។ ចំពោះកូនដែលលែងបៅដោះក៏មិនអាចកំណត់បានថា បានទៅខាងឪពុកជាអ្នកគ្រប់គ្រងដែរ វាជាឆន្ទានុសិទ្ធិរបស់តុលាការជាអ្នកដែលធ្វើការសម្រេចលើបញ្ហានេះ។ ចំណែកកូនដែលទើបនឹងធំដឹងក្តីនៅពេលឪពុកម្តាយលែងលះគ្នា តុលាការអាចសាកសួរទៅកូននោះថា តើចង់ទៅរស់នៅជាមួយឪពុក ឬ ម្តាយ ប្រសិនបើកូននោះនិយាយថាចង់រស់នៅជាមួយឪពុក ឬ ម្តាយ នោះតុលាការមានសិទ្ធិសម្រេចតាមការសម្រេចរបស់កូន ។ ញាតិនៅក្នុងថ្នាក់ទី ៤ របស់កូនសហព័ទ្ធអាចធ្វើការទាមទារតុលាការឲ្យមានការផ្លាស់ប្តូរអំណាចមេបាបាន ប្រសិនបើតុលាការទទួលស្គាល់ថាជាការចាំបាច់ដើម្បីផលប្រយោជន៍កូន ។

ទោះបីជាចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធទាំងពីរបានកាត់ផ្តាច់មែន ក៏ប៉ុន្តែចំណងឪពុកម្តាយជាមួយកូន មិនអាចកាត់ផ្តាច់បានឡើយ ។ សហព័ទ្ធដែលមើលថែរក្សាកូន ត្រូវតែផ្តល់លទ្ធភាពឲ្យទៅភាគីម្ខាងទៀតបានមកសួរសុខទុក្ខកូនបានគ្រប់ពេលវេលា ដោយមិនធ្វើឲ្យមានភាពស្មុគស្មាញ ឬ រារាំងដល់សហព័ទ្ធម្ខាងទៀតមិនឲ្យប្រាស្រ័យទាក់ទងជាមួយកូនឡើយ និង មានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន[96] ។ ប្រសិនបើការចូលជួបកូនពុំបានសម្រេច តុលាការត្រូវកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុក ដើម្បីថែរក្សាកូនតាមការទាមទាររបស់ឪពុក ឬ ម្តាយ[97] ។ យោងតាមសេចក្តីសម្រេចរបស់តុលាការ កូនដែលមានអាយុក្រោម៦ឆ្នាំ ច្រើនប្រគល់ឲ្យទៅរស់នៅជាមួយម្តាយ។

---

[95] មាត្រា ១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[96] មាត្រា ១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[97] មាត្រា ១០៤០ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ចំពោះកូនដែលមានអាយុលើសពី៦ឆ្នាំ បើជាកូនស្រីត្រូវតែទៅរស់នៅជាមួយម្ដាយ ហើយកូនប្រុសត្រូវទៅរស់នៅជាមួយឪពុក ។ ប៉ុន្តែជាទូទៅតុលាការតែងតែធ្វើសេចក្ដីសម្រេច ឲ្យទៅម្ដាយជាអ្នកជាគ្រប់គ្រងថែរក្សាចិញ្ចឹមកូនដើម្បីចៀសវាងកុំឲ្យកូនរស់នៅបែកគ្នា ។

## កថាខណ្ឌទី៤ អាហារកិច្ច

### ១. អាហារកិច្ចចំពោះកូន

#### ១.១. អាហារកិច្ចចំពោះកូនដោយការព្រមព្រៀង

ប្តីប្រពន្ធដែលបានលែងលះគ្នាហើយ ត្រូវបីបាច់ថែរក្សាជួយផ្គត់ផ្គង់ផ្តល់សោហ៊ុយអប់រំ ការហូបចុក និងការរៀនសូត្រដល់កូនទៅតាមលទ្ធភាពរបស់ខ្លួន ។ ពោលគឺ តុលាការត្រូវសម្រេចសេចក្តីតាមការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរ ។ ផ្ទុយទៅវិញ បើមិនមានការព្រមព្រៀងពីភាគីម្ខាងដែលទទួលយកកូនទៅចិញ្ចឹមថាមិនព្រមទទួលយកអាហារកិច្ចចិញ្ចឹមពីសហព័ទ្ធម្ខាងទៀតទេ នោះតុលាការមិនសម្រេចសេចក្តីតាមការព្រមព្រៀងនោះទេ គឺសម្រេចឲ្យសហព័ទ្ធដែលមិនទទួលយកកូនទៅចិញ្ចឹមឲ្យបង់អាហារកិច្ចចិញ្ចឹមកូន ធ្វើយ៉ាងនេះគឺដើម្បីកុំឲ្យសហព័ទ្ធដែលមិនបានចិញ្ចឹមកូនមានការឃ្លាតឆ្ងាយពីកូនខ្លាំងពេក ។

#### ១.២.អាហារកិច្ចចំពោះកូនដោយមិនមានការព្រមព្រៀងរបស់ភាគី

ក្នុងករណីមិនមានការព្រមព្រៀងរបស់សហព័ទ្ធទាំងពីរចំពោះអាហារកិច្ចរបស់កូនទេនោះ តុលាការត្រូវពិនិត្យអំពីជីវភាព និងប្រាក់ចំណូលរបស់សហព័ទ្ធដែលត្រូវផ្តល់ ហើយសម្រេចសេក្តីទៅតាមលទ្ធភាពរបស់គេដោយមិនត្រូវឲ្យលើសពីសម្ថភាពរបស់គេនោះទេ ហើយអាហារកិច្ចនេះត្រូវសម្រេចរហូតដល់កូនមាននីតិភាព ។ ការមិនព្រមបង់អាហារកិច្ចដល់កូន គឺជាអំពើដែលចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន បើកាលណាមានភស្តុតាងបញ្ជាក់ថាសហព័ទ្ធដែលត្រូវផ្តល់អាហារកិច្ចនោះមានភាពមិនស្មោះត្រង់ ។ ប្រសិនបើ សហព័ទ្ធជាឪពុក ឬ ម្តាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ ធ្វើឲ្យធ្វេសប្រហែសក្នុងការបំពេញករណីកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា ដោយឲ្យកូនធ្លាក់ក្នុងភាពយ៉ាប់យឺនពាលាអាវ៉ាសែ ដោយពុំបានគិតគូពីផលប្រយោជន៍របស់កូន មិនបានអប់រំទូន្មាន

កូន និងពុំបានផ្គត់ផ្គង់ឲ្យកូនបានទៅរៀន ដែលអាចនឹងឃើញថាកូនរបស់ខ្លួននឹងគ្មានអនាគត បើបន្តរស់នៅជាមួយអ្នកមានអំណាចមេបានោះតទៅទៀត នោះសហព័ទ្ធដែលមិនមានអំណាចមេបាក្នុងការថែរក្សាកូន មានសិទ្ធិប្ដឹងមកតុលាការដើម្បីដកយកកូននោះមកចិញ្ចឹមវិញ ហើយតុលាការអាចប្រកាសព្យួរ ឬ ដកហូតអំណាចមេបាតាមការស្នើសុំនោះបាន ឬ តាមការទាមទាររបស់ញាតិទាំង៤ថ្នាក់របស់កូន មេឃុំ-ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខមាលភាព ឬ តំណាងអយ្យការបាន [98]។

ប្រសិនបើការកាត់ក្ដីរបស់ចៅក្រមនៅក្នុងសាលក្រមនេះ មានសហព័ទ្ធណាមួយមិនសុខចិត្ត នោះសហព័ទ្ធដែលមិនសុខចិត្តនោះ មានសិទ្ធិប្ដឹងទៅសាលាឧទ្ធរណ៍ក្នុងកំឡុងរយៈពេលកំណត់២ខែចំពោះសាលក្រមចំពោះមុខ ។ ចំពោះសាលក្រមកំបាំងមុខវិញ គឺប្ដឹងទាស់រយៈពេល១៥ថ្ងៃ និងប្ដឹងឧទ្ធរណ៍រយៈពេល ២ខែ គិតត្រឹមពីថ្ងៃផុតកំណត់ប្ដឹងទាស់ ។ ក្នុងរយៈពេលនេះ បើពុំមានសហព័ទ្ធណាមួយចូលមកប្ដឹងក្នុងរយៈពេលនេះទេ សាលក្រមត្រូវចូលជាស្ថាពរ ហើយសហព័ទ្ធទាំងពីរត្រូវអនុវត្តតាមសាលក្រមនេះជាកំណត់ ។

អាហារកិច្ចដែលសហព័ទ្ធនីមួយៗត្រូវផ្ដល់ឲ្យកូនត្រូវឲ្យជាទឹកប្រាក់ ឬ អាចជារបស់អ្វីមួយសំរាប់ខែនីមួយៗ ។

## ២. អាហារកិច្ចចំពោះសហព័ទ្ធ

### ២.១. អាហារកិច្ចចំពោះសហព័ទ្ធដោយការព្រមព្រៀងរបស់ភាគី

ជាទូទៅការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ករណីកិច្ចដែលសហព័ទ្ធមានចំពោះគ្នានឹងគ្នាក្នុងឋានៈជាប្ដី-ប្រពន្ធក៏បញ្ចប់ដែរ ។ ប៉ុន្តែចំពោះករណីអាហារកិច្ចដែលប្ដីប្រពន្ធត្រូវបំពេញចំពោះគ្នាក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ អាចបន្តទៅទៀតបានបន្ទាប់ពីការលែងលះគ្នា ។ ហេតុនេះហើយបានជាអតីតស្វាមី ឬ អតីតភរិយាអាចមានករណីកិច្ចបន្តទៅមុខទៀតបានបន្ទាប់ពីការលែងលះគ្នាបានបញ្ចប់ដើម្បីចេញប្រាក់ជួយគាំទ្រអតីតប្រពន្ធ ឬ ប្ដីរបស់ខ្លួន ។ ប្រសិនបើក្រោយការលែងលះគ្នាបានចប់សព្វគ្រប់ហើយ សហព័ទ្ធណាម្នាងមានស្ថានភាពខ្វះខាតខាងផ្នែកជីវភាព នោះសហព័ទ្ធនោះអាចស្នើសុំដល់តុលាការសុំឲ្យសហព័ទ្ធម្ខាងទៀត ទោះជាកំហុសក្ដី ឬ គ្មានកំហុសក្ដី និងមានជីវភាពប្រសើរជាងខ្លួនឲ្យជួយឧបត្ថម្ភអាហារកិច្ចដល់ខ្លួនទៅតាមលទ្ធភាពប៉ុន្តែបើសហព័ទ្ធដែលខ្វះខាតនោះមាន

[98] មាត្រា ១០៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ប្តី ឬ ប្រពន្ធថ្មីទៀតនោះនឹងមិនមានសិទ្ធិដើម្បីទទួលអាហារកិច្ចនេះទៀតទេ [99]។

## ២.២. អាហារកិច្ចចំពោះសហព័ទ្ធដោយមិនមានការព្រមព្រៀង

ជាគោលការណ៍ការផ្តល់អាហារកិច្ចដល់សហព័ទ្ធខ្វះខាតក្តី តុលាការអាចសម្រេចកែប្រែបានដោយអាចបន្ថយ ឬ បន្ថែមចំនួននៃការផ្តល់ ប្រសិនបើមានសំណូមពរពីសហព័ទ្ធម្ខាង ។ ការសម្រេចកែប្រែនេះ គឺយោងទៅតាមលទ្ធភាពរបស់សហព័ទ្ធដែលជាអ្នកផ្គត់ផ្គង់អាហារកិច្ច មានន័យថាមុនធ្វើការសម្រេចចិត្ត តុលាការត្រូវស៊ើបអង្កេតឲ្យបានច្បាស់លាស់ពីចំណូលប្រចាំខែរបស់សហព័ទ្ធម្ខាងនោះ ជាពិសេសគឺទៅតាមការសម្រេចចិត្តរបស់ពួកគេផ្ទាល់ ។

ការខ្វះខាតរបស់សហព័ទ្ធរួមមាន : សមត្ថភាពរកប្រាក់បាននៃសហព័ទ្ធដែលចង់ឲ្យសហព័ទ្ធម្ខាងទៀតផ្តល់អាហារកិច្ចដល់ខ្លួន អាយុ សុខភាព និងកំរិតជីវភាពរបស់សហព័ទ្ធស្នើសុំការផ្តល់អាហារកិច្ច ។

**កំណត់សម្គាល់ចុងក្រោយ** ការមិនបង់អាហារកិច្ចដល់សហព័ទ្ធចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន បើរកឃើញភស្តុតាងបញ្ជាក់ថាជនដែលត្រូវផ្តល់អាហារកិច្ចនោះ មានភាពមិនស្មោះត្រង់ចំពោះអ្នកទទួលអាហារកិច្ច ។ ប្រសិនបើសហព័ទ្ធដែលទទួលខុសត្រូវផ្គត់ផ្គង់អាហារកិច្ច មិនបានគោរពតាមសេចក្តីសម្រេចស្ថានភាពរបស់តុលាការដោយមិនព្រមបង់រយៈពេល ២ (ពីរ) ខែ យ៉ាងតិចនូវអាហារកិច្ចដល់សហព័ទ្ធ ឬ អតីតសហព័ទ្ធរបស់ខ្លួន ដល់កូនជាអនីតិជនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីរ ១ខែ ដល់ ១ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន)រៀល ដល់ ២.០០០.០០០ (ពីរលាន)រៀល[100] ។

[99] មាត្រា ៧៦ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ

[100] មាត្រា ៣២៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១

# សេចក្តីសន្និដ្ឋាន

ដោយឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ ក្រោមប្រធានបទ " អាពាហ៍ពិពាហ៍ និង ការលែងលះ " រួចមកក្រុមរបស់យើងខ្ញុំយល់ឃើញថា ចំណងអាពាហ៍ពិពាហ៍មួយអាចកើតឡើងបានលុះត្រាតែភាគីទាំងសងខាងគោរពទៅតាមនីតិវិធីដែលច្បាប់បានចែង ក៏ដូចជាលក្ខខណ្ឌនានាដែលច្បាប់តម្រូវឲ្យភាគីនីមួយៗអនុវត្តតាម ។ ជាងនេះទៅទៀត ពួកគាត់ត្រូវតែទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាដាច់ខាត បើពុំនោះទេអាពាហ៍ពិពាហ៍របស់ពួកគាត់ពុំមានចំណងគតិយុត្តអ្វីឡើយ ។

ផ្ទុយទៅវិញ ប្រសិនបើចំណងអាពាហ៍ពិពាហ៍ដែលស្របច្បាប់របស់ពួកគាត់មានភាពរង្គោះរង្គើ ឬ ជួបប្រទះនូវបញ្ហាមួយចំនួនដែលនាំឲ្យឈានដល់ដំណាក់កាលដែលមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ទោះបីជាពួកគាត់ទាំងពីរធ្លាប់ទទួលបាននូវការផ្សះផ្សា ដែលពេលខ្លះការផ្សះផ្សានោះទទួលបានជោគជ័យ ហើយបញ្ហាមួយចំនួនមិនអាចធ្វើការផ្សះផ្សាបាន ដែលមូលហេតុទាំងនេះហើយដែលធ្វើឲ្យចំណងអាពាហ៍ពិពាហ៍របស់ពួកគាត់ឈានដល់ការលែងលះ ។
ក្នុងករណីដែលពួកគាត់ចង់លែងលះគ្នា សហព័ទ្ធទាំងពីរត្រូវតែដាក់ពាក្យសុំលែងលះទៅតុលាការ និង ត្រូវឆ្លងកាត់នូវនីតិវិធីតាមផ្លូវតុលាការជាច្រើនដំណាក់កាលទៀត ទើបពួកគាត់អាចធ្វើការលែងលះគ្នាបាន ។ ដោយយោងទៅតាមបញ្ញត្តិមាត្រាដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានការពារនូវផលប្រយោជន៍របស់សហព័ទ្ធទាំងសងខាង បន្ទាប់ពីពួកគាត់បានលែងលះគ្នាហើយនោះ មិនថាជាភាគីប្តី ឬ ប្រពន្ធ ព្រមទាំងកូនផងដែរ ត្រូវទទួលបាននូវការការពារពីច្បាប់ ។ នៅពេលដែលការលែងលះនោះមានអានុភាពហើយនោះ សហព័ទ្ធទាំងពីរត្រូវតែធ្វើការព្រមព្រៀងគ្នានូវការបែងចែកទ្រព្យសម្បត្តិ ការផ្តល់អាហារកាតព្វកិច្ចដល់កូន និង ដល់អតីតសហព័ទ្ធណាមួយណាមួយដែលមានការខ្វះខាតក្រោយការលែងលះ ការប្រគល់អំណាចមេបាដោយឲ្យកូនទៅរស់នៅជាមួយសហព័ទ្ធណាមួយ និង សហព័ទ្ធដែលមានអំណាចមេបាត្រូវផ្តល់ឱកាសឲ្យសហព័ទ្ធដែលមិនមានអំណាចមេបាបានជួបប្រាស្រ័យទាក់ទងជាមួយកូនផងដែរ ។

សរុបសេចក្តីមក បុគ្គលគ្រប់រូបមុននឹងសម្រេចចិត្តចាប់ដៃគ្នាបង្កើតនូវចំណងអាពាហ៍ពិពាហ៍ដើម្បីបង្កើតជាក្រុមគ្រួសារមួយនៅក្នុងសង្គម ត្រូវតែធ្វើការត្រិះរិះពិចារណាឲ្យបានម៉ត់ចត់ គ្រប់ជ្រុងជ្រោយថាខ្លួនអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការដើរតួនាទីជាស្វាមី ជាភរិយា ជាឪពុក ជាម្តាយដ៏ល្អបានហើយឬនៅ ។ ម្យ៉ាងវិញទៀត ដើម្បីជៀសវាងនូវការបែកបាក់ក្រុមគ្រួសាររបស់សហព័ទ្ធដែលការបែកបាក់នោះធ្វើឲ្យបាត់បង់នូវផលប្រយោជន៍របស់សហព័ទ្ធ ជាពិសេសនោះ ចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរនិងពុំមានសេចក្តីសុខឡើយ ។

# អនុសាសន៍

ក្រោយពីបានសរសេរ និង រៀបចំនូវសារណាបញ្ចប់ការសិក្សានេះរួចមកឃើញថា ប្រជាជនមួយចំនួនមិនមានការយល់ដឹងអំពីរឿងអាពាហ៍ពិពាហ៍ និង ការលែងលះនៅឡើយ ដោយពួកគាត់ពុំបានទទួលបាននូវការផ្សព្វផ្សាយអំពីឯកសារច្បាប់ដែលពាក់ព័ន្ធ ដើម្បីធ្វើការរៀបអាពាហ៍ពិពាហ៍ និង ការលែងលះគ្នាជាដើម ។ ជាពិសេសប្រជាជនដែលរស់នៅតំបន់ជនបទដាច់ស្រយាល ពុំបានយល់ដឹងអំពីនីតិវិធីដែលនាំឲ្យមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ ដោយពួកគាត់អនុវត្តតាមទំនៀមទំលាប់ប្រពៃណីដែលមានតាំងពីដូនមកម្លេះ ដោយពួកគាត់គ្រាន់តែរៀបចំប្រារព្ធនូវអាពាហ៍ពិពាហ៍ ដើម្បីជាការបង្ហាញថា កូនកំលោះ កូនក្រមុំ ជាស្វាមីភរិយានឹងគ្នាហើយ ដោយពុំបានបំពេញទៅតាមផ្លូវច្បាប់ដូចជាគ្មានការចុះសំបុត្រអាពាហ៍ពិពាហ៍អ្វីឡើយ ។ មួយវិញទៀត នៅពេលដែលវិវាទកើតឡើងរវាងប្តី និង ប្រពន្ធ មិនដឹងថា តើត្រូវទៅប្តឹងទៅសមត្ថកិច្ចណាមួយឲ្យជួយដោះស្រាយ ដើម្បីទទួលបាននូវអានុភាពនៅក្រោយពេលលែងលះ ។

ដោយសារកង្វះខាតមួយចំនួននេះហើយ ទើបក្រុមរបស់យើងខ្ញុំ សូមចូលរួមនូវការផ្តល់ជាមតិយោបល់មួយចំនួនក្នុងគោលដៅដើម្បីធ្វើការកែតម្រូវនូវចំណុចទាំងនោះដូចជា ៖

- រដ្ឋាភិបាល ត្រូវផ្តល់ការផ្សព្វផ្សាយជាសាធារណៈ ដើម្បីឲ្យប្រជាជនបានយល់ច្បាស់អំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ និង នីតិវិធីនៃការលែងលះ ដើម្បីជាភាពងាយស្រួលដល់ពួកគាត់ ហើយក៏ជាចំណេះបន្ថែមទៀតសម្រាប់ពួកគាត់ប្រើប្រាស់នៅពេលណាដែលគាត់ជួបប្រទះនូវបញ្ហាទាំងនោះ ហើយក៏ជាវិធីមួយដើម្បីជួយកាត់បន្ថយនូវការលែងលះគ្នាផងដែរ ។

- សហព័ទ្ធទាំងពីរ ត្រូវតែស្មោះស្ម័គ្រមួយនឹងមួយ ដោយពុំមានចិត្តវៀចវេរ ដើម្បីរក្សានូវចំណងអាពាហ៍ពិពាហ៍កុំឲ្យឈានដល់ការលែងលះ ដែលជាមូលហេតុធ្វើឲ្យគ្រួសារដែលធ្លាប់តែមានសុភមង្គល ប្រែទៅជាគ្រួសារដែលបែកបាក់ទៅវិញ។

- រាល់កំហុសតិចតួចដែលសហព័ទ្ធណាម្ខាងបានប្រព្រឹត្ត ត្រូវតែចេះអត់អោនអធ្យាស្រ័យឲ្យគ្នាទៅវិញទៅមក ដើម្បីបញ្ចៀសនូវការបែកបាក់ ។